ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA

# របាយការណ៍ប្រចាំឆ្នាំ២០១២
# និង
# ទិសដៅការងារឆ្នាំ២០១៣

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING


ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA


# របាយការណ៍ប្រចាំឆ្នាំ២០១២

# និង

# ទិសដៅការងារឆ្នាំ២០១៣

# អារម្ភកថា

នៅឆ្នាំ២០១២ នេះ ស្ថានភាពសេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើងវិញក្នុងល្បឿនយឺតជាងមុន ដោយសារប្រទេសអភិវឌ្ឍន៍ខ្លះនៅប្រឈមហានិភ័យនៃការធ្លាក់ចុះនៃសេដ្ឋកិច្ច ប្រព័ន្ធហិរញ្ញវត្ថុនៅមានភាពផុយស្រួយ របៀបវារៈកំណែទម្រង់មិនទាន់អនុវត្តបានពេញលេញ និងជម្រើសគោលនយោបាយស្តារសេដ្ឋកិច្ចតាមតំបន់មិនទាន់មានភាពប្រាកដប្រជានៅឡើយ ។ ជាក់ស្តែង សហរដ្ឋអាមេរិកនៅបន្តប្រឈមនឹងអត្រានិកម្មភាពខ្ពស់ ខណៈវិបត្តិបំណុលនៅតំបន់អឺរ៉ុប ជាពិសេស ប្រទេសក្រិច អ៊ីតាលី អេស្ប៉ាញ និងព័រទុយហ្គាល់នៅមានសភាពតឹងតែងនៅឡើយ ។ នៅតំបន់អាស៊ី ប្រទេសកំពុងអភិវឌ្ឍន៍ដែលមានសេដ្ឋកិច្ចកំពុងងើបឡើងមួយចំនួន ដូចជា ប្រទេសចិន ឥណ្ឌា និងឥណ្ឌូនេស៊ី បន្តមានកំណើនវិជ្ជមាន ប៉ុន្តែក្នុងល្បឿនយឺតជាងមុន ដោយសារផលប៉ះពាល់ពីខាងក្រៅដែលបានធ្វើឲ្យការនាំចេញ និងការវិនិយោគថយចុះ ។

ទិន្នន័យប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ[១] បានបង្ហាញថា អត្រាកំណើនសេដ្ឋកិច្ចពិភពលោកឆ្នាំ២០១២ បានថយចុះដល់ ៣,៣% ពី ៣,៨% នៅឆ្នាំ២០១១ ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានអត្រាកំណើន ២,២% និងអឺរ៉ុប -0,៤% ។ ចំណែកឯសេដ្ឋកិច្ចតំបន់អាស៊ីមានអត្រាកំណើន ៥,៥% ក្នុងនោះប្រទេសចិន ៧,៨% ជប៉ុន ២,២% ឥណ្ឌា ៤,៩% និងអាស៊ាន៥[២] ៥,៤% ។

ចំពោះប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានវាយតម្លៃដោយសុទិដ្ឋិនិយមថា នៅឆ្នាំ២០១២ នេះ សេដ្ឋកិច្ចមានកំណើន ៧% ដែលទ្រទ្រង់ដោយកំណើនវិស័យកសិកម្ម ៣,២% ឧស្សាហកម្ម ១៣,៣% និងសេវាកម្ម ៥% ។ ទន្ទឹមនេះ ប្រតិបត្តិការជញ្ជីងទូទាត់មានស្ថានភាពប្រសើរជាងឆ្នាំមុន ដែលឆ្លុះបញ្ចាំងដោយសមតុល្យរួមមានអតិរេក ២,៣% នៃផសស ។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងដល់ប្រមាណ ៣,៤ ពាន់លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបាន ៤,៥ ខែ ។ ធនាគារជាតិនៃកម្ពុជាបន្តគ្រប់គ្រងទុនបម្រុងអន្តរជាតិស្របតាមគោលការណ៍វិនិយោគគឺ សុវត្ថិភាព សន្ទនីយភាព និងចំណូល ។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្នដើម្បីរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ នៅឆ្នាំ២០១២ អតិផរណាស្ថិតនៅក្រោមកម្រិតគោលដែលរាជរដ្ឋាភិបាលបានកំណត់ក្នុងរង្វង់ ៥% ដោយមានអត្រាមធ្យមប្រចាំឆ្នាំ ៣,១% ធៀបនឹង ៥,៥% នៅឆ្នាំ ២០១១ ។ តម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបន្តមានស្ថិរភាពល្អប្រសើរ និងថែមទាំងបានឡើងថ្លៃ ១,៧% ធៀបនឹងឆ្នាំមុន ដែលបណ្តាលមកពីការកើនឡើងនៃតម្រូវការប្រាក់រៀលក្នុងសកម្មភាពសេដ្ឋកិច្ច និងលំហូរចូលនៃទុនពីបរទេស ។ ស្ថានភាពនេះបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលជាលំដាប់ ។

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារយ៉ាងយកចិត្តទុកដាក់ សំដៅជំរុញប្រតិបត្តិការធនាគារឲ្យប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព និងសុវត្ថិភាព តាមរយៈការលើកកម្ពស់ការត្រួតពិនិត្យ និងការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិនានា ។ វិស័យធនាគារមានការអភិវឌ្ឍទាំងវិសាលភាព និងទំហំប្រតិបត្តិការ

---

១ World Economic Outlook (IMF) ខែតុលា ឆ្នាំ២០១២

២ អាស៊ាន ៥ រួមមានប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាម

ដែលឆ្លុះបញ្ចាំងដោយការកើនឡើងនូវចំនួនគ្រឹះស្ថានធនាគារនិងបណ្តាញសាខា ប្រាក់បញ្ញើ និងឥណទានចំពោះវិស័យឯកជន ។ ទន្ទឹមនេះ វិស័យមីក្រូហិរញ្ញវត្ថុក៏មានការរីកចម្រើន ដោយបានដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ ជារួម ប្រព័ន្ធធនាគារមានសុខភាពរឹងមាំ ដោយអនុបាតសាធនភាពនិងអនុបាតសន្ទនីយភាពខ្ពស់ជាងកម្រិតកំណត់ និងអនុបាតឥណទានមិនដំណើរការបានថយចុះមកនៅត្រឹម ២,៥% ។

ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាធនាគារកណ្តាលជូនក្រសួងស្ថាប័នរដ្ឋ ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាបានពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន Core Banking នៅតាមសាខារបស់ខ្លួន និងបានអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិដែលបានដាក់ឲ្យដំណើរការជាផ្លូវការនៅខែធ្នូ ឆ្នាំ២០១២ ដើម្បីជួយសម្រួលដល់ការផាត់ទាត់និងទូទាត់ ទាំងមូលប្បទានបត្រ និងឧបករណ៍ទូទាត់សងប្រាក់ផ្សេងៗទៀត ឲ្យកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាពថែមទៀត ។

ក្រោមជំនួយបច្ចេកទេសរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាដើម្បីដាក់ឲ្យដំណើរការជាផ្លូវការប្រព័ន្ធចែករំលែកព័ត៌មានឥណទាន កាលពីដើមឆ្នាំ២០១២នេះផងដែរ ។ ប្រព័ន្ធនេះបានទទួលការគាំទ្រយ៉ាងខ្លាំងពីសំណាក់ភាគីពាក់ព័ន្ធនានា ជាពិសេស បានរួមចំណែកធ្វើឲ្យបរិយាកាសអាជីវកម្មក្នុងប្រទេសកម្ពុជាមានភាពល្អប្រសើរជាងមុន (យោងតាមរបាយការណ៍របស់ធនាគារពិភពលោក) ។ ជាក់ស្តែងនៅចុងឆ្នាំនេះ ក្រុមការងារបច្ចេកទេសធនាគារកណ្តាលឡាវ និងប្រទេសកេនយ៉ា បានមកសិក្សាស្វែងយល់អំពីប្រវត្តិ ការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធចែករំលែកព័ត៌មានឥណទាននេះនៅធនាគារជាតិនៃកម្ពុជា ។

ដោយឡែក ការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ សម្រេចបាននូវវឌ្ឍនភាពជាជំហានៗ ដូចជាការរៀបចំកិច្ចបញ្ជិកាគណនេយ្យសម្រាប់ប្រតិបត្តិការទិញ-លក់-រក្សាមូលបត្រ ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា និងនីតិវិធីប្រតិបត្តិការផ្សេងៗសម្រាប់ការចេញផ្សាយមូលបត្រធនាគារកណ្តាល ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានសហការយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានធនាគារ ដើម្បីកំណត់លក្ខណៈរបស់វិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបានដែលធនាគារជាតិនៃកម្ពុជាគ្រោងនឹងចេញផ្សាយនៅពេលខាងមុខ ។

ចំពោះការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានជំរុញកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ-អន្តរជាតិ និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ ក្នុងការតាមដាន ស្វែងរក និងទប់ស្កាត់រាល់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ក្នុងស្មារតីនេះ ស.ហ.ក បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងធនាគារកណ្តាលវៀតណាម ។

សមិទ្ធផលដ៏សំខាន់មួយទៀតក្នុងការពង្រឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាគឺ ការដាក់ឲ្យប្រើប្រាស់ឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ដែលរាជរដ្ឋាភិបាលបានអនុម័តដាក់ឲ្យប្រើប្រាស់ជាផ្លូវការនាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ ។ ឯកសារនេះជាបច្ចុប្បន្នកម្មនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ដែលបានរៀបចំឡើងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំង

ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីជាមូលដ្ឋានក្នុងការបន្តពង្រឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងតំបន់ ។

ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការតំបន់និងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាសម្រេចបានសមិទ្ធផលជាច្រើនគួរឲ្យកត់សម្គាល់ ទាំងចំពោះសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ និងជាប្រធានដឹកនាំកិច្ចប្រជុំទេសាភិបាលធនាគារកណ្តាលអាស៊ាន (ACGM) លើកទី៨ បានទទួលជោគជ័យគួរជាទីមោទនៈ ។ លើសពីនេះ គណៈប្រតិភូជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំរួមលើកទី១ រវាងរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតំបន់ ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានធ្វើជាម្ចាស់ផ្ទះដឹកនាំកិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាលស៊ាសិន (SEACEN) លើកទី៣ និងសហការជាមួយមជ្ឈមណ្ឌលស៊ាសិន និងធនាគារកណ្តាលជាដៃគូក្នុងការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា ដើម្បីលើកកម្ពស់សមត្ថភាពជំនាញស្របតាមការវិវត្តរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់ និងអន្តរជាតិ ។

សរុបសេចក្តីមក សមិទ្ធផលដ៏ល្អប្រសើរដែលសម្រេចបាននេះ កើតឡើងដោយសារការខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់របស់មន្ត្រី-បុគ្គលិកគ្រប់ជាន់ថ្នាក់ និងការគាំទ្រយ៉ាងមុតមាំរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាពិសេសមានកិច្ចសហប្រតិបត្តិការល្អពីក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាផងដែរ ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ក្រុមប្រឹក្សាភិបាល មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា និងគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមវិភាគទានដ៏មានតម្លៃក្នុងការសម្រេចបាននូវជោគជ័យដ៏ល្អប្រសើរនេះ ។

ទេសាភិបាល

ជា ចាន់តូ

# មាតិកា

* * *

ក- របាយការណ៍ប្រចាំឆ្នាំ២០១២ ១

សេចក្តីផ្តើម ២

I- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ៣

១- ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល ៣

១.១- ការវិវត្តថ្លៃទំនិញ និងអតិផរណា ៣

១.២- ស្ថានភាពអត្រាប្តូរប្រាក់ ៥

១.២.១- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ៥

១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន ៦

១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណមួយចំនួន ៧

២- ការវិវត្តរូបិយវត្ថុ ៧

២.១- ការផ្គត់ផ្គង់រូបិយវត្ថុ ៧

២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ៨

២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ៩

២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារ ៩

២.៣- អត្រាការប្រាក់លើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ ១០

៣- ជញ្ជីងទូទាត់ ១១

៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ១១

៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ ១៣

៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ១៤

៤.១- ការដាក់វិនិយោគទុនបម្រុងអន្តរជាតិ ១៤

៤.២- អន្តរាគមន៍ទៅលើទីផ្សារប្តូរប្រាក់ ១៥

៤.៣- ការងារប្រតិវេទន៍ និងការងារគ្រប់គ្រងអាជីវកម្មនាំចេញ-នាំចូលមាស ១៥

៥- សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៥

៥.១- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៦

៥.១.១- ការត្រួតពិនិត្យលើឯកសារ ១៦

៥.១.២- ការត្រួតពិនិត្យដល់ទីកន្លែង ១៦

៥.១.៣- ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១៧

៥.២- ការងារនីតិកម្ម ១៨

៥.៣- ការងារវិភាគ តាមដាន និងការគ្រប់គ្រងទិន្នន័យ ១៨

៥.៤- ការងារផ្តល់អាជ្ញាប័ណ្ណ និងជម្រះបញ្ជី ១៨

៥.៥. ការងារត្រួតពិនិត្យការិយាល័យឥណទាន ១៩

៥.៦. ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ១៩

៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល ២០

៦.១- សេវាគ្រប់គ្រងគណនី ២០

៦.១.១- ស្ថាប័នរដ្ឋ ២០

៦.១.២- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២០

៦.២- សេវាផ្ទេរប្រាក់ក្នុងប្រទេស ២០

៦.៣- សេវាផាត់ទាត់មូលប្បទានបត្រ ២០

៦.៣.១- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល ២១

៦.៣.២- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក ២១

៦.៤- ការងារឥណទាន ២១

៦.៥- ការងារគ្រប់គ្រងមូលបត្រ ២១

៦.៥.១- ការងារគ្រប់គ្រងមូលបត្ររបស់រដ្ឋាភិបាល ២១

៦.៥.២- ការងាររៀបចំចេញផ្សាយវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបាន (NCD) ២១

៦.៦- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាលជប៉ុន ២២

៧- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ២៣

៨- ការអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិ ២៤

៩- ការងារព័ត៌មានវិទ្យា ២៤

II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ២៤

១- សកម្មភាពក្រុមប្រឹក្សាភិបាល ២៤

២- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ២៦

២.១- ស្ថិតិមន្ត្រីបុគ្គលិក ២៦

២.២- ការងារបណ្តុះបណ្តាល ២៦

៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ២៧

៣.១- ការងារសវនកម្មផ្ទៃក្នុង ២៧

៣.២- ការងារអធិការកិច្ច ២៧

៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ២៧

III- ទំនាក់ទំនងអន្តរជាតិ ២៨

១- ទំនាក់ទំនងពហុភាគី ២៨

១.១- មូលនិធិរូបិយវត្ថុអន្តរជាតិ ២៨

១.២- ធនាគារអភិវឌ្ឍន៍អាស៊ី ២៩

១.៣- អាស៊ាន និងអាស៊ាន+៣ ២៩

១.៤- មជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (ស៊ាសិន - SEACEN) ៣០

១.៥- សមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន - Francophone) ៣១

១.៦- សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA) ៣១

១.៧- ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់អាស៊ី (FSBR) ៣២

២- ទំនាក់ទំនងទ្វេភាគី ៣៣

សន្និដ្ឋាន ៣៥

ខ- ទិសដៅការងារឆ្នាំ២០១៣ ៣៧

១- ការងាររូបិយវត្ថុ ៣៨

២- ការជំរុញការប្រើប្រាស់ប្រាក់រៀល និងទីផ្សារអន្តរធនាគារ ៣៨

៣- ការងារវិនិយោគទុនបម្រុងអន្តរជាតិ ៣៨

៤- ការងារអភិវឌ្ឍន៍ប្រព័ន្ធផាត់ទាត់ជាតិ ៣៩

៥- ការងារត្រួតពិនិត្យ ៣៩

៦- ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ៣៩

៧- ការងារប្រតិបត្តិការ និងប្រព័ន្ធផាត់ទាត់ជាតិ ៣៩

៨- ការងារបោះផ្សាយ និងឃ្លាំងបេឡា ៤០

៩- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៤០

១០- ការងារគ្រប់គ្រងសាខា ៤០

១១- ការងារព័ត៌មានវិទ្យា ៤០

១២- ការងារបណ្តុះបណ្តាល ៤០

១៣- ការងារទំនាក់ទំនងអន្តរជាតិ ៤១

ឧបសម្ព័ន្ធ ៤២

ឧបសម្ព័ន្ធ ១ ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា ៤៣

ឧបសម្ព័ន្ធ ២ ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា (ធ្នូ ២០០៨ - ធ្នូ ២០១២) ៤៤

ឧបសម្ព័ន្ធ ៣ ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ) ៤៥

ឧបសម្ព័ន្ធ ៤ ស្ថានភាពរូបិយវត្ថុ (ឯកតា : ពាន់លានរៀល) ៤៦

ឧបសម្ព័ន្ធ ៥ តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា ៤៧

ឧបសម្ព័ន្ធ ៦ តារាងគណនីវិភាគធនាគារពាណិជ្ជ ៤៨

ឧបសម្ព័ន្ធ ៧ ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច ៤៩

ឧបសម្ព័ន្ធ ៨ ជញ្ជីងទូទាត់ប្រទេសកម្ពុជា (ឆ្នាំ២០០៩ ដល់ ឆ្នាំ២០១២) ៥០

# ក- របាយការណ៍ប្រចាំឆ្នាំ២០១២

## សេចក្ដីផ្ដើម

នៅឆ្នាំ២០១២ ទោះបីជាសេដ្ឋកិច្ចពិភពលោកស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជា និងមានហានិភ័យខ្ពស់ ដែលបង្កការគំរាមកំហែងដល់កំណើនសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចនៅតំបន់អាស៊ីក៏ដោយ ក៏ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចប្រទេសកម្ពុជាអាចរក្សាបានស្ថិរភាពល្អប្រសើរ ដោយសម្រេចបានកំណើន ៧% ធៀបនឹង ៧,១% នៅឆ្នាំ២០១១ និង ៦% នៅឆ្នាំ២០១០ ។ ជាមួយគ្នានោះ អត្រាអតិផរណាឆ្នាំលើឆ្នាំបានធ្លាក់ចុះដល់ប្រមាណ ៣% ធៀបនឹង ៤,៩% នៅឆ្នាំ២០១១ ។ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំមានស្ថិរភាពល្អ ដោយអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកអាចរក្សាបានក្នុងរង្វង់ ៤.០១០ រៀល ។ សមិទ្ធផលទាំងនេះឆ្លុះបញ្ចាំងពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលានូវគោលនយោបាយរូបិយវត្ថុនិងសារពើពន្ធ រួមជាមួយកម្មវិធីកំណែទម្រង់និងវិធានការនានារបស់រាជរដ្ឋាភិបាល ។

ទន្ទឹមនេះ ប្រព័ន្ធធនាគារក៏រក្សាបាននូវស្ថិរភាពល្អប្រសើរ និងមានការអភិវឌ្ឍជាលំដាប់ ទាំងវិសាលភាព និងទំហំប្រតិបត្តិការ ។ ជាក់ស្តែង ភាពស៊ីជម្រៅខាងផ្នែកហិរញ្ញវត្ថុ[៣] និងអន្តរការិយកម្មហិរញ្ញវត្ថុមានការរីកចម្រើន បណ្តាញសាខាក៏ត្រូវបានពង្រីកនៅទូទាំងប្រទេស ហើយសេវាហិរញ្ញវត្ថុថ្មីៗត្រូវបានដាក់ឲ្យប្រើប្រាស់បន្ថែមទៀត ដើម្បីបម្រើផលប្រយោជន៍ដល់សាធារណជននិងវិនិយោគិន ។ ស្របពេលនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុជាបន្តបន្ទាប់ ធនាគារជាតិនៃកម្ពុជាក៏បានបន្តលើកកម្ពស់ការត្រួតពិនិត្យ និងការរៀបចំក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនានា ក្នុងគោលដៅជំរុញប្រតិបត្តិការធនាគារឲ្យប្រព្រឹត្តទៅកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាព ។ ក្រៅពីនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ត្រូវបានធ្វើបច្ចុប្បន្នកម្ម ហើយបានដាក់ឲ្យប្រើប្រាស់ជាឯកសារតម្រង់ទិសក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ស្របតាមនិន្នាការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចជាតិ និងតំបន់ ។

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានបន្តផ្តោតការយកចិត្តទុកដាក់ក្នុងការពង្រឹងនិងពង្រីកទំនាក់ទំនងជាមួយនឹងធនាគារកណ្តាលនៃប្រទេសជាដៃគូស្ថាប័នហិរញ្ញវត្ថុក្នុងតំបន់ និងអន្តរជាតិ សំដៅអភិវឌ្ឍវិស័យធនាគារឲ្យកាន់តែរីកចម្រើនរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុតំបន់ ព្រមទាំងលើកកម្ពស់កិត្យានុភាពរបស់ធនាគារជាតិនៃកម្ពុជាលើឆាកអន្តរជាតិ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមជំរុញគំនិតផ្តួចផ្តើមនានាក្នុងតំបន់ និងទទួលបានផលប្រយោជន៍ជាច្រើនតាមរយៈជំនួយបច្ចេកទេស និងកិច្ចសហប្រតិបត្តិការទាំងនេះ ។

---

[៣] Financial deepening = M2/GDP

## I-ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

### ១-ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល

#### ១.១-ការវិវត្តថ្លៃទំនិញ និងអតិផរណា

បើធៀបនឹងឆ្នាំកន្លងទៅ អត្រាអតិផរណានៅឆ្នាំ២០១២ នេះ បានថយចុះគួរឲ្យកត់សម្គាល់ ។ ការថយចុះនេះបណ្តាលមកពីការធ្លាក់ចុះនៃអត្រាអតិផរណានៅបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗ កំណើនទាបនៃថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ គួបផ្សំនឹងកំណើនផលិតកម្មក្នុងស្រុក ។ ទន្ទឹមនេះ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងការផ្គត់ផ្គង់រូបិយវត្ថុសមស្រប ក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាកម្រិតថ្លៃឲ្យនៅទាបផងដែរ ។ ជាក់ស្តែង អត្រាអតិផរណាឆ្នាំលើឆ្នាំមានកម្រិតទាបសមរម្យត្រឹម ២,៥% ធៀបនឹង ៤,៩% និង ៣,១% នៅឆ្នាំ២០១១ និងឆ្នាំ២០១០ រៀងគ្នា ។

ក្រាហ្វ ១ : **អតិផរណាឆ្នាំលើឆ្នាំ**



ចលនាថយចុះនៃអត្រាអតិផរណាឆ្នាំលើឆ្នាំឆ្លុះបញ្ចាំងដោយការថយចុះនៃសន្ទស្សន៍ថ្លៃទំនិញក្រុមមួយចំនួន ខណៈក្រុមខ្លះទៀតមានការកើនឡើងក្នុងកម្រិតទាបជាងឆ្នាំមុន ជាពិសេស ម្ហូបអាហារនិងភេសជ្ជៈដែលកើនតែ ២,៤% និងការដឹកជញ្ជូនតែ ០,៩% ប៉ុណ្ណោះ ធៀបនឹងឆ្នាំមុនដែលមានកំណើន ៦,២% និង ៦,៣% រៀងគ្នា ។

ក្រាហ្វ ២ : **ក្រុមមុខទំនិញដែលឡើងថ្លៃខ្លាំងជាងគេក្នុងឆមាសទី១ ឆ្នាំ២០១២** (ឆ្នាំលើឆ្នាំ)



ការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមម្ហូបអាហារដែលជាក្រុមមានមេគុណខ្ពស់ជាងគេបំផុតនោះ ជាចម្បងបណ្តាលមកពីការឡើងថ្លៃសាច់គោ ១៦,៣% ធញ្ញជាតិផ្សេងៗ ១១,៤% ត្រី ៦,៧% សាច់ទា ៦% ផ្លែឈើ ៥,៧% បន្លែ ៤,២% និងអង្ករ ១,៥% ។ ដោយឡែក ការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមការដឹកជញ្ជូន គឺជាលទ្ធផលនៃការឡើងថ្លៃសេវាកម្មដឹកជញ្ជូន ៥,៣% ប្រេងម៉ាស៊ូត ៤,៧% ប្រេងសាំង ៣,៨% និង ប្រេងម៉ាស៊ីន ២,៤% ។




ដូច្នេះ ក្រុមទំនិញដែលបានរួមចំណែកក្នុងអតិផរណារួម រួមមាន ក្រុមម្ហូបអាហារនិងភេសជ្ជៈពុំមានជាតិស្រវឹង ១,១% ក្រុមផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត ០,៦% ក្រុមភោជនីយដ្ឋាន ០,៣% ក្រុមសម្លៀកបំពាក់និងស្បែកជើង ០,១% ក្រុមការដឹកជញ្ជូន ០,១% និង ៧ក្រុមទៀតដែលនៅសល់បានចូលរួមចំណែកតែ ០,២% ប៉ុណ្ណោះ ។



ខណៈដែលអតិផរណារួមមានកម្រិត ២,៥% អត្រាអតិផរណាស្នូល (មិនរាប់បញ្ចូលក្រុមម្ហូបអាហារ និងក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ) មានកម្រិត ២% ។

## ១.២-ស្ថានភាពអត្រាប្តូរប្រាក់

### *១.២.១-ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក*

ដោយបានបន្តអនុវត្តគោលនយោបាយអត្រាប្តូរប្រាក់យ៉ាងប្រុងប្រយ័ត្ន ក្រោមរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាពល្អប្រសើរ ។ ជាក់ស្តែង ផ្អែកលើអត្រាមធ្យមប្រចាំឆ្នាំ អត្រាប្តូរប្រាក់បានធ្លាក់ចុះពី ៤.០៦៤ រៀល នៅឆ្នាំ២០១១ ដល់ ៤.០៤០ រៀល នាឆ្នាំ២០១២ ពោលគឺប្រាក់រៀលបានឡើងថ្លៃ ០,៦% ។ បើគិតតាមអត្រាប្តូរប្រាក់ទីផ្សារចុងគ្រា ប្រាក់រៀលបានឡើងថ្លៃ ១,៧% ដោយអត្រាប្តូរបានប្រែប្រួលពី ៤.០៥៧ រៀល ក្នុងមួយដុល្លារអាមេរិក នៅឆ្នាំ២០១១ មក ៣.៩៩០ រៀល នៅឆ្នាំ២០១២ ។

ការឡើងថ្លៃនៃប្រាក់រៀល ជាចម្បងបណ្តាលមកពីកំណើនតម្រូវការប្រាក់រៀលសម្រាប់បម្រើសកម្មភាពសេដ្ឋកិច្ចដែលមានការរីកចម្រើនជាលំដាប់ ។ ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការប្រាក់រៀលក្នុងសេដ្ឋកិច្ច និងរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជាបានបន្ថយសម្ពាធកំណើនតម្លៃប្រាក់រៀល តាមរយៈការលក់ប្រាក់រៀលទៅទីផ្សារចំនួន ២៧លើក ដែលមានទឹកប្រាក់សរុប ៤៩២,២ ពាន់លានរៀល ។

ក្រាហ្វ ៥: **ការវិវត្តន៍នៃអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក**
**(អត្រាទិញទីផ្សារចុងគ្រា)**



## តារាង ១: អត្រាប្តូរប្រាក់ប្រចាំខែ (ចុងខែ)

| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
|---|---|---|---|---|---|---|
| | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម |
| ធ្នូ-១១ | ៤.០៥៧ | ៤.០៦៦ | ៤.០៦២ | ៤.០៣៩ | ៤.០៣៩ | ៤.០៣៩ |
| មករា-១២ | ៤.០៧៣ | ៤.០៨២ | ៤.០៧៨ | ៤.០៦៤ | ៤.០៦៤ | ៤.០៦៤ |
| កុម្ភៈ-១២ | ៤.០១៣ | ៤.០១៨ | ៤.០១៦ | ៤.០១៥ | ៤.០១៥ | ៤.០១៥ |
| មិនា-១២ | ៣.៩៩៥ | ៤.០០៥ | ៤.០០០ | ៣.៩៩៥ | ៣.៩៩៥ | ៣.៩៩៥ |
| មេសា-១២ | ៤.០៤២ | ៤.០៥៦ | ៤.០៤៩ | ៤.០២៥ | ៤.០២៥ | ៤.០២៥ |
| ឧសភា-១២ | ៤.០៩៥ | ៤.១០៥ | ៤.១០០ | ៤.០៦៥ | ៤.០៦៥ | ៤.០៦៥ |
| មិថុនា-១២ | ៤.១០០ | ៤.១០៩ | ៤.១០៥ | ៤.០៦៥ | ៤.០៦៥ | ៤.០៦៥ |
| កក្កដា-១២ | ៤.០៧៧ | ៤.០៨៤ | ៤.០៨១ | ៤.០៧០ | ៤.០៧០ | ៤.០៧០ |
| សីហា-១២ | ៤.០៥៣ | ៤.០៦៣ | ៤.០៥៨ | ៤.០៤៥ | ៤.០៤៥ | ៤.០៤៥ |
| កញ្ញា-១២ | ៤.០៥៥ | ៤.០៦២ | ៤.០៥៩ | ៤.០៤៣ | ៤.០៤៣ | ៤.០៤៣ |
| តុលា-១២ | ៤.០២៥ | ៤.០៣៣ | ៤.០២៩ | ៤.០៣០ | ៤.០៣០ | ៤.០៣០ |
| វិច្ឆិកា-១២ | ៣.៩៩៥ | ៤.០០៣ | ៣.៨៩៩៩ | ៣.៩៩២ | ៣.៩៩២ | ៣.៩៩២ |
| ធ្នូ-១២ | ៣.៩៩០ | ៣.៩៩៥ | ៣.៩៩៣ | ៣.៩៩៥ | ៣.៩៩៥ | ៣.៩៩៥០ |

### *១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន*

ផ្អែកលើអត្រាប្តូរប្រាក់ខ្វែងរវាងប្រាក់រៀលជាមួយរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ប្រាក់រៀលបានចុះថ្លៃធៀបនឹងប្រាក់ដុល្លារសិង្ហបុរី ៦% ប្រាក់ប៉េសូហ្វីលីពីន ៤,៧% ប្រាក់ដុល្លារតៃវ៉ាន់ ៣,៨% ប្រាក់វ៉ុនកូរ៉េ ៣,៤% ប្រាក់រីងហ្គីតម៉ាឡេស៊ី ៣,២% ប្រាក់បាតថៃ ៣,២% ប្រាក់ដុល្លារអូស្ត្រាលី ២,៩% ប្រាក់ដុងវៀតណាម ០,៥% ប្រាក់យ៉ន់ចិន ០,៣% និងប្រាក់យ៉េនជប៉ុន ០,១៣% ។ ផ្ទុយទៅវិញ ប្រាក់រៀលបានឡើងថ្លៃធៀបនឹងប្រាក់រូពីឥណ្ឌូនេស៊ី ៥,៤% និងប្រាក់អឺរ៉ូ ០,២% ។

ក្រាហ្វ៦: **ការវិវត្តនៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន**

(សន្ទស្សន៍:ចុងខែ ធ្នូ ២០១១ = ១០០)



### ១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណមួយចំនួន

បើធៀបជាមួយរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ប្រាក់ដុល្លារអាមេរិកបានចុះថ្លៃធៀបនឹងប្រាក់ដុល្លារសិង្ហបុរី ៥,៦% ប្រាក់ប៉េសូហ្វីលីពីន ៤,៦% ប្រាក់ដុល្លារតៃវ៉ាន់ ៣,៣% ប្រាក់វ៉ុនកូរ៉េ ៣,៣% ប្រាក់រីងហ្គីតម៉ាឡេស៊ី ៣,១% ប្រាក់ដុល្លារអូស្ត្រាលី ២,៨% ប្រាក់បាតថៃ ២,៨% ប្រាក់ដុងវៀតណាម ០,៧% ប្រាក់យ៉ន់ចិន ០,៣% និងប្រាក់យ៉េនជប៉ុន ០,០៤% ។ ទន្ទឹមនឹងនោះដែរ ប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃធៀបនឹងប្រាក់រូពីឥណ្ឌូនេស៊ី ៥,៩% និងប្រាក់អឺរ៉ូ ០,៣% ។




## ២- ការវិវត្តរូបិយវត្ថុ

ស្របតាមការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច រូបិយវត្ថុទូទៅ (M2) និងបរិមាណឥណទានចំពោះវិស័យឯកជន បានបន្តកើនឡើងគួរឲ្យកត់សម្គាល់ ។ ទន្ទឹមនេះ ទ្រព្យសកម្មបរទេសសុទ្ធ និងដើមទុនរបស់ប្រព័ន្ធធនាគារនៅតែបន្តរក្សាកំណើនល្អប្រសើរ ដែលជួយជំរុញកំណើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។ ម្យ៉ាងវិញទៀត ភាពប្រកួតប្រជែងនៃវិស័យធនាគារបានកើនឡើង ដែលឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃគម្លាតអត្រាការប្រាក់ធៀបនឹងឆ្នាំកន្លងទៅ ។

### ២.១- ការផ្គត់ផ្គង់រូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) បានកើនដល់ ២៨.៥៩២ ពាន់លានរៀល (៤៧% នៃផ.ស.ស) ពោលគឺកើន ២០,៩% ។ កំណើននេះ បានមកពីការកើនឡើងនៃប្រាក់បញ្ញើជារូបិយប័ណ្ណ ៤.៦២៥ ពាន់លានរៀល (២៤,២%) ប្រាក់បញ្ញើជារៀល ៣២៨ ពាន់លានរៀល (៤៤,៣%) ខណៈដែលរូបិយវត្ថុក្នុងចរាចរណ៍ថយចុះ ១៦ ពាន់លានរៀល (០,៤%) ។

ក្រាហ្វ ៨ : **សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ**




**តារាង ២ : បម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗនិងសន្ទស្សន៍ថ្លៃទំនិញនិងសេវា**

(បម្រែបម្រួលឆ្នាំលើឆ្នាំជាភាគរយ)

| | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|---|
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | -៩០,៥ | -៦៤,៥ | ២៤,៦ | ៥,៦ | ០,២ | -១៧,១ |
| **ឥណទានផ្នែកឯកជន** | ៧៦,០ | ៥៥,០ | ៦,៥ | ២៦,៦ | ៣១,៧ | ៣៤,១ |
| **រូបិយវត្ថុទូទៅ (M2)** | ៦២,៩ | ៤,៨ | ៣៦,៨ | ២០,០ | ២១,៥ | ២០,៩ |
| **រូបិយវត្ថុក្នុងចរាចរណ៍** | ២៤,៤ | ១៥,៣ | ៣០,៨ | ៣,២ | ២១,៧ | -០,៤ |
| **អតិផរណាប្រចាំឆ្នាំ** | ១៤,០ | ១២,៣ | ៥,៣ | ៣,១ | ៤,៩ | ២,៤ |

### ២.២- ភត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ការកើនឡើងនៃរូបិយវត្ថុទូទៅ នៅឆ្នាំ២០១២ នេះ បណ្ដាលមកពីកំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារ ២៦១ ពាន់លានរៀល និងកំណើនទ្រព្យសកម្មក្នុងស្រុកសុទ្ធ ៤.៦៧៧ ពាន់លានរៀល ។ កំណើននៃទ្រព្យសកម្មបរទេសសុទ្ធនេះ គឺដោយសារការកើនឡើងនៃទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាចំនួន ២.៥៧៣ ពាន់លានរៀល ខណៈដែលទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារថយចុះ ២.៣១២ ពាន់លានរៀល ។ ចំណែកឯការកើនឡើងនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធវិញ គឺបណ្ដាលមកពីការកើនឡើងនៃឥណទានចំពោះវិស័យឯកជន ៥.៩៨៤ ពាន់លានរៀល (៣៤,១%) ដើមទុននិងទុនបម្រុងរបស់ប្រព័ន្ធធនាគារកើនឡើង ១.៧៨៨ ពាន់លានរៀល (១៨,៤%) ខណៈដែលឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលថយចុះ ៣៦៣ ពាន់លានរៀល (១៧,១%) ។ នៅក្នុងលំហូរឥណទានចំពោះវិស័យឯកជនសរុប វិស័យដែលទទួលបានឥណទានច្រើនជាងគេរួមមាន វិស័យជួញដូរដុំនិងរាយ ៣៥% សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត ១២% កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ១២% សំណង់និងការជួញដូរ អចលនទ្រព្យ ១១% និង កម្មន្តសាល ១០% ។




### ២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាបានថយចុះចំនួន ៤៧៧ ពាន់លានរៀល (៩,៦%) មកត្រឹម -៥.៤៥៣ ពាន់លានរៀល នៅឆ្នាំ២០១២ ។ ការថយចុះនេះ បណ្តាលមកពីការថយចុះនៃឥណទេយ្យសុទ្ធពីគ្រឹះស្ថានធនាគារ ៧០ ពាន់លានរៀល (១២,១%) និងឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល ៣៤៥ ពាន់លានរៀល (១៩,៤%) ខណៈដែលខ្ទង់ផ្សេងៗសុទ្ធកើនឡើង ៥៩ ពាន់លានរៀល (១០,២%) ។ ការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល ជារួមបណ្តាលមកពីកំណើននៃប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ។

ចំណែកឯទ្រព្យសកម្មបរទេសសុទ្ធវិញមានចំនួន ១៨.៥៨៣ ពាន់លានរៀល (៣១% នៃផ.ស.ស) ពោលគឺបានកើន ២.៥៧៣ ពាន់លានរៀល (១៦,១%) ធៀបនឹងឆ្នាំ២០១១ ។ ជារួម កំណើននេះបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេស ដែលក្នុងនោះមានជាង ៦០% ជាប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនៅធនាគារជាតិនៃកម្ពុជា ។

### ២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារ

ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារមានចំនួន ៤៤.៣៧១ ពាន់លានរៀល (៧០% នៃផ.ស.ស) ពោលគឺកើន ១២.១៥៥ ពាន់លានរៀល (៣៧,៧%) ដែលជួយទ្រទ្រង់ដល់ការផ្តល់ឥណទានរបស់ធនាគារសម្រាប់សកម្មភាពសេដ្ឋកិច្ច ។ កំណើននេះ ឆ្លុះបញ្ចាំងមួយផ្នែកតាមរយៈដើមទុនរបស់គ្រឹះស្ថានធនាគារដែលបើកថ្មី ការបង្កើនដើមទុនរបស់ធនាគារដែលមានស្រាប់ និងការកើនឡើងប្រាក់បញ្ញើរបស់អតិថិជន ។ ប្រាក់បញ្ញើសរុបរបស់និវាសជនមានចំនួន២៤.៧៤៤ពាន់លានរៀល (៤០% នៃផ.ស.ស) កើនឡើង ២៤,៨% ដែលក្នុងនោះ មានជាង ៩០% ជាប្រាក់បញ្ញើជារូបិយប័ណ្ណ ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ៤.៧៧៨ ពាន់លានរៀល (៤៤,៦%) ។ ការប្រែប្រួលនេះ ជាចម្បងបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះវិស័យឯកជន ។ ឥណទានចំពោះវិស័យឯកជនបានកើនឡើង ៣៦% នៃផ.ស.ស ធៀបនឹងឆ្នាំកន្លងទៅដែលមាន ២៩% នៃផ.ស.ស ។ ការថយចុះនៃខ្ទង់ផ្សេងៗសុទ្ធជាលទ្ធផលពីការកើនឡើងនៃដើមទុន ១.៦៩៤ ពាន់លានរៀល (២៦,៣%) និងបំណុលអន្តរធនាគារ ១.៣៦៩ ពាន់លានរៀល ខណៈដែលទ្រព្យសកម្មផ្សេងៗកើនឡើង ២.២៨៩ ពាន់លានរៀល (៧០,៣%) ។ ទន្ទឹមនឹងនេះដែរ ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនៅធនាគារជាតិនៃកម្ពុជា ដែលមួយផ្នែកជាធាតុផ្សំរបស់ទុនបម្រុងអន្តរជាតិបានកើនឡើង ២.៣៩៧ ពាន់លានរៀល (៣៤,០%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារបានថយចុះចំនួន ២.៣១២ ពាន់លានរៀល គឺពី ១.៨៨៤ ពាន់លានរៀល នាឆ្នាំ២០១១ មកត្រឹម -៤២៨ ពាន់លានរៀល នាឆ្នាំ២០១២ ។ ការថយចុះនេះបណ្តាលមកពីកំណើនទ្រព្យអកម្មបរទេស ៣.៧៤០ ពាន់លានរៀល ខ្ពស់ជាងកំណើនទ្រព្យសកម្មបរទេសដែលមាន ១.៤២៨ ពាន់លានរៀល ។ នៅក្នុងកំណើននៃទ្រព្យអកម្មបរទេសសរុបមាន ៦៤% ខ្ចីពីធនាគារខាងក្រៅ ២៥% ជាប្រាក់បញ្ញើរបស់អនិវាសជន និង ១២% ជាប្រាក់បញ្ញើដែលធនាគារបរទេសដាក់នៅធនាគារក្នុងស្រុក ។

### ២.៣- អត្រាការប្រាក់លើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ

តាមការពិនិត្យលើបម្រែបម្រួលអត្រាការប្រាក់កម្ចីនិងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ អត្រាការប្រាក់រយៈពេល ៦ខែ វាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារ មាននិន្នាការថយចុះទាំងអត្រាការប្រាក់បញ្ញើ និងកម្ចី ។ អត្រាការប្រាក់បញ្ញើមានការថយចុះបន្តិច ដោយអត្រាការប្រាក់បញ្ញើជារៀលបានថយចុះពី ៥,២៨% ឆ្នាំ២០១១ មក ៤,៩៧% ឆ្នាំ២០១២ និងអត្រាការប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិកបានរក្សានៅកម្រិត ៣,៤៣% ដដែល ។ អត្រាការប្រាក់កម្ចីបានថយចុះខ្លាំងពី ១៦,៩៩% ឆ្នាំ២០១១ មកត្រឹម ១១,៣១% ឆ្នាំ២០១២ ចំពោះប្រាក់កម្ចីជារៀល និងពី ១៦,៣៨% មក ១១,៨៦% ចំពោះកម្ចីជាប្រាក់ដុល្លារអាមេរិក ។

ក្រាហ្វ ១០: អត្រាការប្រាក់កម្ចី និងប្រាក់បញ្ញើ
(អត្រាមធ្យម ៦ ខែ)



បម្រែបម្រួលនៃអត្រាការប្រាក់បានធ្វើឲ្យគម្លាតអត្រាការប្រាក់ជារៀលថយមកត្រឹម ៦,៣៨% ធៀបនឹង ១១,៧១% នៅឆ្នាំ២០១១ ។ ចំណែកឯគម្លាតអត្រាការប្រាក់ជាដុល្លារអាមេរិកបានថយចុះមក ៨,៤៣% ពី ១២,៩៥% នៅឆ្នាំ២០១១ ។ នេះសរឲ្យឃើញពីការកើនឡើងនៃភាពប្រកួតប្រជែងរបស់ប្រព័ន្ធធនាគារ និងការរីកចម្រើននៃអន្តរការិយកម្មធនាគារនៅកម្ពុជា ។

**តារាង ៣ : អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ (អត្រាមធ្យម៦ខែ - ជាភាគរយ)**

(អត្រាមធ្យម៦ខែ - ជាភាគរយ)

| | ធ្នូ ២០១១ | មករា ២០១២ | កុម្ភៈ ២០១២ | មីនា ២០១២ | មេសា ២០១២ | ឧសភា ២០១២ | មិថុនា ២០១២ | កក្កដា ២០១២ | សីហា ២០១២ | កញ្ញា ២០១២ | តុលា ២០១២ | វិច្ឆិកា ២០១២ | ធ្នូ ២០១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អត្រាការប្រាក់បញ្ញើជារៀល | ៥,២៨ | ៥,២៩ | ៥,២៣ | ៥,០៣ | ៥,០៩ | ៥,០៧ | ៤,៨៥ | ៤,៩៧ | ៤,៩៧ | ៤,៩៤ | ៤,៩០ | ៤,៩១ | ៤,៩១ |
| អត្រាការប្រាក់កម្ចីជារៀល | ១៦,៩៩ | ១៦,៩៦ | ១៧,៦៧ | ១៧,៦៧ | ១៣,២៥ | ១១,៦៧ | ១១,៧៣ | ១១,៧៥ | ១១,៣១ | ១១,៣០ | ១១,៣១ | ១១,២៩ | ១១,២៨ |
| គម្លាត | ១១,៧១ | ១១,៦៧ | ១២,៤៤ | ១២,៦៤ | ៨,១៦ | ៦,៦០ | ៦,៨៨ | ៦,៨៨ | ៦,៣៤ | ៦,៣៦ | ៦,៤១ | ៦,៣៨ | ៦,៣៨ |
| | | | | | | | | | | | | | |
| អត្រាការប្រាក់បញ្ញើជាដុល្លារ | ៣,៤៣ | ៣,៤៣ | ៣,៤២ | ៣,៤២ | ៣,៤៣ | ៣,៤៣ | ៣,៤១ | ៣,៤៣ | ៣,៤៣ | ៣,៤៣ | ៣,៤១ | ៣,៤២ | ៣,៤៣ |
| អត្រាការប្រាក់កម្ចីជាដុល្លារ | ១៦,៣៨ | ១៣,៨៦ | ១៤,០០ | ១៤,០៦ | ១២,៦៤ | ១១,៩៨ | ១២,១៣ | ១២,១៨ | ១១,៨៦ | ១១,៨៩ | ១១,៨៥ | ១១,៨៥ | ១១,៨៤ |
| គម្លាត | ១២,៩៥ | ១០,៤០ | ១០,៥៨ | ១០,៦៤ | ៩,២១ | ៨,៥៥ | ៨,៧២ | ៨,៧២ | ៨,៤៣ | ៨,៤២ | ៨,៤៤ | ៨,៤៣ | ៨,៤១ |

## ៣- ជញ្ជីងទូទាត់

ទោះបីការដោះស្រាយវិបត្តិបំណុលនៅតំបន់អឺរ៉ុបមិនទាន់បានទទួលលទ្ធផលជាវិជ្ជមានក៏ដោយ ក៏បណ្តាប្រទេសអាស៊ីអាគ្នេយ៍ (ភាគច្រើននៃប្រទេសអាស៊ាន) នៅតែបន្តមានកំណើនគួរឲ្យកត់សម្គាល់ ស្របពេលដែលសហរដ្ឋអាមេរិកមានកំណើនបន្តិចបន្តួចក្នុងឆ្នាំ២០១២ នេះ។ទន្ទឹមនេះ ស្ថានភាពប្រសើរគួរឲ្យកត់សម្គាល់នោះគឺតម្រូវការនៃផ្នែកឯកជនរបស់ប្រទេសអភិវឌ្ឍន៍មិនមានការថយចុះទេដែលជាកត្តាធ្វើឲ្យប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជារក្សាភាពល្អប្រសើរ ។ ការប៉ាន់ស្មានដំបូងបានបង្ហាញឲ្យឃើញថា សមតុល្យរួមមានអតិរេកចំនួន ៣២២ លានដុល្លារអាមេរិក (២,៣% នៃផ.ស.ស) បានកើនឡើង ៤% ធៀបនឹងអតិរេកឆ្នាំ២០១១ បន្ទាប់ពីបានផាត់ទាត់ឲ្យកំណើនឱនភាពគណនីចរន្ត ១៧% ។

### ៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ)

សមតុល្យគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) មានឱនភាពប្រមាណ ១.៣១៦ លានដុល្លារអាមេរិក (៩% នៃផ.ស.ស) និងបានកើនឡើង ១៩៤ លានដុល្លារអាមេរិក (១៧%) ធៀបនឹងឆ្នាំ២០១១ ។ ការកើនឡើងនៃឱនភាពគណនីទំនិញប្រមាណ ១៧% និងឱនភាពគណនីប្រាក់ចំណូលសុទ្ធប្រមាណ ១៥% ជាមូលហេតុចម្បងដែលបណ្តាលឲ្យមានកំណើនឱនភាពគណនីចរន្ត ។ ឱនភាពគណនីចរន្តនេះ ត្រូវបានផាត់ទាត់ដោយកំណើនអតិរេកគណនីសេវាសុទ្ធចំនួន ២១% ។

ក្រាហ្វ ១១: **ជញ្ជីងពាណិជ្ជកម្ម** (ឆ្នាំ ១៩៩៨ - ២០១២)




ការនាំចេញផលិតផលក្នុងស្រុកត្រូវបានប៉ាន់ស្មានថាមានតម្លៃ ៥.៥០៤ លានដុល្លារអាមេរិក បានកើនឡើងប្រមាណ ៥៧៧ លានដុល្លារអាមេរិក (១២%) ធៀបនឹងឆ្នាំ២០១១ ។ ការកើនឡើងនៃការនាំចេញសម្លៀកបំពាក់ និងវាយនភ័ណ្ឌដែលមានសមាមាត្រប្រមាណ ៧៧% នៃការនាំចេញសរុបជាកត្តាជំរុញឲ្យមានកំណើនការនាំចេញផលិតផលក្នុងស្រុកនេះ ។ ការនាំចេញសម្លៀកបំពាក់ និងវាយនភ័ណ្ឌមានចំនួនប្រមាណ ៤.២៥៩ លានដុល្លារអាមេរិក បានកើនឡើង ៣៥៧ លានដុល្លារអាមេរិក (៩%) ធៀបនឹងឆ្នាំ២០១១ ។

ការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកមានតម្លៃប្រមាណ ៧.៣២០ លានដុល្លារអាមេរិក បានកើនឡើង ៨៣១ លានដុល្លារអាមេរិក (១៣%) ធៀបនឹងឆ្នាំ២០១១ ។ ការកើនឡើងនៃការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ប្រមាណ ៣៣៦ លានដុល្លារអាមេរិក ជាកត្តាសំខាន់ធ្វើឲ្យមានកំណើននៃការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកនេះ ។ ការនាំចូលប្រេងឥន្ធនៈបានកើនឡើងប្រមាណ ១៦៥ លានដុល្លារអាមេរិក (១៧%) ស្របពេលដែលការនាំចូលអគ្គិសនីបានកើនឡើង ២០,៦ លានដុល្លារអាមេរិក (១៦%) ធៀបនឹងឆ្នាំ២០១១ ។

គណនីសេវាសុទ្ធត្រូវបានប៉ាន់ស្មានថា មានអតិរេកចំនួន ១.០៧៣ លានដុល្លារអាមេរិក កើនឡើង ១៨៤ លានដុល្លារអាមេរិក (២១%) ធៀបនឹងឆ្នាំ២០១១ ។ ការកើនឡើងនៃអតិរេកនេះ បណ្តាលមកពីប្រាក់ចំណូលពីសេវាកើនឡើង ៤៨៣ លានដុល្លារអាមេរិក (២២%) ខណៈដែលចំណាយទូទាត់សេវាទៅឲ្យអនិវាសជនកើនឡើង ៣០០ លានដុល្លារអាមេរិក (២៣%) ។ ចំណូលពីសេវាទេសចរណ៍ត្រូវបានប៉ាន់ស្មានថាមានចំនួន ២.០០០ លានដុល្លារអាមេរិក កើនឡើង ៣៨៣ លានដុល្លារអាមេរិក (២៤%) ដែលបានរួមចំណែកយ៉ាងខ្លាំងដល់កំណើនប្រាក់ចំណូលពីសេវា ។

គណនីប្រាក់ចំណូលសុទ្ធមានឱនភាពប្រមាណ ៨០០ លានដុល្លារអាមេរិក បានកើនឡើង ១០៥ លានដុល្លារអាមេរិក (១៥%) ធៀបនឹងឆ្នាំ២០១១ ។ ការកើនឡើងការផ្ទេរចេញប្រាក់ចំណូលពីការវិនិយោគនៅប្រទេសកម្ពុជា ជាកត្តាចម្បងបណ្តាលឲ្យមានកំណើនឱនភាពប្រាក់ចំណូលសុទ្ធក្នុងឆ្នាំ២០១២ នេះ ។ ទន្ទឹមនេះ

អតិរេកនៃគណនីបង្វែរឯកជនសុទ្ធត្រូវបានប៉ាន់ស្មានថា បានថយចុះ ២១ លានដុល្លារអាមេរិក (១២%) ។

### ៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ

គណនីបង្វែរផ្លូវការសុទ្ធដែលបង្ហាញពីប្រតិបត្តិការចំណូលក្រោមរូបភាពជាហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណង បានថយចុះប្រមាណ ២២ លានដុល្លារអាមេរិក (៣,៥%) ធៀបនឹងឆ្នាំ ២០១១ ។ គណនីហិរញ្ញវត្ថុមានលំហូរចូលសុទ្ធប្រមាណ ១.០៧១ លានដុល្លារអាមេរិក បានកើនឡើង ២៤៦ លានដុល្លារអាមេរិក (៣០%) ដោយសារមានកំណើនលំហូរចូលវិនិយោគផ្ទាល់បរទេសសុទ្ធប្រមាណ ៣៨៤ លានដុល្លារអាមេរិក (៣៩%) ខណៈដែលប្រាក់កម្ចីផ្លូវការសុទ្ធបានថយចុះប្រមាណ ៨៨ លានដុល្លារអាមេរិក (៤០%) ។

ក្រាហ្វ១២: **ជញ្ជីងទូទាត់កម្ពុជា** (ឆ្នាំ ១៩៩៨ - ២០១២)




លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធមានចំនួន ១.២១៦ លានដុល្លារអាមេរិក បានកើនឡើង ៣៨៤ លានដុល្លារអាមេរិក (៣៩%) ធៀបនឹងលំហូរចូលនៅឆ្នាំ២០១១ ។ ការកើនឡើងនេះ បណ្តាលមកពីមានកំណើនលំហូរចូលនៃដើមទុនវិនិយោគបរទេសរបស់វិស័យធនាគារ ៥៥% និងលំហូរចូលនៃដើមទុនវិនិយោគបរទេសរបស់វិស័យមិនមែនធនាគារ ៣៣% ដែលក្នុងនោះ លំហូរចូលវិនិយោគបរទេសផ្នែកកាត់ដេរសម្លៀកបំពាក់និងស្បែកជើង កសិឧស្សាហកម្ម និងរមណីយដ្ឋាន បានកើនឡើងគួរឲ្យកត់សម្គាល់ ។

ក្រាហ្វ១៣: **លំហូរវិនិយោគបរទេស** (ឆ្នាំ ១៩៩៨ - ២០១២)




ការកើនឡើងលំហូរចូលនៃគណនីហិរញ្ញវត្ថុ អាចទ្រទ្រង់ឲ្យការផាត់ទាត់នៃការកើនឡើងឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) និងបានធ្វើឲ្យប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាមានអតិរេកចំនួន ៣២២ លានដុល្លារអាមេរិក ។ អតិរេកនេះ បានបង្ហាញពីកំណើនទ្រព្យសកម្មជាទុនបម្រុងអន្តរជាតិដែលមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ទូទាត់ឲ្យការនាំចូលទំនិញ និងសេវាបាន ៤,៥ ខែ ។

## ៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤.១- ការងារវិនិយោគទុនបម្រុងអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាវិនិយោគទុនបម្រុងអន្តរជាតិក្រោមរូបភាពអូវើណាយ ប័ណ្ណរតនាគារអាមេរិក ឧបករណ៍ហិរញ្ញវត្ថុរយៈកាលមធ្យម (MTI) សញ្ញាប័ណ្ណរយៈពេលវែង និងប្រាក់បញ្ញើរយៈកាលខ្លីជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ និងគ្រឹះស្ថានធនាគារពាណិជ្ជដែលមានស្តង់ដារ និងក្រេឌីតរ៉េតទីងខ្ពស់ ។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិមួយចំនួនក៏ត្រូវបានវិនិយោគតាមរយៈអ្នកចាត់ការខាងក្រៅផងដែរ ។

នៅឆ្នាំ២០១២ នេះ ស្ថានភាពសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងអង់គ្លេសនៅមិនទាន់មានភាពប្រសើរឡើងវិញទាំងស្រុងទេ ។ រីឯបញ្ហាវិបត្តិនៅអឺរ៉ុបនៅតែមានស្ថានភាពតានតឹង ហើយប្រទេសអូស្ត្រាលីនៅតែមានការបារម្ភចំពោះកំណើនសេដ្ឋកិច្ចទាប ។ បញ្ហាទាំងនេះមានឥទ្ធិពលដល់បម្រែបម្រួលនៃអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលទាំងនោះ ។ ជារួម ធនាគារកណ្តាលអាមេរិក និងធនាគារកណ្តាលអង់គ្លេសបានរក្សាអត្រាការប្រាក់គោលប្រាក់ដុល្លារអាមេរិក និងប្រាក់ផោនស្ទែរលីងនៅត្រឹម 0,២៥% និង 0,៥0% រៀងគ្នាដដែល ។ ដោយឡែកធនាគារកណ្តាលអឺរ៉ុប (ECB) បានកាត់បន្ថយអត្រាការប្រាក់គោលចំនួន ២៥ ពិន្ទុ ពី ១% មកនៅត្រឹម 0,៧៥% ហើយធនាគារកណ្តាលអូស្ត្រាលីបានកាត់បន្ថយអត្រាការប្រាក់គោលចំនួន ៤ លើក ស្មើនឹង ១២៥ ពិន្ទុ ពី ៤,២៥% មក ៣% ។

គិតត្រឹមដំណាច់ឆ្នាំ២០១២ ទុនបម្រុងអន្តរជាតិសរុបដែលបានវិនិយោគគិតជាប្រាក់ដុល្លារអាមេរិក (ដោយមិនរាប់បញ្ចូលមាសចំនួន ១២.៤៣៦,១ គីឡូក្រាម និងប្រាក់ SDR ចំនួន ៦៨,៤ លានSDR) មានចំនួន ៣.៨៣៦ លានដុល្លារអាមេរិក កើនឡើងចំនួន ១៩,៤% ធៀបនឹងឆ្នាំ២០១១ (៣.២១៣ លានដុល្លារអាមេរិក) ។

### ៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

ដើម្បីសម្រួលដល់ចរាចរណ៍ប្រាក់រៀលនៅលើទីផ្សារ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ចំនួន ៣៤ លើក ដែលមានទឹកប្រាក់សរុបចំនួន ៥៧៧,៨៩ ពាន់លានរៀល ដោយទទួលបានប្រាក់ដុល្លារអាមេរិកសរុបចំនួន ១៤៤,១៨ លានដុល្លារ ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានលក់ប្រាក់ដុល្លារអាមេរិកជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៩០,៨២ លានដុល្លារអាមេរិក ខណៈដែលការទិញពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានចំនួន ១២,៨០ លានដុល្លារអាមេរិក ។

### ៤.៣. ការងារប្រតិវេទន៍ និងការងារគ្រប់គ្រងអាជីវកម្មនាំចេញ-នាំចូលមាស

ធនាគារជាតិនៃកម្ពុជាបានផ្តល់ទិដ្ឋាការលើប្រតិវេទន៍នាំចូលមាសចំនួន ២២ លើក មានទម្ងន់សរុបចំនួន ១៤.២០០ គីឡូក្រាម និងបានចេញអាជ្ញាប័ណ្ណនាំចេញ-នាំចូល លោហធាតុនិងត្បូងថ្ម មានតម្លៃចំនួន ៤ ច្បាប់ ។ សរុបចំនួនអាជ្ញាប័ណ្ណនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃ ដែលកំពុងមានសុពលភាពមាន ១៩ ច្បាប់ ។

## ៥- សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការចេញបទប្បញ្ញត្តិ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីធានាបានទំនុកចិត្តពីសាធារណជនមកលើប្រព័ន្ធធនាគារ ។ ដោយសារបរិស្ថានសេដ្ឋកិច្ចអំណោយផលល្អ និងមានកំណើនជាបន្តបន្ទាប់ ស្ថានភាពប្រព័ន្ធធនាគារក៏មានការរីកចម្រើនជាលំដាប់ទាំងវិសាលភាព និងទំហំប្រតិបត្តិការ ។ ជាក់ស្តែងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនបានពង្រីកបណ្តាញប្រតិបត្តិការ តាមរយៈការបើកសាខានៅតាមបណ្តារាជធានី-ខេត្ត និងការិយាល័យតំណាងនៅបរទេស ។ ដើម្បីបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជន ធនាគារមួយចំនួន ជាពិសេសធនាគារសាខាបរទេស និងបុត្តសម្ព័ន្ធធនាគារបរទេសបាននាំយកផលិតផល និងសេវាកម្មធនាគារទំនើបថ្មីៗដែលបង្កលក្ខណៈងាយស្រួលដល់អតិថិជន និងបានអភិវឌ្ឍសេវាធនាគារក្នុងកម្រិតមួយគួរឲ្យកត់សម្គាល់ ។

ក្រៅពីវឌ្ឍនភាពខាងលើនេះ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាក៏ត្រូវបានមជ្ឈដ្ឋានជាតិ និងអន្តរជាតិទទួលស្គាល់ផងដែរ ជាពិសេសនៅឆ្នាំនេះ មន្ត្រីធនាគារជាតិនៃកម្ពុជាបានទទួលការអញ្ជើញឲ្យចូលរួមធ្វើបទឧទ្ទេសនាមចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងវេទិកា និងសិក្ខាសាលាស៊ាសិន អាប្រាកា និងនៅបណ្តាប្រទេសមួយចំនួន ដូចជា ភូមា ឡាវ និងវៀតណាម ជាដើម ។

បច្ចុប្បន្នប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជចំនួន ៣២ ធនាគារឯកទេស ៧ ការិយាល័យតំណាងធនាគារបរទេស ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣៥ ដែលក្នុងនោះគ្រឹះស្ថាន ៧ អនុញ្ញាតឲ្យទទួលប្រាក់

បញ្ញើពីសាធារណជន ប្រតិបត្តិករឥណទានជនបទ ៣២ ដែលបានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា និង ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនក្រេឌីត ប្យ៉ូរ៉ូកម្ពុជា ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាទាំងអស់ត្រូវ គោរពតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន ដោយមិនមានបែងចែកថាគ្រឹះស្ថានក្នុងស្រុក ឬសាខាបរទេសនោះទេ ។

ក្នុងឆ្នាំ២០១២ នេះ ប្រព័ន្ធធនាគារមានការរីកចម្រើនគួរឲ្យកត់សម្គាល់ដោយឆ្លុះបញ្ចាំងតាមរយៈ កំណើនទ្រព្យសកម្មសរុប ៣៧,៣% ឥណទានផ្តល់ឲ្យអតិថិជនសរុប ៣៥,១% និងប្រាក់បញ្ញើសរុប ២៩,៧% រៀងគ្នា ធៀបទៅនឹងឆ្នាំ២០១១ ។ ទំហំប្រតិបត្តិករ មូលដ្ឋានអតិថិជន ផលិតផលថ្មីៗរបស់គ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យានៅក្នុងវិស័យធនាគារមានការរីកលូតលាស់ និងដុះដាលពាសពេញផ្ទៃប្រទេស ។ ទន្ទឹមនេះដែរ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានអនុវត្តតាមបទបញ្ជាប្រុងប្រយ័ត្នយ៉ាងល្អប្រសើរ ក្នុងនោះ អនុបាតសាធន ភាពជាមធ្យមមានប្រមាណ ២៥% ខ្ពស់ជាងកម្រិតអប្បរមាដែលមាន ១៥% ហើយអនុបាតសាច់ប្រាក់ ងាយស្រួលមាន ៨២,២% លើសពីកម្រិតកំណត់ ៥០% ។ ចំណែកឥណទានមិនដំណើរការមានត្រឹមតែ ២,៥% ។

### ៥.១. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

#### ៥.១.១. ការត្រួតពិនិត្យលើឯកសារ

ដោយសកម្មភាពប្រតិបត្តិការរបស់ធនាគារកាន់តែមានភាពស្មុគស្មាញ ការធ្វើកំណែទម្រង់នៃវិធីសាស្ត្រ ក្នុងការត្រួតពិនិត្យគឺជាការចាំបាច់ ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលកំណែទម្រង់ ពីការត្រួតពិនិត្យផ្អែកលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិ ទៅជាការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈ អនាគត ហើយកំពុងអភិវឌ្ឍនិងកែសម្រួលប្រព័ន្ធកុំព្យូទ័រទៅជា "ប្រព័ន្ធត្រួតពិនិត្យលើឯកសារ" (Off-site Surveillance System) ដែលជាប្រព័ន្ធត្រួតពិនិត្យមួយស្របតាមការត្រួតពិនិត្យផ្អែកលើហានិភ័យ ។ ប្រព័ន្ធ ត្រួតពិនិត្យលើឯកសារនេះនឹងជួយពង្រឹងការតាមដាន និងការវិភាគលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារជា រៀងរាល់ត្រីមាស តាមទម្រង់របាយការណ៍ថ្មីដែលមានឈ្មោះថា "យុទ្ធសាស្ត្រសម្រាប់ត្រួតពិនិត្យ" ដែលវាយ តម្លៃទៅលើធាតុសំខាន់ៗនៃកាមែល និងលើហានិភ័យភ្ជាប់ផ្សេងៗ ព្រមទាំងវិធានការកែតម្រូវ និងប្រព័ន្ធ ប្រាប់ឲ្យដឹងជាមុនដើម្បីចាត់វិធានការឲ្យទាន់ពេលវេលា ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំចងក្រងគោលការណ៍ និងក្បួននៃការត្រួតពិនិត្យតាម រយៈឯកសារ (Off-site Manual) ស្របតាមការត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់ជាមូលដ្ឋានក្នុងការត្រួត ពិនិត្យ ផ្តល់លក្ខណៈងាយស្រួលនិងមានសង្គតិភាពក្នុងការវិភាគ និងការចាត់វិធានការកែតម្រូវឲ្យទាន់ពេល វេលា ។

#### ៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តការត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុ ប្រកបដោយការយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ ដោយប្រើប្រាស់វិធីសាស្ត្រកាមែល ក្នុងការ វាយតម្លៃ ដើម្បីធានាឲ្យបាននូវភាពរឹងមាំ និងសុវត្ថិភាពនៅក្នុងប្រព័ន្ធធនាគារទាំងមូល ។ ការត្រួតពិនិត្យនេះ

ផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើរចនាសម្ព័ន្ធគ្រប់គ្រង អភិបាលកិច្ចល្អ ការត្រួតពិនិត្យផ្ទៃក្នុង និងផលប៉ះពាល់នៃអាជីវកម្មរបស់គ្រឹះស្ថានធនាគារជាដើម ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានពង្រឹងគុណវុឌ្ឍិមន្ត្រីត្រួតពិនិត្យ និងសិក្សាពីលទ្ធភាពនៃការវិវត្តវិធីសាស្ត្រត្រួតពិនិត្យពីកាមែល ទៅការត្រួតពិនិត្យដោយផ្តោតលើហានិភ័យ និងការព្យាករពីផលប៉ះពាល់នាពេលអនាគត ។ ជាមួយនឹងការរីកចម្រើននៃប្រតិបត្តិការធនាគារ និងគុណវុឌ្ឍិមន្ត្រីត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាមានផែនការត្រួតពិនិត្យឆ្លងដែនចំពោះគ្រឹះស្ថានធនាគារដែលមានសាខានៅបរទេសផងដែរ ។

ក្នុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាបានចុះត្រួតពិនិត្យដល់ទីកន្លែងស្របតាមផែនការដែលបានដាក់ចេញចំពោះធនាគារពាណិជ្ជ ១៩ ធនាគារឯកទេស ៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១៣ និងប្រតិបត្តិករឥណទានជនបទ ៥ ។ លទ្ធផលនៃការត្រួតពិនិត្យបានបង្ហាញថា ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានលក្ខណៈល្អប្រសើរ ។

**៥.១.៣. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

ស្ថានភាពជាទូទៅនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកំពុងរីកចម្រើនជាលំដាប់ ជាក់ស្តែងគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណបានកើនពីចំនួន ១៦ ក្នុងឆ្នាំ២០០៥ ដល់ ៣៥ នៅដំណាច់ឆ្នាំ ២០១២ ដែលក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៧ ត្រូវបានអនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីសាធារណជន និងមានបណ្តាញសាខានៅថ្នាក់ឃុំចំនួន ១២.៩៧៤ ការិយាល័យ ។ ក្រៅពីនេះ នៅមានប្រតិបត្តិករឥណទានជនបទ ៣២ ដែលកំពុងធ្វើប្រតិបត្តិការផ្តល់សេវាហិរញ្ញវត្ថុខ្នាតតូចដល់ប្រជាពលរដ្ឋនៅតាមជនបទ ។

ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានទឹកប្រាក់សរុបចំនួន ៣.៥៣៩ ពាន់លានរៀល ដែលត្រូវបានផ្តល់ដល់អតិថិជនចំនួន១.៣០១.៦៨០ នាក់ ពោលគឺកើនឡើង ៣៦,៦% និង ១៤% រៀងគ្នា ធៀបនឹងដំណាច់ឆ្នាំ២០១១ ។ ទន្ទឹមនោះ ប្រាក់បញ្ញើសរុបមានចំនួន ១.០៩៤,១ ពាន់លានរៀល ដែលទទួលពីអតិថិជនចំនួន ៦៨៦.៦៦៦ នាក់ គឺកើនឡើង ១៣៨,១% និង ១៨៣,៦% រៀងគ្នា ។ រីឯចំនួនស្ត្រីដែលទទួលបានសេវាប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុមានចំនួន ១.០៧៥.១៨១ នាក់ ពោលគឺប្រមាណ ៨២,៦% នៃចំនួនអ្នកខ្ចីប្រាក់សរុប ។

ដើម្បីរក្សាស្ថិរភាពនៃកំណើននិងនិរន្តរភាពរបស់វិស័យមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបន្តការត្រួតពិនិត្យតាមដានជាប្រចាំ តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ព្រមទាំងបានដាក់ចេញនូវបទប្បញ្ញត្តិនានាជាបន្តបន្ទាប់ស្របតាមការអនុវត្តនិងអនុលោមតាមបទដ្ឋានអន្តរជាតិ សំដៅជំរុញឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានមូលដ្ឋានច្បាស់លាស់ក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងទីផ្សារប្រកួតប្រជែងស្មើភាព និងគោរពតាមគោលការណ៍ស្តីពីកិច្ចការពារអតិថិជន និងតម្លាភាព ។ ទន្ទឹមនេះ ចាប់ពីដើមឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យប្រើប្រាស់ប្រព័ន្ធផលិតរបាយការណ៍ស្វ័យប្រវត្តិ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានឈ្មោះថា ប្រព័ន្ធព័ត៌មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ MFIS ។ ប្រព័ន្ធនេះបានផ្តល់ភាពងាយស្រួលក្នុងការទាញយករបាយការណ៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីធ្វើការវិភាគអំពីស្ថានភាពហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅរបស់គ្រឹះស្ថាន។ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានាក្នុងការពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យ ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ជនបទ ចូលរួមចំណែកលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រចតុកោណជំហានទីពីររបស់រាជរដ្ឋាភិបាល ។

### ៥.២. ការងារនីតិកម្ម

ក្នុងឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យប្រើប្រាស់សៀវភៅ "កម្រងច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឆ្នាំ២០១១" ហើយបាននិងកំពុងពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិមួយចំនួនទៀតឲ្យស្របតាមតម្រូវការទីផ្សារ គោលការណ៍គណៈកម្មការទីក្រុងបាសែល ក៏ដូចជាអភិក្រមអន្តរជាតិសំដៅពង្រឹងប្រព័ន្ធធនាគារទាំងមូល ។

បច្ចុប្បន្ននេះ ដោយមានការរីកចម្រើននៃវិស័យធនាគារនិងផលិតផលហិរញ្ញវត្ថុថ្មីៗ ដូចជាការបង្កើតទីផ្សារភាគហ៊ុនជាដើម ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងនូវការអនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្នជាធរមានក្នុងគោលបំណងដើម្បីឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រព្រឹត្តិទៅប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាពខ្ពស់ ។

### ៥.៣. ការងារវិភាគ តាមដាន និងការគ្រប់គ្រងទិន្នន័យ

ចំពោះការងារវិភាគ និងតាមដានម៉ាក្រូ គឺជាការងារវិភាគផ្តោតទៅលើសក្តានុពលនៃហានិភ័យជាប្រព័ន្ធព្រមទាំងហានិភ័យចម្បងៗ ដូចជា ហានិភ័យឥណទាន ហានិភ័យសន្ទីយភាព ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ ដោយហានិភ័យទាំងអស់នេះអាចជះឥទ្ធិពលដល់ប្រព័ន្ធធនាគារ ក៏ដូចជាស្វែងយល់អំពីទំនាក់ទំនងរវាងវិស័យធនាគារនិងស្ថានភាពសេដ្ឋកិច្ច ព្រមទាំងផលប៉ះពាល់អំពីវិបត្តិខាងក្រៅផងដែរ ។ របាយការណ៍វិភាគម៉ាក្រូអំពីស្ថានភាពប្រព័ន្ធធនាគារត្រូវបានរៀបចំឡើងក្នុងរយៈពេលមួយត្រីមាសម្តង និងទៅតាមការចាំបាច់ ដោយប្រើប្រាស់សូចនាករសំខាន់ៗសម្រាប់ការវិភាគ ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានត្រួតពិនិត្យក៏បានរៀបចំនូវយុទ្ធសាស្ត្រត្រួតពិនិត្យមានភាពពាក់ព័ន្ធទៅនឹងការអនុវត្តបទដ្ឋាន និងស្តង់ដារអន្តរជាតិសំខាន់ៗ ដូចជា ការអនុវត្តគោលការណ៍ស្នូលសម្រាប់ការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ការអនុវត្តគោលការណ៍សម្រាប់ភាពគ្រប់គ្រាន់លើដើមទុនដូចជា Basel II និងការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ IFRS ។

ការងារវិភាគ និងតាមដានម៉ាក្រូនេះ មានភាពផ្សារភ្ជាប់ជាមួយការងារគ្រប់គ្រងទិន្នន័យ ហើយបានកំពុងដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធបញ្ជូនរបាយការណ៍ថ្មីតាមរយៈ Online និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យដោយស្វ័យប្រវត្តិ ដែលការងារបានបញ្ចប់ដំណាក់កាលទីមួយជាស្ថាពរ និងកំពុងអនុវត្តដំណាក់កាលទីពីរ ហើយរំពឹងថា នឹងបញ្ចប់នៅក្នុងឆ្នាំ២០១៣ ព្រមទាំងដំណាក់កាលបន្តបន្ទាប់ទៀត ។

### ៥.៤.ការងារផ្តល់អាជ្ញាប័ណ្ណ និងចុះបញ្ជី

ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារពាណិជ្ជចំនួន១លិខិតបើកការិយាល័យតំណាងធនាគារបរទេសចំនួន ២ ផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣ អាជ្ញាប័ណ្ណក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ១ ផ្តល់វិញ្ញាបនប័ត្រដល់ប្រតិបត្តិករឥណទានជនបទស្នើសុំចុះបញ្ជីថ្មីចំនួន ៤ បន្តសុពលភាពវិញ្ញាបនប័ត្រដល់ប្រតិបត្តិករឥណទានជនបទចំនួន ៥ ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា និងតតិយភាគីចំនួន ១ ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មប្តូរប្រាក់

ដល់ធនាគារពាណិជ្ជសរុបចំនួន ៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២៦ អាជ្ញាប័ណ្ណអាជីវករប្តូរប្រាក់ចំនួន ១២ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ទៅអាជីវករចំនួន ១.៥៣១ ។

### ៥.៥. ការងារត្រួតពិនិត្យការិយាល័យឥណទាន

បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា បានដាក់ឲ្យដំណើរការជាផ្លូវការប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅខែមីនា ឆ្នាំ២០១២ ។ គិតចាប់ពីការដាក់ឲ្យដំណើរការប្រព័ន្ធនេះ គ្រឹះស្ថានធនាគារចំនួន ៣៧ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣២ បានចូលរួមជាសមាជិកប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននេះ ។ ទន្ទឹមនេះ ដើម្បីជំរុញឲ្យការផ្តល់ទិន្នន័យប្រកបដោយតម្លាភាព សុក្រឹត្យភាពខ្ពស់ ធនាគារជាតិនៃកម្ពុជាបានក្រើនរំលឹកដល់គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអំពីការអនុវត្តឲ្យពេញលេញ និងត្រឹមត្រូវតាមប្រកាសស្តីពីការចែករំលែកព័ត៌មានចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ដើម្បីកាត់បន្ថយហានិភ័យលើការផ្តល់ឥណទាន ។ នៅក្នុងខែវិច្ឆិកា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីចូលរួមបង្កើតសៀវភៅណែនាំស្តីពីនីតិវិធីគ្រប់គ្រងនិងត្រួតពិនិត្យការិយាល័យព័ត៌មានឥណទាន។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោក ប្រព័ន្ធនេះបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឲ្យកម្ពុជាមានចំណាត់ថ្នាក់ផ្នែកអាជីវកម្មបានល្អប្រសើរជាងមុន ។ ជាក់ស្តែងនៅចុងឆ្នាំនេះ ក្រុមការងារបច្ចេកទេសធនាគារកណ្តាលឡាវ និងកេនយ៉ា បានមកសិក្សាស្វែងយល់អំពីប្រវត្តិ ការគ្រប់គ្រង និងការត្រួតពិនិត្យប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅធនាគារជាតិនៃកម្ពុជា ។

### ៥.៦. ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក)

នៅឆ្នាំ២០១២ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាលេខាធិការដ្ឋាន ដែលមានភារកិច្ចជួយគណៈកម្មាធិការនេះ ក្នុងការអនុវត្តមុខងារនិងភារកិច្ចឲ្យមានប្រសិទ្ធភាព ។ ស.ហ.ក បានសហការជាមួយអគ្គនាយកដ្ឋានត្រួតពិនិត្យចុះត្រួតពិនិត្យដល់ទីកន្លែងលើធនាគារពាណិជ្ជ ៧ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១ ។

ដោយឡែក ស.ហ.ក ក៏បានលើកកម្ពស់ការយល់ដឹងអំពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញ-ប្បទានភេរវកម្ម សម្រាប់បុគ្គលរាយការណ៍ជាក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារអចលនទ្រព្យ និងកាស៊ីណូ ព្រមទាំងអាជ្ញាធរត្រួតពិនិត្យគ្រឹះស្ថានទាំងនេះផងដែរ ។

ទន្ទឹមនេះ ស.ហ.ក បានពង្រឹងនិងពង្រីកកិច្ចសហការជាមួយដៃគូជាតិនិងអន្តរជាតិជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការស្វែងរក និងទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ នៅឆ្នាំ២០១២ នេះ ស.ហ.ក បានចុះហត្ថលេខាលើអនុស្សរណៈយល់គ្នាស្តីពី ការផ្លាស់ប្តូរព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មក្នុងក្របខ័ណ្ឌជាតិ ជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងក្នុងក្របខ័ណ្ឌអន្តរជាតិ ជាមួយធនាគារកណ្តាលវៀតណាម ។ ក្រៅពីនេះ ស.ហ.ក ក៏បានទទួលសំណើចុះហត្ថលេខាលើអនុស្សរណៈយល់គ្នាពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៃសាធារណរដ្ឋកូរ៉េ សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋហ្វីលីពីន ប្រទេសប្រ៊ុយណេ និងព្រះរាជាណាចក្រថៃឡង់ និងកំពុងរៀបចំ

យុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១២-២០១៥ ក្នុងគោលបំណងបង្កើតប្រព័ន្ធមួយដ៏រឹងមាំដើម្បីប្រយុទ្ធប្រឆាំងសកម្មភាពទាំងនេះ ស្របតាមការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ និងនិន្នាការក្នុងតំបន់និងពិភពលោក ។

## ៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ៦.១- សេវាគ្រប់គ្រងគណនី

បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីជារូបិយវត្ថុ និងជាដុល្លារអាមេរិកប្រមាណ ១.០៣៤ គណនី ។ គណនីទាំងនោះជារបស់ស្ថាប័នរដ្ឋនិងអង្គភាពរដ្ឋបាលកណ្តាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការអនុញ្ញាតឲ្យធ្វើអាជីវកម្ម និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។

#### *៦.១.១- ស្ថាប័នរដ្ឋ*

ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធនាគារជាតិនៃកម្ពុជាបានទទួលបើកគណនីជូនស្ថាប័នរដ្ឋ និងផ្តល់សេវាទូទាត់មានដូចជា ដកសាច់ប្រាក់ ផ្ទេរប្រាក់ បើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ។

ការបង់ពន្ធដារ និងពន្ធគយដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជា មានទំហំទឹកប្រាក់សរុប ២.២០៤ ពាន់លានរៀល ។ ចាប់ពីខែកញ្ញា ឆ្នាំ២០១២ មក ការបង់ចំណូលពន្ធដារត្រូវបានផ្ទេរទៅធនាគារពាណិជ្ជវិញ ។

#### *៦.១.២- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ*

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបើកគណនីនៅធនាគារជាតិនៃកម្ពុជារួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើធានាលើដើមទុន គណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីប្រាក់បញ្ញើមានកាលកំណត់ ។ សមតុល្យសរុបនៃប្រាក់បញ្ញើទាំងនោះមាន ៣៨៧ ពាន់លានរៀល និង ២.០៤០ លានដុល្លារអាមេរិក ។

### ៦.២- សេវាផ្ទេរប្រាក់ក្នុងប្រទេស

+ **ការផ្ទេរចូលមកទីស្នាក់ការកណ្តាលៈ**
  - ជាប្រាក់រៀលមានចំនួន ៧៩៩ ពាន់លានរៀល
  - ជាប្រាក់ដុល្លារមានចំនួន ៦៧៨ លានដុល្លារអាមេរិក ។
+ **ការផ្ទេរចេញទៅសាខារាជធានី-ខេត្តៈ**
  - ជាប្រាក់រៀលមានចំនួន ១.០៥៥ ពាន់លានរៀល
  - ជាប្រាក់ដុល្លារមានចំនួន ១៤៩ លានដុល្លារអាមេរិក ។

### ៦.៣- សេវាផាត់ទាត់មូលប្បទានបត្រ

ប្រតិបត្តិការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ត្រូវបានដំណើរការប្រកបដោយប្រសិទ្ធភាព និងប្រព្រឹត្តិទៅជារៀងរាល់ថ្ងៃធ្វើការ ។ សកម្មភាពផាត់ទាត់ឆ្នាំនេះបានដំណើរការចំនួន ២៣៤ ថ្ងៃ ។

***៦.៣.១- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល***

សភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀលមានសមាជិកចូលរួមចំនួន ៣១ ក្នុងនោះមានធនាគារពាណិជ្ជ ២៨ ធនាគារឯកទេស ២ និងធនាគារជាតិនៃកម្ពុជា ។ មូលប្បទានបត្រដែលបានផាត់ទាត់សរុបមាន ៣៩.៧៥៦សន្លឹកស្មើនឹងចំនួនប្រាក់សរុប ២.៣៨៨ ពាន់លានរៀល ក្នុងនោះមាន៖

- **ទីស្នាក់ការកណ្តាល:** ការផាត់ទាត់មូលប្បទានបត្រមាន ៣៩.២៨៨សន្លឹក ស្មើនឹងទឹកប្រាក់ ២.៣៤៤ ពាន់លានរៀល ។ បើធៀបនឹងឆ្នាំ២០១១ ចំនួនមូលប្បទានបត្របានកើន ៤.៥៤៦ សន្លឹក ស្មើនឹង ១៣% ហើយទឹកប្រាក់ទូទាត់បានកើន ៥២៣ ពាន់លានរៀល ស្មើនឹង ២៩% ។

- **សាខាធនាគារជាតិនៃកម្ពុជា:** សាខាខេត្តសៀមរាប ព្រះសីហនុ បាត់ដំបង និងកំពង់ចាម បានផាត់ទាត់មូលប្បទានបត្រសរុប ៤៦៨សន្លឹក ស្មើនឹងទឹកប្រាក់ ០.០៤៤ ពាន់លានរៀល ។

***៦.៣.២- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក***

សភាផាត់ទាត់មូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិក មានសមាជិកចូលរួមចំនួន ៣៨ ក្នុងនោះមានធនាគារពាណិជ្ជ ៣២ ធនាគារឯកទេស ៥ និងធនាគារជាតិនៃកម្ពុជា ។ មូលប្បទានបត្រសរុបដែលបានផាត់ទាត់មាន ៦៩២.១៦២ សន្លឹក ស្មើនឹងទឹកប្រាក់ ១២.៨៧៨ លានដុល្លារអាមេរិក ក្នុងនោះមាន៖

- **ទីស្នាក់ការកណ្តាល:** ការផាត់ទាត់មូលប្បទានបត្រមាន ៦៥៨.៣២៩សន្លឹក ស្មើនឹងទឹកប្រាក់ ១២.៥៧៥ លានដុល្លារអាមេរិក ។ បើធៀបទៅនឹងឆ្នាំ២០១១ ចំនួនមូលប្បទានបត្រកើន ៩៩.៤៣៥ សន្លឹក ស្មើនឹង ១៨% ហើយទឹកប្រាក់ទូទាត់កើន ៣.០០២ លានដុល្លារអាមេរិក ស្មើនឹង ៣១%។

- **សាខាធនាគារជាតិនៃកម្ពុជាខេត្ត:** សាខាខេត្តសៀមរាប ព្រះសីហនុ បាត់ដំបង និងកំពង់ចាម បានផាត់ទាត់មូលប្បទានបត្រសរុប ៣៣.៨៣៣សន្លឹក ស្មើនឹងទឹកប្រាក់ ៣០៣ លានដុល្លារអាមេរិក។

**៦.៤- ការងារឥណទាន**

ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទានចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រមូលបំណុលដែលដល់កាលកំណត់សង ដូចខាងក្រោម៖

- សមតុល្យដើមគ្រា ១៨,៥ ពាន់លានរៀល
- ឥណទានដែលបានផ្តល់ ៤៩,៣ ពាន់លានរៀល
- ឥណទានដែលបានទូទាត់សង ៦៥,៧ ពាន់លានរៀល
- សមតុល្យចុងគ្រា ២,៦ ពាន់លានរៀល ។

**៦.៥- ការងារគ្រប់គ្រងមូលបត្រ**

***៦.៥.១-ការងារគ្រប់គ្រងមូលបត្ររបស់រាជរដ្ឋាភិបាល***

ធនាគារជាតិនៃកម្ពុជាបានតាមដានសម្របសម្រួលការងារពាក់ព័ន្ធនឹងការគ្រប់គ្រងបណ្ណសងតាមបញ្ជារបស់រាជរដ្ឋាភិបាល ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ។

***៦.៥.២-ការងាររៀបចំចេញផ្សាយវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបាន(NCD)***

ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចជួបពិភាក្សាពិគ្រោះយោបល់ជាមួយសមាគមធនាគារនៅកម្ពុជា

(ABC) សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ដើម្បីពិគ្រោះយោបល់ និងទទួលអនុសាសន៍លើគម្រោងចេញផ្សាយវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបាន (NCD) នាពេលខាងមុខ ។

**៦.៦- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល**

***ក- ហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន***

***ក.១- ហិរញ្ញប្បទានឥតសំណងក្នុងគម្រោង***

រាជរដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងក្នុងគម្រោងដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៣ គម្រោង គឺ ទី១) គម្រោងកែលម្អបរិក្ខារពេទ្យនៅតាមមន្ទីរពេទ្យថ្នាក់ជាតិនិងមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត មានទឹកប្រាក់ ៣៧៤ លានយ៉េន ទី២) គម្រោងស្តារនិងកាត់បន្ថយគ្រោះមហន្តរាយដោយសារទឹកជំនន់ ១.៥១០ លានយ៉េន និង ទី៣) គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស មានទឹកប្រាក់ ២៨៣ លានយ៉េន ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងធនាគារ ជាមួយធនាគារតូក្យូមីតស៊ុយប៊ីស៊ី ដើម្បីសម្រួលដល់ការទូទាត់ហិរញ្ញប្បទានខាងលើនេះ ។ ចំពោះគម្រោងដែលបានផ្តល់និងកំពុងអនុវត្តក្នុងឆ្នាំនេះ មានដូចខាងក្រោម៖

១- គម្រោងការពារទឹកជំនន់ក្នុងរាជធានីភ្នំពេញជំហានទី៣ មានទឹកប្រាក់ ៣.៧០០ លានយ៉េន
២- គម្រោងបំពាក់ឧបករណ៍សម្រាប់សកម្មភាពបោសសម្អាតមីនជំហានទី៦ មានទឹកប្រាក់ ១.២៩៨ លានយ៉េន
៣- គម្រោងជួសជុលនិងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តនានា មានទឹកប្រាក់ ២.៧៦០ លានយ៉េន
៤- គម្រោងសម្រាប់អាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស មានទឹកប្រាក់ ២៧៣ លានយ៉េន
៥- គម្រោងបំពាក់ឧបករណ៍អប់រំនៅដេប៉ាតឺម៉ង់ទេព្យកោសល្យធនធានរ៉ែនិងភូគព្ភសាស្ត្រនៃវិទ្យាស្ថាន បច្ចេកវិទ្យាកម្ពុជា មានទឹកប្រាក់ ៥៥,៧ លានយ៉េន និង
៦- គម្រោងសម្រាប់សាងសង់ស្ពានអ្នកលឿង មានទឹកប្រាក់ ១១.៩៤០ លានយ៉េន ។

***ក.២- ហិរញ្ញប្បទានឥតសំណងក្រៅគម្រោង***

រាជរដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងក្រៅគម្រោងដល់រាជរដ្ឋាភិបាលកម្ពុជានូវទឹកប្រាក់សរុប៦០០លានយ៉េន សម្រាប់ការពារគ្រោះធម្មជាតិដែលបណ្តាលមកពីទឹកជំនន់ ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងធនាគារ ជាមួយធនាគារតូក្យូមីតស៊ុយប៊ីស៊ី សម្រាប់ការទូទាត់ដែលត្រូវបានបញ្ចប់ និងបានបិទគណនីវិញកាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ។

***ខ- កម្ចីសម្បទានរាជរដ្ឋាភិបាលជប៉ុន***

ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងធនាគារ ជាមួយធនាគារតូក្យូមីតស៊ុយប៊ីស៊ី សម្រាប់កម្ចីសម្បទានគម្រោងជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រខាងលិចបឹងទន្លេសាប (L/A No.CP-P11) ដែលមានទឹកប្រាក់ ៤.២៦៩ លានយ៉េន ។ ចំពោះកម្ចីសម្បទានដែលបានផ្តល់កន្លងមក មានគម្រោងមួយត្រូវបានបញ្ចប់ គឺគម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ (L/ANo.CP-P6)

ដែលមានទឹកប្រាក់ ៣១៨ លានយ៉េន ហើយគម្រោងកំពុងអនុវត្តមានដូចខាងក្រោម ៖

១- គម្រោងអភិវឌ្ឍន៍កំពុងផែពហុបំណងខេត្តព្រះសីហនុ (L/A No.CP-P10) មានទឹកប្រាក់ ៧.១៧៦ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០១០)

២- គម្រោងផ្គត់ផ្គង់ទឹកស្អាតនិរោធន៍ (L/A No.CP-P9) មានទឹកប្រាក់ ៣.៥១៣ លានយ៉េន (ចុះហត្ថលេខា ឆ្នាំ២០១០)

៣- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ (L/A No.CP-P8) មានទឹកប្រាក់ ៣.៦៥១ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៨)

៤- គម្រោងអភិវឌ្ឍន៍ខ្សែបណ្តាញថាមពលអគ្គិសនីមហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P7) មានទឹកប្រាក់ ២.៦៣២ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៧) និង

៥- គម្រោងបង្កើតបណ្តាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P5) មានទឹកប្រាក់ ៣.០២៩ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៥) ។

**៧- ការគ្រប់គ្រងចរាចរណ៍ធនបត្រ**

ចំណូលសាច់ប្រាក់រៀលតាមបេឡាប្រតិបត្តិការមានចំនួន ៧.៣៣២,៥ ពាន់លានរៀល បើធៀបនឹងឆ្នាំ២០១១ កើនឡើង ៦,២% ក្នុងនោះ ប្រាក់បញ្ញើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកើនឡើង ៤៣១,៦ ពាន់លានរៀល (៤៦,៤%) ប្រាក់បញ្ញើអគ្គិសនីកម្ពុជាកើនឡើង ៨៦,៦ ពាន់លានរៀល (១៤,៥%) និងពីសាខាធនាគារជាតិនៃកម្ពុជាកើនឡើង ១៨១,៣ ពាន់លានរៀល (៤៧,២%) ។ ផ្ទុយទៅវិញ ក៏មានចំណូលមួយចំនួនថយចុះដែរ ដូចជា ចំណូលពីឃ្លាំងសម្របសម្រួលបោះផ្សាយថយចុះ ៦៤,៧ ពាន់លានរៀល (១,៨%) ប្រាក់បញ្ញើអាជីវករថយចុះ ៣៧,៥ ពាន់លានរៀល (៦,៣%) ចំណូលបញ្ញើរតនាគារជាតិថយចុះ ៩១,៣ ពាន់លានរៀល (២០,១%) និងចំណូលសាច់ប្រាក់ផ្សេងៗថយចុះ ៧៦,១ ពាន់លានរៀល (២២,៩%) ។

ចំពោះការចំណាយសាច់ប្រាក់តាមបេឡាប្រតិបត្តិការវិញមាន ៧.៣៤៥,៣ ពាន់លានរៀល បើធៀបនឹងឆ្នាំ២០១១ កើនឡើង ៦,៦% ក្នុងនោះ ការបញ្ចេញទៅឃ្លាំងសម្របសម្រួលបោះផ្សាយកើនឡើង ៥៤៩,៨ ពាន់លានរៀល (១៩%) ចំណាយលើការដកប្រាក់បញ្ញើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកើនឡើង ១៣១,៤ ពាន់លានរៀល (៤៨,៧%) និងចំណាយឲ្យរតនាគារជាតិកើនឡើង ២០៦,៨ ពាន់លានរៀល (១០,៨%) ។ ផ្ទុយទៅវិញ ក៏មានចំណាយមួយចំនួនថយចុះដែរ ដូចជា ចំណាយអាជីវករដកប្រាក់បញ្ញើថយចុះ ២២៩,១ ពាន់លានរៀល (៥៤,៨%) ចំណាយឲ្យសាខាធនាគារជាតិនៃកម្ពុជាថយចុះ ១៣០,៥ ពាន់លានរៀល (១២,៧%) និងចំណាយផ្សេងៗថយចុះ ៧៣,៧ ពាន់លានរៀល (២០%) ។

ក្នុងគ្រានេះដែរ សកម្មភាពប្រាក់ដុល្លារអាមេរិកតាមបេឡាប្រតិបត្តិការសរុបមាន ៣.៨០១,៧ លានដុល្លារអាមេរិក កើនឡើង ៨៧២,១ លានដុល្លារអាមេរិក (២៩,៨%) ហើយចំណាយតាមរយៈបេឡាប្រតិបត្តិការមាន ៣.៨០១,៧ លានដុល្លារ កើនឡើង ៨៧១,៨(២៩,៨) បើធៀបនឹងឆ្នាំ២០១១ ។

ដើម្បីសម្រួលដល់ចរាចរណ៍ក្រដាសប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានផ្តល់ក្រដាសប្រាក់ថ្មីឲ្យសាខាធនាគារជាតិនៃកម្ពុជាសម្រាប់ដូរយកក្រដាសប្រាក់ចាស់ ទក់ រហែក ចំនួន ៤៣៦,១ ពាន់លានរៀល កើនឡើង ១២២,៨ ពាន់លានរៀល (៣៩,២%) បើធៀបនឹងឆ្នាំ២០១១ ហើយបានធ្វើការកាត់ កម្ទេច និង

បំផ្លាញចោលក្រដាសប្រាក់ ចាស់ ទក់ រហែក ដោយម៉ាស៊ីនធម្មតាចំនួន ៩៩៤,១ ពាន់លានរៀល កើនឡើង ១៦៩,៤ ពាន់លានរៀល (២០,៥%) និងដោយម៉ាស៊ីនស្វ័យប្រវត្តិចំនួន ៦១៩ ពាន់លានរៀល កើនឡើង ១៤៤,៩ ពាន់លានរៀល (៣០,៦%) បើធៀបនឹងឆ្នាំ២០១១ ។

ចំពោះការងារគ្រប់គ្រងសាច់ប្រាក់និងការងាររាំងខ្ទប់ចរាចរណ៍ក្រដាសប្រាក់ក្លែងក្លាយ ធនាគារជាតិនៃកម្ពុជាតែងតែតាមដាន និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចជាប្រចាំ ហើយបានដកហូតក្រដាសប្រាក់រៀលក្លែងក្លាយប្រភេទចតចម្លងចំនួន ៦៨១សន្លឹក កើនឡើង ៤២៤ សន្លឹក (១,៦ដង) ក្រដាសប្រាក់គំរូចំនួន ០៦សន្លឹក កើនឡើង ០៤សន្លឹក (២ដង) និងក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយចំនួន ៣៨០ សន្លឹក ថយចុះ ៣៣ សន្លឹក (៨%) បើធៀបនឹងឆ្នាំ២០១១ ។

### ៨- ការអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិ

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធផាត់ទាត់ជាតិដែលបានចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០១០ ត្រូវបានបញ្ចប់ ហើយប្រព័ន្ធផាត់ទាត់ជាតិត្រូវបានដាក់ដំណើរការជាផ្លូវការនៅខែធ្នូ ឆ្នាំ២០១២ ។ ជាមួយនឹងការអភិវឌ្ឍប្រព័ន្ធនេះ ធនាគារជាតិនៃកម្ពុជាបានបំពាក់ប្រព័ន្ធ Client Module នៅស្នាក់ការកណ្តាលរបស់ធនាគារជាសមាជិក ៣៨ ធនាគារ សម្រាប់ភ្ជាប់ទៅប្រព័ន្ធផាត់ទាត់ជាតិនៅសភាផាត់ទាត់ជាតិ ហើយបានបណ្តុះបណ្តាលដល់សមាជិកទាំងនោះ និងសាខាធនាគារជាតិនៃកម្ពុជាចំនួន ៤ អំពីការប្រើប្រាស់ប្រព័ន្ធ Client Module នេះ ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិសម្រាប់ជាមូលដ្ឋានគតិយុត្តក្នុងការគ្រប់គ្រង និងសម្រួលដល់ដំណើរការប្រព័ន្ធផាត់ទាត់ជាតិ និងសេចក្តីណែនាំសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធ Client Module ។

### ៩- ការងារព័ត៌មានវិទ្យា

ការងារព័ត៌មានវិទ្យាដែលធនាគារជាតិនៃកម្ពុជាបានផ្តោតសំខាន់ក្នុងឆ្នាំនេះ រួមមាន ការរៀបចំប្រព័ន្ធផាត់ទាត់ជាតិ និងការធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ដំណើរការប្រតិបត្តិការសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រោមជំនួយបច្ចេកទេសរបស់រតនាគារសហរដ្ឋអាមេរិក ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធផ្ញើរបាយការណ៍មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIURS) ដែលនឹងដាក់ឲ្យដំណើរការក្នុងឆ្នាំ២០១៣ ។ ទន្ទឹមនេះ ដោយមានជំនួយបច្ចេកទេសពីបណ្តាជំនាញការអមធនាគារជាតិនៃកម្ពុជា ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងអភិវឌ្ឍប្រព័ន្ធផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ និងធនាគារឯកទេសតាមបណ្តាញអ៊ីនធើណិត (BSRS) ហើយកំពុងអភិវឌ្ឍនិងគ្រោងដាក់ឲ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងការចេញផ្សាយវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជា (NCDBES) នៅឆ្នាំ២០១៣ ខាងមុខ ។

## II-ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្ន មានសមាសភាពដូចខាងក្រោម៖

- ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាប្រធាន

| | | |
|---|---|---|
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិកា |
| - ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ចុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិកា ។ |

ក្នុងឆ្នាំនេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ៦ លើក ដើម្បីពិភាក្សានិងអនុម័តការងារមួយចំនួនដូចខាងក្រោម៖

១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩០ នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ស្តីពី៖

(i) ការពិនិត្យនិងសម្រេចសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជាសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១១

(ii) របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ របស់សវនករឯករាជ្យ PWC

(iii) របាយការណ៍សវនកម្មនៅធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០០៧ របស់អាជ្ញាធរសវនកម្មជាតិ ។

២. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩១ នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ ដើម្បីពិនិត្យនិងសម្រេចសេចក្តីព្រាងរបាយការណ៍ស្តីពី ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០១១ និងផែនការថវិកាឆ្នាំ២០១២ ។

៣. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩២ នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ ដើម្បីពិនិត្យនិងសម្រេចសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា ។

៤. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩៣ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ដើម្បីពិភាក្សាអំពីគោលនយោបាយវិនិយោគសម្រាប់ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ និងពិភាក្សាអំពីសំណើសុំបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ច ។

៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩៤ នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ដើម្បីពិនិត្យនិងអនុម័តសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពចំណូល-ចំណាយថវិកាឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា ។

៦. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩៥ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២ ដើម្បីពិនិត្យនិងអនុម័តសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១២ និងទិសដៅការងារឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា ។

## ២- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

### ២.១- ស្ថិតិមន្ត្រីបុគ្គលិក

- ក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជាទីស្នាក់ការកណ្តាល មានចំនួន ៨៦៩រូប (ប្រុស ៤៨៧រូប ស្រី ៣៨២រូប)
- ក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត មានចំនួន ៣៧៩រូប (ប្រុស ២១៧រូប ស្រី ១៦២រូប)

សរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេស មានចំនួន ១.២៤៨រូប (ប្រុស ៧០៤រូប ស្រី ៥៤៤រូប) បើធៀបនឹងក្របខ័ណ្ឌក្នុងខែធ្នូ ឆ្នាំ២០១១ ដែលមានចំនួន ១.២៦០រូប (ប្រុស ៧១៨រូប ស្រី ៥៤២រូប) មានការប្រែប្រួលដូចតទៅះ

- ទីស្នាក់ការកណ្តាល : ថយចុះ ៥រូប (ចូល ១៣រូប ចេញ ១៨រូប)
- សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត : ថយចុះ ៧រូប (ចូល ២រូប ចេញ ៩រូប) ។

### ២.២- ការងារបណ្តុះបណ្តាល

#### ក- ការងារបណ្តុះបណ្តាលក្នុងប្រទេស

ធនាគារជាតិនៃកម្ពុជាបានបើកវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាចំនួន ១៥លើក (មន្ត្រីបុគ្គលិកចូលរួម ៥៣១រូប) និងវគ្គឧទ្ទេសនាមដោយមន្ត្រីដែលបានត្រឡប់មកពីបណ្តុះបណ្តាលនៅក្រៅប្រទេសចំនួន ១៣ លើក (មន្ត្រីបុគ្គលិកចូលរួម ៥៣០រូប) ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីបុគ្គលិកចូលរួមវគ្គសិក្សានៅសាលាភូមិន្ទរដ្ឋបាល ២រូប វគ្គបណ្តុះបណ្តាលនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ ៧រូប (ជំនាន់ទី ២១ ចំនួន ៦រូប និងជំនាន់ទី ២២ ចំនួន ១រូប) វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំចំនួន ១វគ្គ(មន្ត្រីបុគ្គលិកសិក្សា ១១រូប) សិក្សាភាសាអង់គ្លេសនៅមជ្ឈមណ្ឌល អូស្ត្រាលីសម្រាប់ការបណ្តុះបណ្តាល (ACE) ចំនួន ១២រូប និងសិក្ខាសាលាវគ្គបណ្តុះបណ្តាលនិងកិច្ចប្រជុំផ្សេងៗតាមការអញ្ជើញពីបណ្តាក្រសួង-ស្ថាប័ននានាចំនួន ២៩លើក (មន្ត្រីបុគ្គលិកចូលរួម ៥៥រូប) និងបានរៀបចំប្រឡងឆ្លងចូលក្របខ័ណ្ឌហើយមានមន្ត្រី ២៩រូប ជាប់ជាស្ថាពរក្នុងក្របខ័ណ្ឌក្រមការ ។

#### ខ- ការងារបណ្តុះបណ្តាលក្រៅប្រទេស

ធនាគារជាតិនៃកម្ពុជាបានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេសតាមរយៈសិក្ខាសាលាចំនួន ៩៨លើក (មន្ត្រីបុគ្គលិកចូលរួម ១៥៧រូប) ទស្សនកិច្ចសិក្សាចំនួន ១០លើក (មន្ត្រីបុគ្គលិកចូលរួម ២៨រូប) វគ្គសិក្សារយៈពេលខ្លីចំនួន ៣៥លើក (មន្ត្រីបុគ្គលិកចូលរួម ៧៨រូប) វគ្គសិក្សារយៈពេលវែងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ចំនួន៨លើក នៅប្រទេស ញូហ្សេឡែន អូស្ត្រាលី និងជប៉ុន(មន្ត្រីបុគ្គលិកចូលរួម ១០រូប) និងកិច្ចប្រជុំនានាចំនួន ៦៦លើក (មន្ត្រីបុគ្គលិកចូលរួម ១៦៧រូប) ។ វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំ ទាំងនេះត្រូវបានអញ្ជើញនិងឧបត្ថម្ភដោយប្រទេសនិងស្ថាប័នអន្តរជាតិដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារកណ្តាលម៉ាឡេស៊ី ធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលឥណ្ឌា រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មជ្ឈមណ្ឌលស៊ាសិន ធនាគារកណ្តាលសាធារណរដ្ឋឆែក ធនាគារ

កណ្តាលអាឡឺម៉ង់ រដ្ឋាភិបាលអូស្រ្តាលី ក្រសួងសេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ី ធនាគារកណ្តាលថៃ ធនាគារកណ្តាលលុចហ្សំបួរ អាស៊ាន និងស្ថាប័នផ្សេងៗទៀត ។

## ៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

### ៣.១- ការងារសវនកម្មផ្ទៃក្នុង

អនុលោមតាមផែនការឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបណ្តាអង្គភាពក្រោមឱវាទតាមរយៈការធ្វើសវនកម្ម និងចេញផ្សាយរបាយការណ៍សវនកម្មសម្រេចជូននាយកដ្ឋាននៅទីស្នាក់ការកណ្តាលដែលរួមមាន៖ នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ នាយកដ្ឋានប្រតិបត្តិការ ខុទ្ទកាល័យ ព្រមទាំងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តដែលរួមមាន៖ ខេត្តស្វាយរៀង កំពត តាកែវ ក្រចេះ កំពង់ឆ្នាំង ពោធិ៍សាត់ ព្រៃវែង ស្ទឹងត្រែង សៀមរាប និងកំពង់ចាម ដោយបានផ្តល់អនុសាសន៍នានាសម្រាប់កែលម្អចំណុចខ្វះខាតមួយចំនួន សំដៅកាត់បន្ថយហានិភ័យដែលអាចកើតឡើងជាយថាហេតុ ។ ទន្ទឹមនេះ សវនករបានដំណើរការចុះពិនិត្យតាមដានការអនុវត្តអនុសាសន៍ពាក់ព័ន្ធនឹងនីតិវិធីនៃការគ្រប់គ្រងសាច់ប្រាក់ ការចំណាយផ្ទៃក្នុងនិងការគ្រប់គ្រងអង្គភាព នៅនាយកដ្ឋានរោងពុម្ព សាខាធនាគារជាតិនៃកម្ពុជារាជធានីភ្នំពេញ ខេត្តព្រះសីហនុ កំពង់ចាម បាត់ដំបង ស្វាយរៀង កំពង់ឆ្នាំង បន្ទាយមានជ័យ កំពត តាកែវ ក្រចេះ និងរតនគិរី ក្នុងគោលបំណងធានាថាសវនដ្ឋានបាននិងកំពុងចាត់វិធានការ កែតម្រូវដើម្បីអនុវត្តបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រៅពីការងារសវនកម្ម សវនករបានចូលរួមក្នុងការពិនិត្យផ្ទៀងផ្ទាត់លើតារាងអត្រាការប្រាក់ របាយការណ៍ស្តីពីការទិញ-លក់ប្រាក់ដុល្លារអាមេរិក ស្ថិតិរូបិយវត្ថុប្រចាំខែ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែ ទុនបម្រុងអន្តរជាតិ និងស្ថិតិជញ្ជីងទូទាត់របស់នាយកដ្ឋានស្ថិតិ សម្រាប់ផ្ញើជូនមូលនិធិរូបិយវត្ថុអន្តរជាតិ ។

### ៣.២- ការងារអធិការកិច្ច

សាខាធនាគារជាតិនៃកម្ពុជាចំនួន១៥ ត្រូវបានចុះពង្រឹងការងារនិងធ្វើអធិការកិច្ច ដោយផ្តោតជាសំខាន់លើការធានាសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តតាមរាល់សេចក្តីណែនាំនានារបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងពង្រឹងគុណវុឌ្ឍិនិងវិន័យការងារមន្ត្រីបុគ្គលិកនៅតាមសាខាឲ្យកាន់តែប្រសើរ ។ ទន្ទឹមនេះការត្រួតពិនិត្យលើឯកសារក៏បានដំណើរការជាប្រចាំ តាមរយៈរបាយការណ៍ប្រចាំខែរបស់បណ្តានាយកដ្ឋាននៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជា ដោយបានពិនិត្យឡើងវិញលើការអនុវត្តតាមមុខងារ-ភារកិច្ច និងផ្ទៀងផ្ទាត់ទិន្នន័យរបស់បណ្តាអង្គភាពពាក់ព័ន្ធ ដើម្បីរកឲ្យឃើញភាពត្រឹមត្រូវប្រាកដប្រជា ។

## ៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ ឲ្យកាន់តែមានប្រសិទ្ធភាព និងបន្តតាមដានការអនុវត្តកម្មវិធីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន Core Banking នៅតាមសាខារាជធានី-ខេត្ត ព្រមទាំងបន្តបណ្តុះបណ្តាលនិងផ្គត់ផ្គង់ធនធានមនុស្សបន្ថែមទៀត ដើម្បីពង្រឹងការអនុវត្តប្រព័ន្ធនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ។ ដោយឡែក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបន្តសាកល្បងជំហានទី៣ លើការគ្រប់គ្រងចំណូល-ចំណាយ

ថវិការដ្ឋ ដោយបានបើកគណនីប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋនៅធនាគារអេស៊ីលីដា និងធនាគារកាណាឌីយ៉ា រួមមាន៖ រាជធានីភ្នំពេញ កំពង់ធំ ពោធិ៍សាត់ កំពត ក្រចេះ និងរតនគិរី ខណៈដែលបានអនុញ្ញាតជាគោលការណ៍ឲ្យមន្ទីរ-អង្គភាពជំនាញនិងរតនាគាររាជធានី-ខេត្តទាំងនេះ បិទគណនីនៅសាខាធនាគារជាតិនៃកម្ពុជា ។

ទន្ទឹមនេះដែរ សាខាធនាគារជាតិនៃកម្ពុជាក៏បានបើកគណនីប្រាក់បញ្ញើឲ្យក្រុង ស្រុក ខណ្ឌចំណុះខេត្តទាំង៦ មានខេត្តព្រៃវែង ស្វាយរៀង តាកែវ កំពង់ឆ្នាំង កំពង់ស្ពឺ និងប៉ៃលិន តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឲ្យក្រុង ស្រុក ខណ្ឌចំណុះខេត្តខាងលើអាចដំណើរការបើកប្រាក់បៀវត្ស ប្រាក់បំណាច់ និងលាភការផ្សេងៗ និងបានសម្រួលដល់ការទទួលចំណូលជាប្រាក់ដុល្លាររបស់មន្ទីរ អង្គភាព សាលាខេត្ត និងក្រុង ស្រុក ចំណុះឲ្យខេត្ត ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និងបាត់ដំបងដែលបម្រើសេវាឲ្យរតនាគារខេត្តប៉ៃលិន ។

## III- ទំនាក់ទំនងអន្តរជាតិ

### ១- ទំនាក់ទំនងពហុភាគី

#### ១.១- មូលនិធិរូបិយវត្ថុអន្តរជាតិ

មូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញទស្សនកិច្ចនៅធនាគារជាតិនៃកម្ពុជាចំនួន ៥ លើក៖

លើកទី១ ចាប់ពីថ្ងៃទី២៣ ខែមេសា ដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២ ស្តីពីការងារបច្ចេកទេសជាមួយនាយកដ្ឋានស្ថិតិ ក្នុងគោលបំណងពិភាក្សា និងតាមដានអនុសាសន៍ និងផែនការសកម្មភាពដែលរៀបចំឡើងដោយក្រុមបេសកកម្មនៅឆ្នាំ២០១០ ពាក់ព័ន្ធនឹងការពង្រឹង និងចងក្រងស្ថិតិជញ្ជីងទូទាត់ ព្រមទាំងស្ថានភាពវិនិយោគអន្តរជាតិ ឲ្យស្របតាមរូបមន្តនៃការចងក្រងស្ថិតិជញ្ជីងទូទាត់លើកទី៦ (BPM6) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

លើកទី២ ចាប់ពីថ្ងៃទី២៣-២៩ ខែឧសភា ឆ្នាំ២០១២ ស្តីពី ស្ថានភាពសេដ្ឋកិច្ច និងការពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដែលមានគោលបំណងផ្តោតទៅលើ (១) ស្ថានភាពរូបិយវត្ថុបច្ចុប្បន្ន និងការព្យាករស្ថានភាពរូបិយវត្ថុអនាគត (២) ទិដ្ឋភាពនៃការគរពូនទុនបម្រុងអន្តរជាតិឆ្នាំ២០១២-២០១៣ (៣) ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១២-២០១៣ និង (៤) ស្ថានភាពបច្ចុប្បន្ននៃក្របខ័ណ្ឌព្យាករសន្ទនីយភាព នៃប្រព័ន្ធធនាគារ ។

លើកទី៣ ជាបេសកកម្មប្រចាំគ្រានៃកិច្ចពិភាក្សាមាត្រាទី IV ចាប់ពីថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២ ដើម្បីបន្តតាមដានការវិវត្ត និងវិភាគអំពីស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា។

លើកទី៤ ក្នុងឱកាសដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ាន ពីថ្ងៃទី១៨-២០ ខែវិច្ឆិកា ឆ្នាំ២០១២ ឯកឧត្តម Naoyuki Shinohara អនុប្រធាន IMF បានដឹកនាំគណៈប្រតិភូ IMF មកចូលរួមកិច្ចប្រជុំកំពូលនេះ ។ សូមបញ្ជាក់ផងដែរថា ឯកឧត្តម Naoyuki Shinohara បានមកបំពេញទស្សនកិច្ចនៅកម្ពុជាម្តងរួចមកហើយកាលពីថ្ងៃទី២៦-៣០ ខែមីនា ឆ្នាំ២០១២ ដើម្បីចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន (ACGM) លើកទី៨ កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន (AFMM) លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ ។

លើកទី៥ នៅថ្ងៃទី៣-១៤ ខែធ្នូ ឆ្នាំ២០១២ ក្រុមបេសកកម្មទីផ្សាររូបិយវត្ថុនិងដើមទុនរបស់ IMF (IMF MCM) បានធ្វើទស្សនកិច្ចនៅកម្ពុជាផងដែរ ក្នុងគោលបំណងស្វែងយល់ពីបញ្ហានានា និងវឌ្ឍនភាពទីផ្សារនិងប្រតិបត្តិការប្តូរប្រាក់នៅកម្ពុជា ។

**១.២- ធនាគារអភិវឌ្ឍន៍អាស៊ី**

ធនាគារអភិវឌ្ឍន៍អាស៊ីបានចូលរួមចំណែកដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍន៍វិស័យ ហិរញ្ញវត្ថុនៅកម្ពុជា ។ ស្ថិតនៅក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជា រួមជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម គណៈកម្មការមូលបត្រកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ផ្សេងទៀត បានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវឯកសារបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០ ប្រកបដោយជោគជ័យ កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ ។ ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្រ នេះ កម្មវិធីឥណទានសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុជំហានទី III (FSPL III) ត្រូវបានរៀបចំឡើង ដោយបែងចែកជាបីអនុកម្មវិធីសម្រាប់រយៈពេល ៣ឆ្នាំ (២០១១-២០១៣) ដែលក្នុងមួយអនុកម្មវិធីមានទឹកប្រាក់ ១៥ លានដុល្លារអាមេរិក ។ អនុកម្មវិធីទី១ ត្រូវបានបញ្ចប់នៅឆ្នាំ២០១១ ចំណែកអនុកម្មវិធីទី២ មានផែនការ សកម្មភាពចំនួន ៣២ ដែលក្នុងនោះ ផែនការសកម្មភាព ១២ ពាក់ព័ន្ធនឹងធនាគារជាតិនៃកម្ពុជា ដោយក្រសោបការងារសំខាន់ៗដូចជា ការធ្វើបច្ចុប្បន្នកម្មក្របខ័ណ្ឌច្បាប់ ការពង្រឹងវិធានការដើម្បីលើកកម្ពស់វិស័យហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ការពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដោយប្រុងប្រយ័ត្ន និងការធ្វើទំនើបកម្មប្រព័ន្ធផាត់ទាត់ជាតិ ។ ផែនការសកម្មភាពនៅក្នុងអនុកម្មវិធីទី២ ត្រូវបំពេញបញ្ចប់ នៅចុងឆ្នាំ២០១២ នេះ ។

**១.៣- អាស៊ាន និងអាស៊ាន+៣**

ក្នុងនាមជាប្រធានកិច្ចប្រជុំអាស៊ាននៅឆ្នាំនេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំយ៉ាងខ្លាំងក្នុងការជំរុញរបៀបវារៈនៃការកសាងសហគមន៍អាស៊ាន និងពង្រឹងសេដ្ឋកិច្ច ទំនាក់ទំនងនយោបាយនិងសង្គមជាមួយដៃគូពិភាក្សាអាស៊ាន ។

ក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ កិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុនិងធនាគារ ដោយបានដើរតួនាទីជាប្រធានប្តូរវេនអាស៊ាន និងបានធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំអាស៊ាននានា ជាពិសេស កិច្ចប្រជុំកំពូលអាស៊ានដែលបានប្រព្រឹត្តទៅកាលពីខែវិច្ឆិកា ។ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកយ៉ាងសកម្មក្នុងការជំរុញសមាហរណកម្មផ្នែកហិរញ្ញវត្ថុ ដែលជាអាទិភាពចម្បងមួយរបស់អាស៊ាន ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានទទួលធ្វើជាម្ចាស់ផ្ទះ និងជាប្រធានដឹកនាំកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៨ កាលពីថ្ងៃទី២៩ ខែមីនា

និងកិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាលនិងអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី២០ នៅថ្ងៃទី២៦ ខែមីនា ហើយបាន ចូលរួមកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀតទាំងក្នុងនិងក្រៅប្រទេស ។

ជាលើកដំបូងហើយដែលរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលនៃប្រទេសអាស៊ាន រួមជាមួយ ចិន ជប៉ុន និងកូរ៉េ បានជួបប្រជុំគ្នាលើកទី១៥ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។ កិច្ចប្រជុំនេះផ្តល់ជាវេទិកា ចែករំលែកនូវជំនាញនិងបទពិសោធន៍ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងតំបន់ ។

ក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ប្រទេសជាសមាជិកបានចូលរួមយ៉ាងសកម្មក្នុងការជំរុញ សមាហរណកម្មហិរញ្ញវត្ថុអាស៊ានតាមរយៈការអភិវឌ្ឍទីផ្សារទុន សេរីភាវូបនីយកម្មគណនីដើមទុន សេរីភាវូប-នីយកម្មសេវាហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់និងផាត់ទាត់ សមាហរណកម្មវិស័យធនាគារ និងការកសាងសមត្ថភាព ធនធានមនុស្ស ស្របតាមគោលដៅសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ ។ លើសពីនេះ គណៈកម្មការ ជាន់ខ្ពស់ (SLC) បានជួបប្រជុំជាប្រចាំជាមួយប្រធានក្រុមការងារពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីលទ្ធផលនិងការ អនុវត្តបង្គោលចរ (Milestones) សម្រាប់សមាហរណកម្មអាស៊ាន សំដៅជំរុញសមាហរណកម្មលើវិស័យ អាទិភាពទាំងនេះឲ្យកាន់តែមានប្រសិទ្ធភាព ។

ក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ ប្រទេសជាសមាជិកបានឯកភាពគ្នាក្នុងការបង្កើនទំហំ សរុបនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ពី១២០ពាន់លាន ទៅ ២៤០ពាន់លានដុល្លារអាមេរិក ហើយបច្ចុប្បន្នកំពុងធ្វើការកែសម្រួលលក្ខន្តិកបច្ចេកទេសមួយចំនួននៅក្នុងកិច្ចព្រមព្រៀងនេះ ។ ចំពោះវឌ្ឍនភាព នៃការបើកគណនីរូបិយវត្ថុជាតិ ប្រទេសសមាជិកមួយចំនួនបានបើកគណនីរវាងគ្នារួចរាល់ហើយ ក្នុងនោះការ បើកគណនីរវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលកូរ៉េក៏បានបញ្ចប់ផងដែរ ។ ក្រៅពីនេះ ការិយាល័យ ស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ក៏មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ផងដែរ រួមមាន ការរៀបចំ លក្ខន្តិកគតិយុត្តរបស់ការិយាល័យនេះឲ្យទៅជាស្ថាប័នអន្តរជាតិ ការរៀបចំសេចក្តីព្រាងនៃសន្ធិសញ្ញា (AMRO Treaty) ការរៀបចំគណៈកម្មាធិការថវិកា និងការរៀបចំតារាងសូចនាករតាមដានសម្រាប់យន្តការទប់ស្កាត់ វិបត្តិ (CPF) ។ ទន្ទឹមនេះ ផែនទីគោចរថ្មីសម្រាប់គំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ាន+៣ (ABMI) ត្រូវបាន អនុម័តជាឯកឆ័ន្ទ ដោយប្រទេសសមាជិកអាស៊ាន+៣ ក្នុងគោលបំណងអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណ ក្នុងតំបន់ឲ្យ កាន់តែទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព តាមរយៈការកែនប្រមូលសន្សំក្នុងតំបន់ ដើម្បីគាំទ្រការ វិនិយោគក្នុងតំបន់វិញ ។ លើសពីនេះ យន្តការធានាលើឥណទាននិងវិនិយោគ (CGIF) ដែលមានដើមទុនសរុប ចំនួន ៧០០លានដុល្លារអាមេរិក ត្រូវបានបញ្ចប់ដំណាក់កាលទី១ ប្រកបដោយជោគជ័យ និងត្រៀមអនុវត្ត ដំណាក់កាលទី២ក្នុងពេលឆាប់ៗខាងមុខនេះ ។ គោលបំណងរបស់ CGIF គឺដើម្បីអភិវឌ្ឍ ទីផ្សារសញ្ញាប័ណ្ណ ក្នុងតំបន់តាមរយៈការផ្តល់ការធានាដល់ប័ណ្ណបំណុលរបស់សហគ្រាសក្នុងតំបន់ដែលចេញផ្សាយជារូបិយវត្ថុ ជាតិ ។ ទន្ទឹមនឹងនេះ វេទិកាទីផ្សារសញ្ញាប័ណ្ណអាស៊ាន+៣ ក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីជួយដល់ការ សម្របសម្រួលស្តង់ដារនិងបទប្បញ្ញត្តិទាក់ទងនឹងប្រតិបត្តិការសញ្ញាប័ណ្ណឆ្លងដែនក្នុងតំបន់ ។

**១.៤- មជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ ( ស៊ាសិន - SEACEN )**

ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលស៊ាសិន កាន់តែជិតស្និទ្ធ

ក្នុងទិសដៅជំរុញការសិក្សាស្រាវជ្រាវនិងបណ្តុះបណ្តាលធនធានមនុស្សរបស់ខ្លួន ស្របតាមនិន្នាការនៃការអភិវឌ្ឍក្នុងតំបន់ ។ ដោយមជ្ឈមណ្ឌលស៊ាសិនបានធ្វើការផ្លាស់ប្តូរឆ្នាំប្រតិបត្តិការ ពីខែឧសភា-មេសា មក ខែមករា-ធ្នូ នៅឆ្នាំ២០១២នេះ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលធនាគារកណ្តាលស៊ាសិនចំនួនពីរលើក (លើកទី៣១ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ និងលើកទី៣២ នៅទីក្រុងអ៊ូឡានបាតា ប្រទេសម៉ុងហ្គោលី) និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិមជ្ឈមណ្ឌលស៊ាសិន (EXCO) ចំនួនពីរលើក (លើកទី១០ នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា និងលើកទី១១ នៅទីក្រុងប៊ូសាន ប្រទេសកូរ៉េ) ។ ធនាគារជាតិនៃកម្ពុជាបានទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាកម្រិតខ្ពស់លើកទី៣ ថ្នាក់ទេសាភិបាលរងស៊ាសិន ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលមន្ត្រីក្នុងការងារស្ថិរភាពហិរញ្ញវត្ថុ និងការងារត្រួតពិនិត្យធនាគារ ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលារបស់មជ្ឈមណ្ឌលស៊ាសិនសហការជាមួយមជ្ឈមណ្ឌលសិក្សាធនាគារកណ្តាលអង់គ្លេសលើកទី៥ ស្តីពី "ការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច" ។ ព្រមជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូនមន្ត្រីបុគ្គលិកឲ្យចូលរួមការស្រាវជ្រាវ កិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលនានារបស់មជ្ឈមណ្ឌលស៊ាសិន ។

**១.៥- សមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង** (**ហ្វ្រង់កូហ្វូន** - Francophone)

កិច្ចសហប្រតិបត្តិការជាមួយបណ្តាសមាជិកហ្វ្រង់កូហ្វូន ក៏ត្រូវបានបន្តពង្រឹងជាប្រចាំ ។ គណៈប្រតិភូជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជា ដែលដឹកនាំដោយឯកឧត្តមទេសាភិបាល បានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង លើកទី១៩ (ហ្វ្រង់កូហ្វូន) ក្រោមប្រធានបទ "ធនាគារកណ្តាល : តួនាទីនិងបេសកកម្មថ្មី នៅក្នុងបរិបទដែលស្ថានភាពសេដ្ឋកិច្ចពិភពលោកកំពុងប្រែប្រួល" ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣-២៦ ខែឧសភា ឆ្នាំ២០១២ នៅប្រទេសម៉ូរីស ។ វេទិកានៃកិច្ចប្រជុំប្រចាំឆ្នាំនេះ បានផ្តល់ឱកាសឲ្យទេសាភិបាលជាសមាជិកជួបពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ព្រមទាំងជំរុញកិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការដោះស្រាយបញ្ហាប្រឈមថ្មីៗចំពោះធនាគារកណ្តាល ។

**១.៦- សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក** (APRACA)

ការចូលជាសមាជិកសមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិកនាឆ្នាំ១៩៩៩ បានផ្តល់ឱកាសជាច្រើនដល់ធនាគារជាតិនៃកម្ពុជាក្នុងការចូលរួមសន្និសីទ វេទិកាពិភាក្សា និងការបណ្តុះបណ្តាលជាច្រើន នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។ កាលពីថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាមានកិត្តិយសធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទថ្នាក់តំបន់ស្តីពី "ការពង្រឹងសមត្ថភាពកសិករខ្នាតតូចតាមរយៈភាពច្នៃប្រឌិតនៃហិរញ្ញវត្ថុជនបទ" ដែលមានការចូលរួមពីភ្ញៀវជាតិនិងអន្តរជាតិ មកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ប្រមាណ ២០០ នាក់ ។ ជាមួយគ្នានេះ ក៏មានការរៀបចំកិច្ចប្រជុំគណៈកម្មការប្រតិបត្តិលើកទី ៦១ និងមហាសន្និបាតលើកទី ១៨ របស់សមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិកផងដែរ ។

តាមការអនុម័តរបស់មហាសន្និបាតលើកទី ១៨ របស់សមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិក ធនាគារជាតិនៃកម្ពុជាត្រូវបានជ្រើសតាំងជាប្រធានរបស់សមាគមនេះ ក្នុងអាណត្តិរយៈពេល២ឆ្នាំ គិតចាប់ពីខែមិថុនា ឆ្នាំ២០១២ ដល់ខែឧសភា ឆ្នាំ២០១៤ ។

### ១.៧- ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់អាស៊ី ( Financial Stability Board Regional Consultative Group for Asia-FSBR )

អនុវត្តតាមសេចក្តីសម្រេចរបស់សន្និសីទកំពូលនៃក្រុមប្រទេស G20 កាលពីខែមិថុនា ឆ្នាំ២០១០ ក្រុមប្រឹក្សាស្ថិរភាពហិរញ្ញវត្ថុអន្តរជាតិ (FSB) បានរៀបចំក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់ (FSB-RCG) ជាផ្លូវការ នៅខែវិច្ឆិកា ឆ្នាំ២០១០ ដោយបានចែកជា ៦តំបន់ រួមទាំងតំបន់អាស៊ី ។ ការបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់នេះ ដើម្បីធានាការអនុវត្តតាមធម្មនុញ្ញ (Charter) របស់ក្រុមប្រឹក្សាស្ថិរភាពហិរញ្ញវត្ថុអន្តរជាតិ និងធ្វើជាវេទិកាឲ្យអាជ្ញាធរហិរញ្ញវត្ថុរបស់ប្រទេសជាសមាជិក និងមិនមែនសមាជិកនៃក្រុមប្រឹក្សាស្ថិរភាពហិរញ្ញវត្ថុអន្តរជាតិជួបប្រជុំ ផ្លាស់ប្តូរយោបល់ បទពិសោធន៍ និងស្វែងយល់ពីភាពផុយស្រួយនិងផលវិបាកនៃវិបត្តិ និងធ្វើកំណែទម្រង់គោលនយោបាយ បទប្បញ្ញត្តិនានា ដែលអាចប៉ះពាល់មកលើប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ហើយនេះក៏ជាគំនិតផ្តួចផ្តើមក្នុងគោលបំណងថែរក្សា និងគាំទ្រស្ថិរភាពហិរញ្ញវត្ថុក្នុងតំបន់ ក៏ដូចជាស្ថិរភាពហិរញ្ញវត្ថុសកលដែរ ។

ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់អាស៊ី (FSBR) ត្រូវបានរៀបចំឡើង និងដឹកនាំដោយសហប្រធានគឺ ធនាគារកណ្តាលនៃសាធារណរដ្ឋកូរ៉េនិងធនាគារកណ្តាលម៉ាឡេស៊ី សម្រាប់អាណត្តិឆ្នាំ២០១១-២០១២ និងមានសមាជិកចំនួន ១៦ ប្រទេស ដែលជាតំណាងធនាគារកណ្តាល អាជ្ញាធរត្រួតពិនិត្យ និងក្រសួងហិរញ្ញវត្ថុ រួមមាន ប្រទេសអូស្ត្រាលី ចិន ហុងកុង ឥណ្ឌា ឥណ្ឌូនេស៊ី ជប៉ុន សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ញូវហ្សេឡែន ហ្វីលីពីន ប៉ាគីស្ថាន សិង្ហបុរី ស្រីលង្កា ថៃ វៀតណាម និងកម្ពុជា ។ ក្នុងនាមជាសមាជិក ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមក្នុងកិច្ចប្រជុំចង្អៀតប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់ចំនួនបីលើករួចមកហើយ ។

កិច្ចប្រជុំរបស់ក្រុមពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុអាស៊ីកន្លងទៅ បានផ្តោតសំខាន់លើបញ្ហាប្រឈម និងការអនុវត្តគោលនយោបាយកំណែទម្រង់ហិរញ្ញវត្ថុសកល និងផលប៉ះពាល់លើប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសកំពុងងើបឡើង រួមមាន ១)- កំណែទម្រង់ក្របខ័ណ្ឌមូលធនបាសែល III ២)- ក្របខ័ណ្ឌសន្ទនីយភាព ៣)-ក្របខ័ណ្ឌគោលនយោបាយគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសំខាន់ៗក្នុងពិភពលោក (G-SIFI) និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសំខាន់ៗក្នុងស្រុក (D-SIFI) ៤)- កំណែទម្រង់ឧបករណ៍និស្សន្ទវត្ថុនៃទីផ្សារលែងបញ្ជរ (OTC) និង ៥)- កំណែទម្រង់ថ្នាក់ជាតិនិងតំបន់ផ្សេងទៀត ។

តាមការចូលរួមនេះ ធនាគារជាតិនៃកម្ពុជាទទួលបានបទពិសោធន៍ និងទ្រឹស្តីមួយចំនួនសម្រាប់ពង្រឹងយន្តការអនុវត្តន៍ប្រព័ន្ធធនាគារស្រមោល (Shadow Banking) និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសំខាន់ៗក្នុងស្រុក ។ ប៉ុន្តែ ដោយសារតែប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាពុំទាន់មានលក្ខណៈស្មុគស្មាញ ហើយទីផ្សារទុនទើបចាប់ផ្តើម ដូចនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រុមពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំ

តំបន់អាស៊ីដើម្បីសិក្សានិងស្វែងយល់ពីសកម្មភាពនៃធនាគារស្រមោលនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសំខាន់ៗ ក្នុងស្រុក ក្នុងទិសដៅរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុក្នុងប្រទេសនិងតំបន់ ។

**២- ទំនាក់ទំនងទ្វេភាគី**

ទន្ទឹមនឹងសហប្រតិបត្តិការពហុភាគី ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់លើការកសាង និងពង្រឹងនូវទំនាក់ទំនងទ្វេភាគីជាមួយបណ្តាធនាគារកណ្តាល និងបណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយចំនួនទៀត ដើម្បីសម្រេចបាននូវគោលដៅរួមគឺ ការពង្រឹងប្រព័ន្ធធនាគារជាទូទៅនៅក្នុងបរិស្ថានសេដ្ឋកិច្ចពិភពលោកមួយដែលកាន់តែមានលក្ខណៈជាសកល ។

ធនាគារជាតិនៃកម្ពុជាតែងតែបានទទួលជំនួយបច្ចេកទេសពីធនាគារកណ្តាលអាឡឺម៉ង់ ក្នុងរូបភាពជាកិច្ចសហប្រតិបត្តិការទ្វេភាគីលើផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជា សំដៅអភិវឌ្ឍប្រព័ន្ធធនាគារឲ្យកាន់តែរឹងមាំថែមទៀត ។ ជាក់ស្តែង ក្នុងឆ្នាំនេះ ធនាគារកណ្តាលអាឡឺម៉ង់បានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាចំនួន ៣លើក ៖ លើកទី១ នៅថ្ងៃទី២១-២៤ ខែកុម្ភៈ ឆ្នាំ២០១២ លើប្រធានបទស្តីពី "ការរក្សាស្ថិរភាពហិរញ្ញវត្ថុក្នុងបរិបទសេដ្ឋកិច្ចទំហំតូចនិងបើកចំហ" លើកទី២ នៅថ្ងៃទី១៧-១៩ខែកក្កដា ឆ្នាំ២០១២ លើប្រធានបទ ការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុនៅក្រោយពេលវិបត្តិ និងលើកទី៣ ចាប់ផ្តើមពីថ្ងៃទី១១-១៥ ខែធ្នូ ឆ្នាំ២០១២ លើប្រធានបទស្តីពី "ការត្រួតពិនិត្យធនាគារ" ។

ជាមួយគ្នានេះដែរ កិច្ចសហប្រតិបត្តិការទ្វេភាគីត្រូវបានពង្រឹងថែមទៀតជាមួយធនាគាររដ្ឋវៀតណាម តាមរយៈកិច្ចប្រជុំទ្វេភាគី និងការចុះហត្ថលេខាលើអនុស្សរណៈយល់គ្នាចំនួនពីរ គឺ ១- អនុស្សរណៈយល់គ្នាស្តីពីការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង ២- អនុស្សរណៈយល់គ្នាស្តីពីការបណ្តុះបណ្តាល ដែលបានធ្វើនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ។ ជាងនេះទៀត សាកលវិទ្យាល័យធនាគារទីក្រុងហូជីមិញបានរៀបចំការបណ្តុះបណ្តាលវគ្គសុក្រឹតការលើប្រធានបទ "គណនេយ្យនិងសវនកម្មនៃគ្រឹះស្ថានធនាគារ" ចាប់ពីថ្ងៃទី១-៥ ខែតុលា ឆ្នាំ២០១២ នៅធនាគារជាតិនៃកម្ពុជា ។ ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ កិច្ចប្រជុំទ្វេភាគី រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧-២៩ ខែកក្កដា ឆ្នាំ២០១២ នៅខេត្តហួហ៊ីន ប្រទេសថៃ ។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលឡាវក៏ត្រូវបានពង្រឹងថែមមួយកម្រិតទៀតតាមរយៈកិច្ចជួបពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់ទៅលើស្ថានភាពសេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយរូបិយវត្ថុរវាងប្រទេសទាំងពីរ នៅថ្ងៃទី២៦-២៨ ខែធ្នូ ឆ្នាំ២០១២ នៅប្រទេសឡាវ ។

ចំណែកអាជ្ញាធររូបិយវត្ថុសិង្ហបុរីវិញ បានពង្រឹងទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា តាមរយៈកិច្ចប្រជុំពិភាក្សាការងារជាលក្ខណៈទ្វេភាគី កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ ។ ក្រៅពីនេះ ថ្នាក់ដឹកនាំជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជាបានចូលរួមសន្និសីទអន្តរជាតិប្រចាំឆ្នាំ២០១២ របស់ធនាគារ

កណ្តាលកូរ៉េ ក្រោមប្រធានបទ "គោលនយោបាយរូបិយវត្ថុ និងម៉ាក្រូប្រុងប្រយ័ត្ននៅក្រោយពេលវិបត្តិ" កាលពីថ្ងៃទី១៤-១៥ ខែមិថុនា ឆ្នាំ២០១២ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ ។

ម៉្យាងវិញទៀត ក្នុងឆ្នាំ២០១២ នេះ កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយរតនាគារសហរដ្ឋអាមេរិក ក្រោមរូបភាពជាជំនួយបច្ចេកទេស ត្រូវបានធ្វើឡើងតាមរយៈការផ្តល់មន្ត្រីទីប្រឹក្សាបច្ចេកទេស ២រូប ដល់ធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងសមត្ថភាពមន្ត្រីនៅអគ្គនាយកដ្ឋានត្រួតពិនិត្យ និងអគ្គនាយកដ្ឋានបច្ចេកទេស ។

## សន្និដ្ឋាន

ទោះបីជាស្ថិតក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកបន្តងើបឡើងក្នុងល្បឿនយឺតជាងឆ្នាំកន្លងទៅ និងមានភាពមិនប្រាកដប្រជាក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជាបានរក្សាអត្រាកំណើនខ្ពស់គួរឲ្យកត់សម្គាល់ ដែលគាំទ្រជាចម្បងដោយភាពរឹងមាំនៃការនាំចេញ កំណើននៃវិស័យទេសចរណ៍ និងវិស័យកសិកម្ម ព្រមទាំងការងើបឡើងនៃវិស័យអចលនទ្រព្យ ។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុនិងត្រួតពិនិត្យប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការគាំទ្រគោលនយោបាយជំរុញកំណើនប្រកបដោយភាពរឹងមាំនិងចីរភាព តាមរយៈការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច អភិវឌ្ឍនិងពង្រឹងស្ថិរភាពប្រព័ន្ធធនាគារ ស្របតាមផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន និងទន់ភ្លន់ប្រកបដោយប្រសិទ្ធភាព ហើយបានរក្សាអត្រាអតិផរណាឲ្យស្ថិតនៅកម្រិតទាប ។ ទន្ទឹមនេះ ការផ្គត់ផ្គង់បរិមាណរូបិយវត្ថុក្នុងកម្រិតសមស្រប បានជួយសម្រួលដល់កំណើនសកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយសម្ពាធអតិផរណា ។ ម្យ៉ាងទៀត ការបន្តអនុវត្តនយោបាយប្តូរប្រាក់ក្រោមរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង នៅតែជាគោលនយោបាយសមស្របក្នុងស្ថានភាពដែលសេដ្ឋកិច្ចកម្ពុជាមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើរូបិយវត្ថុជាតិ ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សំដៅជំរុញការប្រើប្រាស់ប្រាក់រៀលសម្រាប់រយៈពេលខ្លី និងមធ្យម ។

នៅក្នុងស្ថានភាពដែលទីផ្សារហិរញ្ញវត្ថុពិភពលោកពិសេសនៅតំបន់អឺរ៉ុប នៅមានភាពតានតឹងនិងមិនប្រាកដប្រជា ការគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា ត្រូវបានធ្វើឡើងដោយការប្រុងប្រយ័ត្នផ្អែកតាមគោលការណ៍សុវត្ថិភាព សន្ទនីយភាព និងការគរពូនចំណូល ។ ជាលទ្ធផល ទុនបម្រុងអន្តរជាតិបានកើនឡើងជាលំដាប់ ហើយបានជួយបម្រើដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងពង្រឹងឲ្យកាន់តែប្រសើរឡើងនូវជំនឿទុកចិត្តរបស់អ្នកវិនិយោគទុនមកលើសេដ្ឋកិច្ចកម្ពុជា ។

ទន្ទឹមនឹងសមិទ្ធផលសម្រេចបានក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច វិស័យធនាគារនៅកម្ពុជាក៏មានស្ថិរភាពល្អប្រសើរ និងមានការរីកចម្រើនគួរជាទីមោទនៈ ទាំងផ្នែកវិសាលភាព និងទំហំប្រតិបត្តិការ ។ ភាពរីកចម្រើននេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈ ១/. កំណើនអន្តរការិយកម្មហិរញ្ញវត្ថុ ជាពិសេស ការកេណ្ឌប្រមូលធនធានទំនេរយកទៅផ្តល់ហិរញ្ញប្បទានដល់វិស័យសេដ្ឋកិច្ចដែលមានសក្តានុពល ដូចជា វិស័យកសិកម្ម ស្របតាមការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាល ២/. ការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុស្របតាមតម្រូវការទីផ្សារ ៣/. ការពង្រីកបណ្តាញគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យកាន់តែទូលំទូលាយក្នុងការផ្តល់សេវាហិរញ្ញវត្ថុទៅដល់សហគ្រាសធនតូចនិងមធ្យម និងប្រជាជននៅតាមតំបន់ដាច់ស្រយាល ៤/. ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុមានការកើនឡើងជាលំដាប់ ដែលគាំទ្រដល់កំណើនសកម្មភាពសេដ្ឋកិច្ចជាតិ ។ សមិទ្ធផលទាំងនេះ ទទួលបានដោយសារកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព តាមរយៈការបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធធនាគារ ការអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិ ទាំងកម្រិតម៉ាក្រូនិងមីក្រូ ការលើកកម្ពស់ប្រសិទ្ធភាពប្រព័ន្ធទូទាត់និងផាត់ទាត់

និងការពង្រឹងប្រតិបត្តិតាមបទប្បញ្ញត្តិជាធរមាន ស្របតាមការរីកចម្រើននៃវិស័យធនាគារ និងតាមស្តង់ដារអន្តរជាតិ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងអភិវឌ្ឍទីផ្សាររូបិយវត្ថុនិងអន្តរធនាគារនៅកម្ពុជា ដែលនឹងបំរើឲ្យកាន់តែប្រសើរឡើងនូវសេចក្តីត្រូវការសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ ដើម្បីធានាបាននូវស្ថិរភាពនិងសុខមាលភាពនៃប្រព័ន្ធធនាគារទាំងមូល ។

ស្របពេលដែលវិស័យធនាគារនិងហិរញ្ញវត្ថុមានការរីកចម្រើនជាលំដាប់ ការពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកគឺជាការងារអាទិភាពចម្បងមួយរបស់ធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងសមត្ថភាពជំនាញ បទពិសោធន៍ និងការផ្ទេរចំណេះដឹងរបស់មន្ត្រីបុគ្គលិក តាមរយៈវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនិងវែង ទាំងនៅក្នុងនិងក្រៅប្រទេស ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានបន្តពង្រឹងនិងពង្រីកសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ជាមួយនឹងធនាគារកណ្តាល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ទាំងក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ ក្នុងគោលដៅអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុកម្ពុជាឲ្យកាន់តែមានប្រសិទ្ធភាព ភាពប្រកួតប្រជែង និងសមាហរណកម្ម ព្រមទាំងបានពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុតំបន់និងអន្តរជាតិ ដើម្បីរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍប្រកបដោយចីរភាព ។

# ខ- ទិសដៅការងារឆ្នាំ២០១៣

## ទិសដៅការងារឆ្នាំ២០១៣

ប្រឈមនឹងវិបត្តិអឺរ៉ុបដែលមិនទាន់ដោះស្រាយរួច និងហានិភ័យផ្សេងៗដែលអាចនាំឲ្យសេដ្ឋកិច្ចធ្លាក់ចុះ ពិភពលោកកំពុងផ្ដោតការយកចិត្តទុកដាក់ទៅលើការអនុវត្តគោលនយោបាយ និងវិធានការនានាដើម្បីស្ដារជំនឿទុកចិត្ត ព្រមទាំងកាត់បន្ថយនិងទប់ស្កាត់ការរីករាលដាលនៃវិបត្តិ ដើម្បីគាំទ្រកំណើនឲ្យមានសន្ទុះឡើងវិញនារយៈពេលខ្លីនិងមធ្យមខាងមុខ ។ ចំពោះប្រទេសអភិវឌ្ឍន៍ គោលនយោបាយជាគន្លឹះដែលចាំបាច់ត្រូវអនុវត្តគឺ ការពង្រឹងវិស័យហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់ការងើបឡើងនៃសេដ្ឋកិច្ច ។ ចំណែកឯនៅប្រទេសកំពុងងើបឡើងនិងកំពុងអភិវឌ្ឍន៍វិញ គោលនយោបាយរយៈពេលខ្លី គឺការឆ្លើយតបឲ្យបានទាន់ពេលវេលា និងសមស្រប ចំពោះការថមថយកំណើនតម្រូវការក្នុងស្រុក និងតម្រូវការរបស់ប្រទេសអភិវឌ្ឍន៍ ។ យោងតាមការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០១៣ ត្រូវរំពឹងថានឹងមានកំណើនលើសឆ្នាំ២០១២ ដោយមានអត្រា ៣,៦% ។

ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជាក៏ត្រូវបានព្យាករដោយសុទិដ្ឋិនិយមផងដែរថា នឹងបន្តមានកំណើនរឹងមាំ ក្នុងរង្វង់ ៧% នៅឆ្នាំ២០១៣ ។ ក្នុងទិសដៅបន្តគាំទ្រ និងពង្រឹងមូលដ្ឋានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជានឹងបន្តជំរុញអភិវឌ្ឍប្រព័ន្ធធនាគារស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០ ព្រមទាំងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់ បង្កើនប្រសិទ្ធភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងប្រុងប្រយ័ត្នដើម្បីរក្សាស្ថិរភាពថ្លៃ ព្រមទាំងជំរុញការប្រើប្រាស់ប្រាក់រៀលឲ្យកាន់តែទូលំទូលាយ ។ ទិសដៅការងារ ចម្បងៗសម្រាប់អនុវត្តនៅឆ្នាំ២០១៣ រួមមាន៖

**១. ការងាររូបិយវត្ថុ** (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ)

| | |
|---|---|
| - រូបិយវត្ថុទូទៅ (M2) | ១៨% |
| - រូបិយវត្ថុក្នុងចរាចរណ៍ | ៧% |
| - ប្រាក់បញ្ញើជារូបិយប័ណ្ណ | ១៩% |
| - ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា | -១៥% |
| - ឥណទានសុទ្ធចំពោះរាជរដ្ឋាភិបាលពីវិស័យឯកជន | -២៧% |
| - ទុនបម្រុងផ្លូវការសុទ្ធ | ១៣% ។ |

**២. ការជំរុញការប្រើប្រាស់ប្រាក់រៀល និងទីផ្សារអន្តរធនាគារ**

- រៀបចំផែនការយុទ្ធសាស្ត្រជំរុញការប្រើប្រាស់ប្រាក់រៀលឲ្យកាន់តែទូលំទូលាយ និង
- រៀបចំចេញផ្សាយវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបាន (NCD) សម្រាប់អភិវឌ្ឍន៍ទីផ្សាររូបិយវត្ថុ និងអន្តរធនាគារ ។

**៣. ការងារវិនិយោគទុនបម្រុងអន្តរជាតិ**

- រៀបចំសេចក្ដីណែនាំការវិនិយោគទុនបម្រុងអន្តរជាតិ និង
- បន្តពង្រឹងសមត្ថភាពដើម្បីបង្កើនប្រសិទ្ធភាពនៃការវិនិយោគ ។

### ៤. ការងារអភិវឌ្ឍន៍ប្រព័ន្ធផាត់ទាត់ជាតិ

- រៀបចំសេចក្តីព្រាងគោលការណ៍សម្រាប់ការទូទាត់តាមទូរស័ព្ទចល័ត ។ គោលការណ៍នេះផ្តោតជាចម្បងលើការការពារអតិថិជន សុវត្ថិភាព មូលនិធិ និងសុវត្ថិភាពសារពាក់ព័ន្ធនឹងបញ្ហាទូទាត់ ។ល។
- រៀបចំកម្រងសទ្ទានុក្រមសម្រាប់ប្រព័ន្ធទូទាត់ ដោយផ្អែកលើឯកសាររបស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS)
- សិក្សាស្រាវជ្រាវនូវច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធនិងសេវាទូទាត់សងប្រាក់របស់ប្រទេសផ្សេងៗក្នុងតំបន់ និង
- សិក្សាគម្រោងអភិវឌ្ឍន៍ប្រព័ន្ធ Shared Switch ។

### ៥. ការងារត្រួតពិនិត្យ

- បន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានឥណទាន ដើម្បីផ្តល់នូវព័ត៌មានបន្ថែមសម្រាប់ការតាមដានលើប្រព័ន្ធធនាគារ
- ជំរុញការកែលម្អប្រព័ន្ធត្រួតពិនិត្យលើឯកសារ (Off-Site Surveillance System) ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ក្នុងការវិភាគភាពរឹងមាំរបស់គ្រឹះស្ថាន
- ពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យផ្អែកលើហានិភ័យ និងមន្ត្រីការិយាល័យឥណទាន
- សិក្សាស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិថ្មី បន្តពិនិត្យនិងកែលម្អប្រកាស និងបទប្បញ្ញត្តិដែលមានស្រាប់បន្ថែមទៀតឲ្យស្របទៅតាមការវិវត្តនៃទីផ្សារស្របតាមស្តង់ដារអន្តរជាតិ និងគោលការណ៍គណៈកម្មការទីក្រុងបាសែល និង
- ពង្រឹងការងារបណ្តុះបណ្តាលផ្ទៃក្នុងសម្រាប់មន្ត្រីបុគ្គលិក ។

### ៦. ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក)

- រៀបចំយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- វាយតម្លៃហានិភ័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ
- សហការជាមួយអាជ្ញាធរអាណាព្យាបាលដើម្បីត្រួតពិនិត្យបុគ្គលរាយការណ៍ និង
- ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់រាយការណ៍ និងវិភាគប្រតិបត្តិការ ។

### ៧. ការងារប្រតិបត្តិការ និងប្រព័ន្ធផាត់ទាត់ជាតិ

- បន្តរៀបចំ និងសាកល្បងប្រព័ន្ធចុះបញ្ជីមូលបត្រ ដើម្បីដំណើរការបោះផ្សាយមូលបត្រ ( NCD ) របស់ធនាគារជាតិនៃកម្ពុជា
- សិក្សាលើការរៀបចំឡើងវិញនូវប្រព័ន្ធចុះបញ្ជីមូលបត្ររបស់រាជរដ្ឋាភិបាល ដើម្បីធានាការអនុវត្តបានពេលមានតម្រូវការ និង
- អនុវត្តកិច្ចដំណើរការផាត់ទាត់តាមប្រព័ន្ធផាត់ទាត់ជាតិ ។

**៨. ការងារបោះផ្សាយ និងឃ្លាំងបេឡា**

- ពង្រឹងការងារបម្រើអតិថិជនក្នុងការបើកសាច់ប្រាក់ និងបង់សាច់ប្រាក់នៅបញ្ជរបេឡាឲ្យបានកាន់តែប្រសើរឡើង
- ពង្រឹងការងារថែរក្សានិងការពារឃ្លាំងប្រាក់
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច រាំងខ្ទប់ចរាចរណ៍ក្រដាសប្រាក់ក្លែងក្លាយ
- សហការជាមួយធនាគារជាដៃគូ ក្នុងការរៀបចំសិក្ខាសាលាស្តីពីការពិនិត្យ និងបង្ការក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ និង
- ពង្រឹងការងារគ្រប់គ្រង និងផ្គត់ផ្គង់ធនបត្រ ។

**៩. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច**

- ធ្វើសវនកម្មនៅនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគណនេយ្យ និងសាខាធនាគារជាតិនៃកម្ពុជា ខេត្តរតនគីរី កោះកុង កំពង់ស្ពឺ បន្ទាយមានជ័យ ស្វាយរៀង និងខេត្តព្រះសីហនុ ព្រមទាំងចុះពិនិត្យតាមដានការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើងក្នុងឆ្នាំ២០១២ និង
- ពង្រឹងការងារ និងធ្វើអធិការកិច្ចនៅសាខាធនាគារជាតិនៃកម្ពុជា ។

**១០. ការងារគ្រប់គ្រងសាខា**

- ពង្រឹងការងារប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ឲ្យស្របតាមការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់ទាំងនោះ និង
- សហការជាមួយអាជ្ញាធរមូលដ្ឋានប្រចាំសាខារាជធានី-ខេត្ត ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលឲ្យកាន់តែទូលំទូលាយ ។

**១១. ការងារព័ត៌មានវិទ្យា**

- ពង្រឹងសមត្ថភាពប្រើប្រាស់ និងតាមដានកិច្ចដំណើរការប្រព័ន្ធផាត់ទាត់ជាតិ និង
- ធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ដំណើរការប្រតិបត្តិការសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជាដែលរួមមាន ប្រព័ន្ធផ្ញើរបាយការណ៍មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIURS) ប្រព័ន្ធផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ និងធនាគារឯកទេសតាមបណ្តាញអ៊ីនធើណិតមកធនាគារជាតិនៃកម្ពុជា (BSRS) និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងការចេញផ្សាយមូលបត្រអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជា (NCDBES) ។

**១២. ការងារបណ្តុះបណ្តាល**

- បន្តយន្តការពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកតាមរយៈការបើកវគ្គបណ្តុះបណ្តាល ការចែករំលែកនិងផ្ទេរចំណេះដឹង ពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យធនាគារ និងវគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំសម្រាប់មន្ត្រីបុគ្គលិក

- ចូលរួមសហការ និងរៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗនៅធនាគារជាតិនៃ
  កម្ពុជា និង
- ចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលា និងវគ្គសិក្សានានានៅក្នុងនិងក្រៅប្រទេស ។

**១៣. ការងារទំនាក់ទំនងអន្តរជាតិ**

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូពហុភាគី និងទ្វេភាគី ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១

## តារាង១ - ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា

(គ្រាគោល តុលា-ធ្នូ ២០០៦=១០០)

| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់(CPI) | ២០១១ | ២០១២ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **និង សន្ទស្សន៍ថ្លៃតាមក្រុមមុខទំនិញទំនិញ** | **ធ្នូ** | **មករា** | **កុម្ភៈ** | **មីនា** | **មេសា** | **ឧសភា** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **ធ្នូ** |
| **មុខទំនិញគ្រប់មុខ** | **១៤៥,០៣** | **១៤៦,៥០** | **១៤៧,០២** | **១៤៧,៩២** | **១៤៨,៧២** | **១៤៧,១២** | **១៤៧,៣៣** | **១៤៧,៣៥** | **១៤៨,៩៣** | **១៤៩,៣៣** | **១៤៩.០៤** | **១៤៨,៦៨** | **១៤៨,៧២** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ១៦៣,៦០ | ១៦៥,៦៣ | ១៦៥,០៩ | ១៦៥,៤៧ | ១៦៦,៩០ | ១៦៥,៥៧ | ១៦៧,០២ | ១៦៦,៦៥ | ១៦៨,៦០ | ១៦៩,២០ | ១៦៩,២០ | ១៦៨,០០ | ១៦៨,៥៦ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១២៣,៧២ | ១២៤,៦៤ | ១២៤,៣៣ | ១២៤,៣២ | ១២៤,៤៨ | ១២៥,៦៦ | ១២៦,២៤ | ១២៥,២២ | ១២៥,៩៥ | ១២៥,៦៩ | ១២៥,៨២ | ១២៥,៩២ | ១២៥,៩៤ |
| សម្លៀកបំពាក់ និងស្បែកជើង | ១១៨,០៩ | ១១៨,៧៥ | ១១៩,៩២ | ១២០,៥៨ | ១២១,៣៣ | ១២០,៨៣ | ១២១,៤៨ | ១២២,០៥ | ១២២,៤៨ | ១២៣,១០ | ១២២,៧២ | ១២២,៧៤ | ១២៣,៥៨ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ១២៣,៦១ | ១២៤,៤៤ | ១២៥,២៩ | ១២៧,៩៥ | ១២៧,៩១ | ១២៦,៤២ | ១២៥,៣៥ | ១២៥,២៣ | ១២៦,៣៣ | ១២៧,២០ | ១២៦,០៧ | ១២៦,៦០ | ១២៧,៧៥ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ១២៤,៤៧ | ១២៥,៣៧ | ១២៧,២៤ | ១២៧,៣០ | ១២៦,៩៧ | ១២៧,០៧ | ១២៧,៤០ | ១២៧,២៦ | ១២៨,១៣ | ១២៨,១៨ | ១២៨,៨៥ | ១២៨,៧៨ | ១២៨,៧៣ |
| សុខាភិបាល | ១១៥,៤០ | ១១៦,១១ | ១១៥,៦៥ | ១១៦,៥៩ | ១១៦,២៤ | ១១៦,៦១ | ១១៦,៤៨ | ១១៦,៤៨ | ១១៦,១៥ | ១១៥,៣៧ | ១១៥,៦៤ | ១១៥,៨៥ | ១១៥,៩១ |
| ការដឹកជញ្ជូន | ១២៨,២២ | ១២៩,៧៣ | ១៣២,៦៤ | ១៣៤,៤៩ | ១៣៤,៥៣ | ១៣១,០៧ | ១២៧,០១ | ១២៨,៦៧ | ១៣២,០៣ | ១៣១,១២ | ១៣០,២២ | ១២៩,៩៣ | ១២៩,៣៤ |
| គមនាគមន៍ | ៧២,៩៨ | ៧២,២២ | ៧២,១៤ | ៧១,៧២ | ៧១,៨៣ | ៧១,៩៥ | ៧១,៩៩ | ៧២,០៦ | ៧១,៨៨ | ៧១,៣៩ | ៧១,៤១ | ៧១,៥៤ | ៧១,៤៣ |
| ការកម្សាន្ត និងវប្បធម៌ | ១០២,៣៤ | ១០២,៣៤ | ១០១,៩៩ | ១០២,៥១ | ១០២,៦៥ | ១០២,៨៧ | ១០៣,៦២ | ១០៣,៦៥ | ១០២,៧០ | ១០២,៦៨ | ១០៣,៣៣ | ១០២,៨១ | ១០៣,៩៨ |
| ការសិក្សា | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤២,៦៩ | ១៤៤,៥១ | ១៤៤,៨១ | ១៤៥,៧២ | ១៤៦,៦៥ | ១៤៦,១១ | ១៤៦,១១ |
| ភោជនីយដ្ឋាន | ១៨៩,៣៤ | ១៩១,៥១ | ១៩៤,៨០ | ១៩៤,០៦ | ១៩៦,៣៣ | ១៩១,២៩ | ១៩៤,៨១ | ១៩៤,៨១ | ១៩៦,១៦ | ១៩៧,៧១ | ១៩៧,០៣ | ១៩៩,១៣ | ១៩៩,៩៥ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១៥១,២៩ | ១៥២,១១ | ១៥៣,៣៣ | ១៥៣,៦៣ | ១៥៤,៧៥ | ១៥២,១៨ | ១៥១,១៨ | ១៥០,៤៤ | ១៥១,១៦ | ១៥២,៥១ | ១៥២,៣៧ | ១៥២,៦៧ | ១៥២,៦២ |
| | | | | | | **បម្រែបម្រួលភាគរយខែលើខែ** | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **-០,៨៨** | **១,០១** | **០,៣៦** | **០,៦១** | **០,៥៤** | **-១,០៨** | **០,១៤** | **០,០១** | **១,០៧** | **០,២៧** | **-០,២០** | **-០,២៤** | **០,០២** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | -១,៤៧ | ១,២៤ | -០,៣៣ | ០,២៣ | ០,៨៧ | -០,៨០ | ០,៨៨ | -០,២២ | ១,១៧ | ០,៣៥ | ០,០០ | -០,៧១ | -០,២៦ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | -០,១៧ | ០,៧៥ | -០,២៥ | -០,០១ | ០,១៣ | ០,៩៥ | ០,៤៦ | -០,៨១ | ០,៥៩ | -០,២០ | ០,១០ | ០,០៨ | ០,០២ |
| សម្លៀកបំពាក់ និងស្បែកជើង | -០,៧៩ | ០,៥៦ | ០,៩៩ | ០,៥៥ | ០,៦២ | -០,៤២ | ០,៥៤ | ០,៤៧ | ០,៣៦ | ០,៥១ | -០,៣១ | ០,០១ | ០,៦៨ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ០,០៩ | ០,៦៧ | ០,៦៨ | ២,១៣ | -០,០៣ | -១,១៧ | -០,៨៤ | -០,១០ | ០,៨៨ | ០,៦៩ | -០,៨៩ | ០,៤២ | ០,៩១ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | -០,២៧ | ០,៧៣ | ១,៤៩ | ០,០៤ | -០,២៥ | ០,០៨ | ០,២៦ | -០,១២ | ០,៦៩ | ០,០៤ | ០,៥៣ | -០,០៥ | -០,០៤ |
| សុខាភិបាល | -១,៣៤ | ០,៦១ | -០,៣៩ | ០,៨១ | -០,៣០ | ០,៣២ | -០,១២ | ០,០០ | -០,២៨ | -០,៦៧ | ០,២៤ | ០,១៨ | ០,០៦ |
| ការដឹកជញ្ជូន | ០,២៤ | ១,១៨ | ២,២៤ | ១,៤០ | ០,០៣ | -២,៥៧ | -៣,១០ | ១,៣១ | ២,៦១ | -០,៦៩ | -០,៦៩ | -០,២២ | -០,៤៦ |
| គមនាគមន៍ | ០,៥៩ | -១,០៤ | -០,១២ | -០,៥៨ | ០,១៦ | ០,១៦ | ០,០៦ | ០,១០ | -០,២៥ | -០,៦៩ | ០,០៤ | ០,១៨ | -០,១៦ |
| ការកម្សាន្ត និងវប្បធម៌ | ០,១៩ | ០,០០ | -០,៣៤ | ០,៥១ | ០,១៤ | ០,២១ | ០,៧៣ | ០,០៣ | -០,៩២ | -០,០១ | ០,៦៣ | -០,៥០ | ១,១៤ |
| ការសិក្សា | ០,៣៦ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ១,២៨ | ០,២១ | ០,៦៣ | ០,៦៤ | -០,៣៧ | ០,០០ |
| ភោជនីយដ្ឋាន | -០,៧៥ | ១,១៥ | ១,៧២ | -០,៣៨ | ១,១៧ | -២,៥៧ | ១,៨៤ | ០,០០ | ០,៧០ | ០,៧៩ | -០,៣៤ | ១,០៧ | ០,៤១ |
| ទំនិញ និងសេវាកម្មផ្សេងៗ | -១,៦០ | ០,៥៤ | ០,៨០ | ០,២០ | ០,៧៣ | -១,៦៦ | -០,៦៥ | -០,៤៩ | ០,៤៨ | ០,៨៩ | -០,០៩ | ០,២០ | -០,០៣ |
| | | | | | | **បម្រែបម្រួលភាគរយឆ្នាំលើឆ្នាំ** | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **៤,៩១** | **៥,៧៧** | **៥,៤២** | **៥,៣៥** | **៤,៧៨** | **២,១៩** | **១,៨៣** | **១,២៨** | **២,១៨** | **១,៤៤** | **១,២០** | **១,៦២** | **២,៥៤** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ៦,១៦ | ៧,៧៣ | ៦,៧២ | ៦,២០ | ៥,៨១ | ២,១២ | ២,២៩ | ១,១៥ | ១,៩៣ | ០,៧៩ | ០,៦០ | ១,១៨ | ១,៤២ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១,៥០ | ១,៥៩ | ១,១៥ | ១,០៣ | ០,៩៨ | ២,៤០ | ២,៤៩ | ១,៣៩ | ២,៥៩ | ២,២០ | ១,៦៥ | ១,៦០ | ១,៨០ |
| សម្លៀកបំពាក់ និងស្បែកជើង | ៣,០៤ | ៣,៣០ | ៥,០៨ | ៤,៤២ | ៤,៩០ | ៤,០៨ | ៣,៨២ | ៤,៧៦ | ៤,៦៣ | ៣,៨៦ | ៣,៣២ | ៣,១២ | ៤,៦៥ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ២,១៣ | ១,៩៤ | ១,៨០ | ៣,៦២ | ២,៦៣ | ១,៤៤ | ០,៥៩ | ១,៣០ | ២,២៦ | ២,៨៣ | ២,១៤ | ២,៥១ | ៣,៣៥ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ២,២២ | ២,២៩ | ៤,១០ | ៣,៩០ | ៣,២៣ | ៣,៣២ | ៣,៥៥ | ៣,០៣ | ៣,៣១ | ២,៤៨ | ៣,៣៥ | ៣,១៩ | ៣,៤៣ |
| សុខាភិបាល | -១,៤៤ | -០,៤៧ | -១,១៣ | -០,៥៤ | -១,១២ | -១,២៣ | -០,៣៤ | -០,៥១ | -០,៤៧ | -១,០៣ | -០,៩១ | -០,៩៦ | ០,៤៤ |
| ការដឹកជញ្ជូន | ៦,៣២ | ៦,៨៥ | ៨,២៨ | ៨,១៩ | ៥,៨៥ | ៣,៦៥ | -០,៣០ | -០,៤០ | ២,៧៤ | ០,៩៩ | ១,០៥ | ១,៥៨ | ០,៨៧ |
| គមនាគមន៍ | -០,៥១ | -២,១៩ | -១,៨៧ | -២,១៤ | -១,៥៨ | -១,៧០ | -០,៨៤ | -០,៧៦ | -១,០៥ | -១,៧៥ | -១,៨២ | -១,៣៩ | -២,១២ |
| ការកម្សាន្ត និងវប្បធម៌ | -១,១៩ | -០,៩៨ | -០,៨៨ | -០,១៨ | ០,០៣ | ០,៤៩ | ១,៥០ | ១,៤៥ | ១,៦៥ | ១,១៦ | ១,១០ | ០,៦៦ | ១,៦១ |
| ការសិក្សា | ១,៨០ | ១,៨០ | ១,៨០ | ១,៨០ | ១,៥៥ | ១,៥៩ | ២,២៤ | ៣,២៦ | ៣,០៦ | ២,៨៧ | ៣,១៥ | ២,៧៧ | ២,៤០ |
| ភោជនីយដ្ឋាន | ៧,៥១ | ៧,២៧ | ៦,៧៦ | ៥,៨៣ | ៦,៤៥ | ២,៧៣ | ៣,៦១ | ៣,០០ | ៣,១៤ | ៣,៨៣ | ៣,៥៥ | ៤,៣៨ | ៥,៦០ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ៨,៥៣ | ១០,០៣ | ៩,៦០ | ៨,៥១ | ៨,៣៩ | ៥,៧៩ | ៤,១៩ | ៣,៤៥ | ៣,១០ | ២,១៨ | ០,៥៦ | -០,៧០ | ០,៨៧ |
| | | | | | | **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ៣ខែ** | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **១៤៦,២១** | **១៤៥,៩៥** | **១៤៦,១៨** | **១៤៧,១៥** | **១៤៧,៨៩** | **១៤៧,៩២** | **១៤៧,៧៣** | **១៤៧,២៧** | **១៤៧,៨៧** | **១៤៨,៥៤** | **១៤៩,១០** | **១៤៩,០២** | **១៤៨,៨១** |
| បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ | ៥,២៨ | ៥,៤៥ | ៥,៣៧ | ៥,៥១ | ៥,១៨ | ៤,០៩ | ២,៩២ | ១,៧៧ | ១,៧៧ | ១,៦៤ | ១,៦១ | ១,៤២ | ១,៧៨ |
| | | | | | | **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ១២ខែ** | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **១៤៣,៨៤** | **១៤៤,៥០** | **១៤៥,១៣** | **១៤៥,៧៦** | **១៤៦,៣២** | **១៤៦,៥៩** | **១៤៦,៨១** | **១៤៦,៩៦** | **១៤៧,២៣** | **១៤៧,៤០** | **១៤៧,៥៥** | **១៤៧,៧៥** | **១៤៨,០៦** |
| បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ | ៥,៤៨ | ៥,៦៨ | ៥,៨១ | ៥,៩៤ | ៥,៩០ | ៥,៥៣ | ៥,០៨ | ៤,៥៩ | ៤,២៤ | ៣,៨០ | ៣,៤៦ | ៣,១៣ | ២,៩៣ |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ

# ឧបសម្ព័ន្ធ ២

## តារាង ២ - ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា ( ធ្នូ ២០០៨ - ធ្នូ ២០១២ )

(គ្រាគោល តុលា-ធ្នូ ២០០៦=១០០)

| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ( CPI ) និង សន្ទស្សន៍ថ្លៃតាមក្រុមមុខទំនិញទំនិញ | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ | ធ្នូ-១១ | ធ្នូ-១២ |
|---|---|---|---|---|---|
| **មុខទំនិញគ្រប់មុខ** | **១២៧,២៦** | **១៣៤,០៣** | **១៣៨,២៥** | **១៤៥,០៣** | **១៤៨,៧២** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ១៤១,០៦ | ១៤៨,៧១ | ១៥៤,១១ | ១៦៣,៦០ | ១៦៧,៥៦ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១១១,០០ | ១២២,៤៨ | ១២១,៨៩ | ១២៣,៧២ | ១២៥,៩៤ |
| សម្លៀកបំពាក់ និងស្បែកជើង | ១០៨,៩២ | ១១១,៧៥ | ១១៤,៦១ | ១១៨,០៩ | ១២៣,៥៨ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ១១៥,៣៤ | ១១៧,៦២ | ១២១,០៣ | ១២៣,៦១ | ១២៧,៧៥ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ១១៤,៥០ | ១២០,០១ | ១២១,៧៦ | ១២៤,៤៧ | ១២៨,៧៣ |
| សុខាភិបាល | ១០៩,៩៤ | ១១៦,៣១ | ១១៧,០៩ | ១១៥,៤០ | ១១៥,៩១ |
| ការដឹកជញ្ជូន | ១០៤,២១ | ១១៦,៦៦ | ១២០,៥៩ | ១២៨,២២ | ១២៩,៣៤ |
| គមនាគមន៍ | ៧៨,៤៥ | ៧២,៩៩ | ៧៣,៣៥ | ៧២,៩៨ | ៧១,៤៣ |
| ការកម្សាន្ត និងវប្បធម៌ | ១០៤,៧១ | ១០៣,០៩ | ១០៣,៥៧ | ១០២,៣៤ | ១០៣,៩៨ |
| ការសិក្សា | ១២៧,៤០ | ១៣៨,៧៦ | ១៤០,១៦ | ១៤២,៦៩ | ១៤៦,១១ |
| ភោជនីយដ្ឋាន | ១៦៥,៦២ | ១៧១,៩៧ | ១៧៦,១២ | ១៨៩,៣៤ | ១៩៩,៩៥ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១១៣,៨៦ | ១២៦,៧៥ | ១៣៩,៤០ | ១៥១,២៩ | ១៥២,៦២ |
| | | | **បម្រែបម្រួលភាគរយឆ្នាំលើឆ្នាំ** | | |
| **មុខទំនិញគ្រប់មុខ** | **១២,៥២** | **៥,៣២** | **៣,១៤** | **៤,៩១** | **២,៥៤** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ១៩,០៨ | ៥,៤២ | ៣,៦៣ | ៦,១៦ | ២,៤២ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ៨,៦០ | ១០,៣៤ | -០,៤៨ | ១,៥០ | ១,៨០ |
| សម្លៀកបំពាក់ និងស្បែកជើង | ៦,៨០ | ២,៦០ | ២,៥៦ | ៣,០៤ | ៤,៦៥ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ២,៣៨ | ១,៩៨ | ២,៩០ | ២,១៣ | ៣,៣៥ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ៧,៣៧ | ៤,៨១ | ១,៤៦ | ២,២២ | ៣,៤៣ |
| សុខាភិបាល | ៤,១៩ | ៥,៨០ | ០,៦៧ | -១,៤៤ | ០,៤៤ |
| ការដឹកជញ្ជូន | -៧,៣៨ | ១១,៩៤ | ៣,៣៧ | ៦,៣២ | ០,៨៧ |
| គមនាគមន៍ | -៧,៩៧ | -៦,៩៥ | ០,៤៩ | -០,៥១ | -២,១២ |
| ការកម្សាន្ត និងវប្បធម៌ | ៦,១៥ | -១,៥៤ | ០,៤៦ | -១,១៩ | ១,៦១ |
| ការសិក្សា | ២០,១៩ | ៨,៩២ | ១,០១ | ១,៨០ | ២,៤០ |
| ភោជនីយដ្ឋាន | ៥៣,០៩ | ៣,៨៤ | ២,៤១ | ៧,៥១ | ៥,៦០ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ៣,៤៥ | ១១,៣២ | ៩,៩៨ | ៨,៥៣ | ០,៨៧ |
| | | | **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ៣ខែ** | | |
| **មុខទំនិញគ្រប់មុខ** | **១៣២,២៧** | **១៣៤,៣៨** | **១៣៨,៨៨** | **១៤៦,២១** | **១៤៨,៨១** |
| បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ | ១៧,៧៦ | ១,៥៩ | ៣,៣៥ | ៥,២៨ | ១,៧៨ |
| | | | **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ១២ខែ** | | |
| **មុខទំនិញគ្រប់មុខ** | **១៣២,០០** | **១៣១,១២** | **១៣៦,៣៦** | **១៤៣,៨៤** | **១៤៨,០៦** |
| បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ | ២៥,០០ | -០,៦៦ | ៤,០០ | ៥,៤៨ | ២,៩៣ |

## តារាង៣ - ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ ( អត្រានិញចុងខែ )

| រូបិយប័ណ្ណ | ២០១១ | ២០១២ | | | | | | | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ធ្នូ-១២ /ធ្នូ-១១ |
| អេសដេអែរ | ៦.១៨១ | ៦.២៨៩ | ៦.២៤៣ | ៦.១៧៣ | ៦.២៣៦ | ៦.១៤៥ | ៦.១៤១ | ៦.១៣៧ | ៦.១៥០ | ៦.២២៥ | ៦.១៨៩ | ៦.១២៦ | ៦.១៤០ | -០,៧ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៤.០៩៨ | ៤.៣០១ | ៤.៣៣៤ | ៤.១៤៥ | ៤.២០៥ | ៣.៩៣៥ | ៤.០៧៥ | ៤.២៧២ | ៤.១៦១ | ៤.២១៩ | ៤.១៦៥ | ៤.១៦៣ | ៤.១៥០ | ១,៣ |
| ដុល្លារ-ហុងកុង | ៥២០ | ៥២៤ | ៥១៨ | ៥១៤ | ៥១៩ | ៥២៣ | ៥២៤ | ៥២៥ | ៥២២ | ៥២១ | ៥២០ | ៥១៥ | ៥១៥ | -១,០ |
| យ៉េន-ជប៉ុន | ៥២,០១ | ៥៣,២៦ | ៤៩,៨៥ | ៤៨,៦២ | ៥០,០៩ | ៥១,៤៩ | ៥១,២៦ | ៥២,០៩ | ៥១,៤៨ | ៥២,០៨ | ៥០,៥១ | ៤៨,៦១ | ៤៦,៤៥ | -១០,៧ |
| វ៉ុន-កូរ៉េ | ៣,៥០ | ៣,៦០ | ៣,៥៨ | ៣,៥១ | ៣,៥៥ | ៣,៤៣ | ៣,៥១ | ៣,៥៨ | ៣,៥៦ | ៣,៦២ | ៣,៦៧ | ៣,៦៨ | ៣,៧៤ | ៦,៩ |
| ដុល្លារ-ញ៉ូស៊ីឡែន | ៣.១១៩ | ៣.៣២៨ | ៣.៣៧៤ | ៣.២៦៤ | ៣.៣១១ | ៣.០៥០ | ៣.១៩៤ | ៣.២៩៣ | ៣.២២៩ | ៣.៣៥៧ | ៣.៣០៣ | ៣.២៨៥ | ៣.២៨៧ | ៥,៤ |
| យ័ន់ចិន | ៦៣៩ | ៦៤១ | ៦៣៧ | ៦៣៣ | ៦៣៨ | ៦៣៩ | ៦៣៩ | ៦៣៨ | ៦៣៧ | ៦៤១ | ៦៤៥ | ៦៤២ | ៦៤១ | ០,៣ |
| ដុល្លារ-តៃវ៉ាន់ | ១៣៣ | ១៣៧ | ១៣៦ | ១៣៥ | ១៣៧ | ១៣៧ | ១៣៦ | ១៣៥ | ១៣៥ | ១៣៨ | ១៣៨ | ១៣៧ | ១៣៨ | ៣,៨ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូណេស៊ី | ០,៤៤៥ | ០,៤៥២ | ០,៤៤ | ០,៤៣៥ | ០,៤៣៧ | ០,៤៣០ | ០,៤២៨ | ០,៤២៩ | ០,៤២២ | ០,៤២១ | ០,៤១៩ | ០,៤១៤ | ០,៤១១ | -៧,៦ |
| រីងហ្គីត-ម៉ាឡេស៊ី | ១.២៧៤ | ១.៣៣០ | ១.៣៣៩ | ១.៣០០ | ១.៣២៦ | ១.២៧៦ | ១.២៧២ | ១.២៩២ | ១.២៩២ | ១.៣១៥ | ១.៣១៦ | ១.៣១០ | ១.៣០៤ | ២,៤ |
| ប៉េសូ-ហ្វីលីពីន | ៩២,១០ | ៩៤,២៧ | ៩៣,៥៩ | ៩២,៩០ | ៩៤,៩២ | ៩៣,៣៨ | ៩៥,៨៥ | ៩៧,១២ | ៩៥,៧៤ | ៩៦,៤២ | ៩៧,៥៣ | ៩៧,៧៧ | ៩៧,៣៧ | ៥,៧ |
| ដុល្លារ-សាំងហ្គាពួរ | ៣.១០៨ | ៣.២២៩ | ៣.២១៥ | ៣.១៧៣ | ៣.២៥០ | ៣.១៥២ | ៣.១៧៣ | ៣.២៦៤ | ៣.២២៧ | ៣.២៩៦ | ៣.២៩៨ | ៣.២៦៩ | ៣.២៦៦ | ៥,១ |
| បាត-ថៃ | ១២៧ | ១៣០ | ១៣២ | ១២៩ | ១៣១ | ១២៧ | ១២៧ | ១២៩ | ១២៩ | ១៣១ | ១៣១ | ១៣០ | ១៣១ | ៣,១ |
| ដុង-វៀតណាម | ០,១៩២ | ០,១៩៣ | ០,១៩២ | ០,១៩២ | ០,១៩៣ | ០,១៩៥ | ០,១៩៤ | ០,១៩៥ | ០,១៩៤ | ០,១៩៣ | ០,១៩៣ | ០,១៩១ | ០,១៩១ | -០,៥ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៥.២៣០ | ៥.៣៣៨ | ៥.៤១០ | ៥.៣២០ | ៥.៣២៦ | ៥.០២៦ | ៥.០៥៦ | ៤.៩៩០ | ៥.០៦១ | ៥.២២០ | ៥.២០២ | ៥.១៧៨ | ៥.២៨៥ | ១,១ |
| **ផ្សេង** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៦.២២៥ | ៦.៣៨២ | ៦.៣៩១ | ៦.៣៧៥ | ៦.៥៤៩ | ៦.២៨៧ | ៦.៣០៩ | ៦.៣៩៤ | ៦.៣៨៥ | ៦.៥៦២ | ៦.៥៦០ | ៦.៤០២ | ៦.៤៥៦ | ២,៧ |

# តារាង៤ - ស្ថានភាពរូបិយវត្ថុ

(ឯកតា : ពាន់លានរៀល)

| | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ | ធ្នូ-១១ | ធ្នូ-១២ |
|---|---|---|---|---|---|
| | | | **( គិតជាពាន់លានរៀល )** | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១០.៣៤៦** | **១៤.៦៥៥** | **១៦.៦៩៨** | **១៧.៨៩៤** | **១៨.១៥៥** |
| ទ្រព្យសកម្មបរទេស | ១២.៨៨៦ | ១៦.៥១៣ | ១៨.៩១៨ | ២០.៦១៧ | ២៤.៦១៤ |
| ទ្រព្យអកម្មបរទេស | -២.៥៤០ | -១.៨៥៨ | -២.២២០ | -២.៧២៣ | -៦.៤៥៩ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១.៥១៣** | **១.៥៧៣** | **២.៧៧៩** | **៥.៧៦១** | **១០.៤៣៧** |
| **ឥណទានក្នុងស្រុក** | **៦.៩០៧** | **៨.២៨០** | **១១.២០៦** | **១៥.៤៣០** | **២១.០៥៦** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | **-២.៩៨៧** | **-២.២៥២** | **-២.១២៧** | **-២.១២៣** | **-២.៤៨៦** |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -៣.២៥៧ | -២.៥២២ | -២.៣៩៧ | -២.៣៩៣ | -២.៧៥៧ |
| **ផ្នែកមិនមែនរដ្ឋាភិបាល** | **៩.៨៩៤** | **១០.៥៣២** | **១៣.៣៣៣** | **១៧.៥៥៣** | **២៣.៥៤២** |
| ចំពោះសហគ្រាសរដ្ឋ | ១ | ០ | ២ | ០ | ៦ |
| ចំពោះផ្នែកឯកជន | ៩.៨៩៣ | ១០.៥៣២ | ១៣.៣៣១ | ១៧.៥៥៣ | ២៣.៥៣៧ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-៥.៣៩៤** | **-៦.៧០៧** | **-៨.៤២៧** | **-៩.៦៦៩** | **-១០.៦១៨** |
| ប្រាក់បញ្ញើរឹតត្បិត | -២៨៨ | -៣៤១ | -៤៧៦ | -៦០៨ | -៦៥៥ |
| ដើមទុន និងទុនបម្រុង | -៥.៧៧៦ | -៧.២៥៨ | -៨.៦៧៣ | -៩.៧០៣ | -១១.៤៩១ |
| ផ្សេងៗ | ៦៧០ | ៨៩២ | ៧២២ | ៦៤១ | ១.៥២៧ |
| **រូបិយវត្ថុទូទៅ** ( M2 ) | **១១.៨៥៩** | **១៦.២២៨** | **១៩.៤៧៧** | **២៣.៦៥៥** | **២៨.៥៩២** |
| **រូបិយវត្ថុ** ( M1 ) | **២.៤០០** | **៣.១២០** | **៣.២២១** | **៣.៩៥៦** | **៥.០៤៦** |
| រូបិយវត្ថុក្រៅធនាគារ | ២.២៩៥ | ៣.០០២ | ៣.០៩៩ | ៣.៧៧២ | ៣.៧៥៦ |
| ប្រាក់បញ្ញើចរន្ត | ១០៥ | ១១៩ | ១២២ | ១៨៥ | ២៩០ |
| **រូបិយវត្ថុផ្សេងៗ** | **៩.៤៥៩** | **១៣.១០៨** | **១៦.២៥៦** | **១៩.៦៩៨** | **២៤.៥៤៦** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ១៨៥ | ៣៥៩ | ៤០៨ | ៥៥៧ | ៧៨០ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៩.២៧៤ | ១២.៧៤៩ | ១៥.៨៤៨ | ១៩.១៤១ | ២៣.៧៦៦ |
| | | | **( បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ )** | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-៣,៦** | **៤១,៧** | **១៣,៩** | **៧,២** | **១,៥** |
| ទ្រព្យសកម្មបរទេស | ៨,៤ | ២៨,២ | ១៤,៦ | ៩,០ | ១៩,៤ |
| ទ្រព្យអកម្មបរទេស | ១១៩,៨ | -២៦,៨ | ១៩,៤ | ២២,៧ | ១៣៧,២ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១៦២,៧** | **៤,០** | **៧៦,៦** | **១០៧,៣** | **៨១,២** |
| **ឥណទានក្នុងស្រុក** | **៥១,១** | **១៩,៩** | **៣៥,៣** | **៣៧,៧** | **៣៦,៥** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | -៦៤,៥ | ២៤,៦ | -៥,៥ | -០,២ | -១៧,១ |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | -៨,៩ | -០,០ | -៥,២ | ៥,២ | ០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | ៥៤,២ | -២២,៦ | -៥,០ | -០,១ | ១៥,២ |
| **ផ្នែកមិនមែនរដ្ឋាភិបាល** | ៥៤,៩ | ៦,៤ | ២៦,៦ | ៣១,៦ | ៣៤,១ |
| ចំពោះសហគ្រាសរដ្ឋ | -៤៩,៨ | -១០០ | ០ | -១០០ | - |
| ចំពោះផ្នែកឯកជន | ៥៥,០ | ៦,៥ | ២៦,៦ | ៣១,៧ | ៣៤,១ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-៣៥,០** | **-២៤,៣** | **-២៥,៧** | **-១៤,៧** | **-៩,៨** |
| ប្រាក់បញ្ញើរឹតត្បិត | ១៣,១ | ១៨,៥ | ៣៩,៦ | ២៧,៦ | ៧,៨ |
| ដើមទុន និងទុនបម្រុង | ៣៤,០ | ២៥,៧ | ១៩,៥ | ១១,៩ | ១៨,៤ |
| ផ្សេងៗ | ១៧,១ | ៣៣,១ | -១៩,១ | -១១,២ | ១៣៨,២ |
| **រូបិយវត្ថុទូទៅ** ( M2 ) | **៤,៨** | **៣៦,៨** | **២០,០** | **២១,៥** | **២០,៩** |
| **រូបិយវត្ថុ** ( M1 ) | **១៦,៩** | **៣០,០** | **៣,២** | **២២,៨** | **២,៣** |
| រូបិយវត្ថុក្រៅធនាគារ | ១៥,៣ | ៣០,៨ | ៣,២ | ២១,៧ | -០,៤ |
| ប្រាក់បញ្ញើចរន្ត | ៦៨,៣ | ១៣,២ | ៣,១ | ៥០,៩ | ៥៧,២ |
| **រូបិយវត្ថុផ្សេងៗ** | **២,២** | **៣៨,៦** | **២៤,០** | **២១,២** | **២៤,៦** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៥២,៧ | ៩៤,១ | ១៣,៨ | ៣៦,៤ | ៤០,០ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ១,៥ | ៣៧,៥ | ២៤,៣ | ២០,៨ | ២៤,២ |

# ឧបសម្ព័ន្ធ ៥

## តារាង៥ - តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា

| | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ | ធ្នូ-១១ | ធ្នូ-១២ |
|---|---|---|---|---|---|
| | | | (គិតជាពាន់លានរៀល) | | |
| **រូបិយវត្ថុបម្រុង** | **៦.១០០** | **៨.៧៤១** | **១០.២៤៥** | **១១.០៣៣** | **១៣.១២៩** |
| រូបិយវត្ថុក្រៅធនាគារ | ២.២៩៥ | ៣.០០២ | ៣.០៩៩ | ៣.៧៧២ | ៣.៧៥៦ |
| បេឡាធនាគារពាណិជ្ជ | ៩០ | ៨៦ | ១៤០ | ១៧៦ | ២២៨ |
| ប្រាក់បញ្ញើធនាគារ | ៣.៦៨៨ | ៥.៦២១ | ៦.៩៧៨ | ៧.០៣២ | ៩.០៥៤ |
| ប្រាក់បម្រុងកាតព្វកិច្ច | ១.៦៣២ | ១.៦៧៧ | ២.១៣៤ | ២.៦៣៤ | ៣.៤៨៨ |
| ប្រាក់បញ្ញើផ្សេងៗ | ២.០៥៥ | ៣.៩៤៥ | ៤.៨៤៤ | ៤.៣៩៨ | ៥.៥៦៦ |
| ផ្សេងៗ | ២៨ | ៣២ | ២៨ | ៥៣ | ៩២ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១០.៧៧៦** | **១៣.២៦២** | **១៤.៩៨២** | **១៦.០១០** | **១៨.៥៨៣** |
| ទ្រព្យសកម្មបរទេស | ១០.៧៧៦ | ១៣.៧១០ | ១៥.៤១០ | ១៦.៤៣៥ | ១៩.០០៣ |
| ទ្រព្យអកម្មបរទេស | ០ | ៤៤៨ | ៤២៨ | ៤២៥ | ៤២១ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៤.៦៧៦** | **-៤.៥២០** | **-៤.៧៣៨** | **-៤.៩៧៧** | **-៥.៤៥៣** |
| ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល | -២.៦៩៦ | -១.៩៧៦ | -១.៧៨៥ | -១.៧៨៣ | -២.១២៦ |
| ឥណទេយ្យចំពោះរាជរដ្ឋាភិបាល | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ២.៩៦៦ | ២.២៤៦ | ២.០៥៥ | ២.០៥៤ | ២.៣៩៦ |
| ឥណទានសុទ្ធចំពោះធនាគារពាណិជ្ជ | -១៩៤ | -២៩៦ | -៤៣៩ | -៥៧៦ | -៦៣៥ |
| ខ្ទង់ផ្សេងៗសុទ្ធ | -១.៧៨៨ | -២.២៥០ | -២.៥១៤ | -២.៦១៧ | -២.៦៩២ |
| | | | (បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ) | | |
| **រូបិយវត្ថុបម្រុង** | **២១,៦** | **៤៣,៣** | **១៧,២** | **៧,៧** | **១៩,០** |
| រូបិយវត្ថុក្រៅធនាគារ | ១៥,៣ | ៣០,៨ | ៣,២ | ២១,៧ | -០,៤ |
| បេឡាធនាគារពាណិជ្ជ | ៩០,៧ | -៤,០ | ៦២,៦ | ២៥,៣ | ២៩,៥ |
| ប្រាក់បញ្ញើធនាគារ | ២៤,២ | ៥២,៤ | ២៤,១ | ០,៨ | ២៨,៧ |
| ប្រាក់បម្រុងកាតព្វកិច្ច | ១០៩,៩ | ២,៧ | ២៧,៣ | ២៣,៤ | ៣២,៤ |
| ប្រាក់បញ្ញើផ្សេងៗ | -៦,២ | ៩១,៩ | ២២,៨ | -៩,២ | ២៦,៥ |
| ផ្សេងៗ | ១១៥,២ | ១៧,០ | -១៤,១ | ៩២,៤ | ៧២,៩ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **២៥,៦** | **២៣,១** | **១៣,០** | **៦,៩** | **១៦,១** |
| ទ្រព្យសកម្មបរទេស | ២៥,៦ | ២៧,២ | ១២,៤ | ៦,៦ | ១៥,៦ |
| ទ្រព្យអកម្មបរទេស | | | -៤,៥ | -០,៧ | -១,០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៣១,៣** | **៣,៣** | **-៤,៨** | **-៥,១** | **-៩,៦** |
| ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល | -៦៥,២ | ២៦,៧ | ៩,៧ | ០,១ | -១៩,២ |
| ឥណទេយ្យចំពោះរាជរដ្ឋាភិបាល | -៨,៩ | ០,០ | ០,០ | ០,០ | ០,០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ៥៣,៨ | -២៤,៣ | -៨,៥ | -០,១ | ១៦,៧ |
| ឥណទានសុទ្ធចំពោះធនាគារពាណិជ្ជ | ២៨,៣ | ៥២,៥ | ៤៨,១ | ៣១,៣ | ១០,២ |
| ខ្ទង់ផ្សេងៗសុទ្ធ | -០,៥ | -២៥,៨ | -១១,៧ | -៤,១ | -២,៩ |

# ឧបសម្ព័ន្ធ ៦

## តារាង៦ - តារាងគណនីវិភាគធនាគារពាណិជ្ជ

| | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ | ធ្នូ-១១ | ធ្នូ-១២ |
|---|---|---|---|---|---|
| | | | (គិតជាពាន់លានរៀល) | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-៤៣១** | **១.៣៩៣** | **១.៧១៥** | **១.៨៨៤** | **-៤២៨** |
| ទ្រព្យសកម្មបរទេស | ២.១១០ | ២.៨០៤ | ៣.៥០៨ | ៤.១៨២ | ៥.៦១០ |
| ទ្រព្យអកម្មបរទេស | ២.៥៤០ | ១.៤១១ | ១.៧៩២ | ២.២៩៨ | ៦.០៣៨ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៥.៩៦២** | **៥.៧៣៣** | **៧.១៨៥** | **១០.៧២២** | **១៥.៤៩៩** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **៩.៥៦១** | **១០.២៥៤** | **១២.៩៩១** | **១៧.២១៣** | **២៣.១៨២** |
| ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល | -២៩២ | -២៧៦ | -៣៤២ | -៣៤០ | -៣៦០ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | ១ | ០ | ២ | ០ | ៦ |
| ឥណទានចំពោះផ្នែកឯកជន | ៩.៨៩២ | ១០.៥៣០ | ១៣.៣៣១ | ១៧.៥៥៣ | ២៣.៥៣៧ |
| ឥណទេយ្យសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | -៤០ | ០ | ០ | ០ | ០ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-៣.៥៩៨** | **-៤.៥២១** | **-៥.៨០៦** | **-៦.៤៩២** | **-៧.៦៨៣** |
| **ទុនបម្រុង** | **៤.០០៥** | **៦.០៦៨** | **៧.៤៥០** | **៧.២២៤** | **៩.៦៧៣** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ៩០ | ៨៦ | ១៤០ | ១៧៦ | ២២៨ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ៣.៩១៥ | ៥.៩៨២ | ៧.៣០៩ | ៧.០៤៨ | ៩.៤៤៥ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុកសុទ្ធ)** | **៩.៥៣៧** | **១៣.១៩៤** | **១៦.៣៥០** | **១៩.៨៣០** | **២៤.៧៤៤** |
| ប្រាក់បញ្ញើចរន្ត | ៧៧ | ៨៦ | ៩៥ | ១៣១ | ១៩៨ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ១៨៥ | ៣៥៩ | ៤០៨ | ៥៥៧ | ៧៨០ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៩.២៧៤ | ១២.៧៤៩ | ១៥.៨៤៨ | ១៩.១៤១ | ២៣.៧៦៦ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **១៧.៣០៨** | **២១.៣៤៤** | **២៦.៣៧២** | **៣២.២១៦** | **៤៤.៣៧១** |
| | | | (បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ) | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-១២០,០** | **-៤២៣,៦** | **២៣,១** | **៩,៨** | **-១២២,៧** |
| ទ្រព្យសកម្មបរទេស | -៣៦,៣ | ៣២,៩ | ២៥,១ | ១៩,២ | ៣៤,១ |
| ទ្រព្យអកម្មបរទេស | ១១៩,៨ | -៤៤,៥ | ២៧,០ | ២៨,២ | ១៦២,៧ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៤៨,៣** | **-៣,៨** | **២៥,៣** | **៤៩,២** | **៤៤,៦** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **៥៥,២** | **៧,៣** | **២៦,៧** | **៣២,៥** | **៣៤,៧** |
| ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល | -៥៨,៥ | ៥,៣ | -២៣,៩ | ០,៧ | -៦,១ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | -៤៩,៨ | -១០០ | ០ | -១០០ | ០ |
| ឥណទានចំពោះផ្នែកឯកជន | ៥៥,០ | ៦,៥ | ២៦,៦ | ៣១,៧ | ៣៤,១ |
| ឥណទេយ្យសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | ០ | -១០០ | ០ | ០ | ០ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-៦៨,២** | **-២៥,៦** | **-២៨,៤** | **-១១,៨** | **-១៨,៣** |
| **ទុនបម្រុង** | **២៧,៩** | **៥១,៥** | **២២,៨** | **-៣,០** | **៣៣,៩** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ៩០,៧ | -៤,០ | ៦២,៦ | ២៥,៣ | ២៩,៥ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ២៦,៩ | ៥២,៨ | ២២,២ | -៣,៦ | ៣៤,០ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុកសុទ្ធ)** | **២,៥** | **៣៨,៤** | **២៣,៩** | **២១,៣** | **២៤,៨** |
| ប្រាក់បញ្ញើចរន្ត | ៥៦,១ | ១១,៨ | ៩,៥ | ៣៨,៨ | ៥០,៨ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៥២,៧ | ៩៤,១ | ១៣,៨ | ៣៦,៤ | ៤០,០ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ១,៥ | ៣៧,៥ | ២៤,៣ | ២០,៨ | ២៤,២ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **២៧,៨** | **២៣,៣** | **២៣,៦** | **២២,២** | **៣៧,៧** |

## តារាង៧ - ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច

(ឯកតា : ពាន់លានរៀល)

| | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| **១- គ្រឹះស្ថានហិរញ្ញវត្ថុ** | **១៣៥** | **១៤៥** | **១៧៧** | **៣២៣** | **៥៣៧** |
| ធនាគារជាតិនៃកម្ពុជា | ០ | ០ | ០ | ០ | ០ |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៩ | ១០ | ១៨ | ១០៥ | ៣៣១ |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត | ១២៦ | ១៣៥ | ១៦០ | ២១៩ | ២០៦ |
| **២- គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ** | **៨.៣០០** | **៩.២០៨** | **១១.៦៩៥** | **១៥.០៥៧** | **២០.៤១៤** |
| កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | ៥១៦ | ៧០៩ | ៨៨៤ | ១.៥៦៩ | ២.២៨៨ |
| ឧស្សាហកម្មរ៉ែ | ៧ | ១១ | ៥៥ | ១៣ | ៨៤ |
| កម្មន្តសាលកម្ម | ៩៨៤ | ៩២០ | ១.១៥០ | ១.៦២២ | ២.២០៧ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ៧៧ | ៥៦ | ៧៣ | ២០៩ | ២២៤ |
| សំណង់ | ៧៧៤ | ៩០៤ | ៩៣១ | ១.៣១៧ | ១.៧៨៥ |
| ការជួញដូរដុំ | ១.៦១៨ | ១.៣៥៣ | ២.៣១៦ | ២.៥៤៥ | ៤.១៨៩ |
| ការជួញដូររាយ | ១.២៤៥ | ១.៩២២ | ២.៣៦៩ | ៣.១៨៧ | ៣.៦៩៧ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ១.២៧៧ | ១.២៦២ | ១.២៨៨ | ១.៣១២ | ១.៤១៦ |
| ដឹកជញ្ជូននិងស្តុកបណ្តោះអាសន្ន | ១៣៧ | ១៧៦ | ២៥២ | ២៧២ | ៣១០ |
| បណ្តាញព័ត៌មាននិងទូរគមនាគមន៍ | ២៤៤ | ៣០៨ | ៣៥៦ | ៥២៨ | ៧៨៥ |
| អាជីវកម្មជួលនិងភតិសន្យាប្រតិបត្តិការ មិនរាប់បញ្ចូលភតិសន្យា និងការជួលអចលនទ្រព្យ | ២៤ | ៤៦ | ៩៩ | ២៩៣ | ៣០៨ |
| ការជួញដូរអចលនទ្រព្យ | ៧៣៧ | ៦៦៣ | ៦១៣ | ៥៦៥ | ៧៣៣ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត | ៦៥៩ | ៨៧៩ | ១.៣០៩ | ១.៦២៤ | ២.៣៧៧ |
| **៣- គម្រោងការផ្ទាល់ខ្លួនផ្សេងៗទៀត** | **១.៣១៦** | **១.១៤២** | **១.១៨៣** | **២.០០២** | **២.៣៣៦** |
| ការឲ្យខ្ចីជាបុគ្គល | ៥៨៤ | ៧៤៨ | ៦៨៤ | ៨៧៤ | ៩៨២ |
| ការឲ្យខ្ចីតាមប័ណ្ណឥណទាន | ១៦ | ១៧ | ២៤ | ៣៣ | ៣៦ |
| ការឲ្យខ្ចីទិញផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន | ៧១៦ | ៣៧៨ | ៤៧៦ | ១.០៩៦ | ១.៣១៨ |
| **៤- ឥណទានផ្សេងៗ** | **៨១** | **៤៦** | **១៦៥** | **២៩៧** | **៤៨៥** |
| **សរុបឥណទានដុល** | **៩.៨៣៣** | **១០.៥៤១** | **១៣.២២១** | **១៧.៦៨០** | **២៣.៧៦២** |

## តារាង៨ - សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

(ឯកតា : ពាន់លានរៀល)

| | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| **ប្រាក់បញ្ញើជារៀល** | | | | | |
| ប្រាក់បញ្ញើជារៀល | ៤១ | ១០២ | ១៤១ | ១៧៦ | ២៧៨,៦ |
| ប្រាក់បញ្ញើសន្សំ | ៦៣ | ២៣៣ | ១៩៨ | ២៦៧ | ៣៥៨,១ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៤២ | ១៣៩ | ២០១ | ២៨២ | ៣៩៩,៧ |
| ប្រាក់បញ្ញើផ្សេងៗ | ២ | ១ | ១ | ០,៣ | ១៤,៣ |
| **សរុប** | **១៤៨** | **៤៧៦** | **៥៤១** | **៧២៥** | **១.០៥០,៧** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | |
| ប្រាក់បញ្ញើជារៀល | ៩៥៩ | ២.៧១៤ | ៣.២១៩ | ៣.៨៣៥ | ៥.៣២០,៤ |
| ប្រាក់បញ្ញើសន្សំ | ១.៧០៣ | ៤.២៥៦ | ៦.០៧៤ | ៧.០១០ | ៨.៥៩០,៥ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១.០៧២ | ៦.៣០៨ | ៧.៥៦៥ | ៨.៨៩៨ | ១១.២៩៩,១ |
| ប្រាក់បញ្ញើផ្សេងៗ | ៤៦ | ៨៩ | ៨០ | ៤១២ | ៦៤៩,៨ |
| **សរុប** | **៣.៧៨០** | **១៣.៣៦៦** | **១៦.៩៣៨** | **២០.១៥៦** | **២៥.៨៥៩,៩** |
| **សរុបរួម** | **៣.៩២៧** | **១៣.៨៤២** | **១៧.៤៧៩** | **២០.៨៨១** | **២៦.៩១០,៦** |

# ឧបសម្ព័ន្ធ ៨

## ជញ្ជីងទូទាត់ប្រទេសកម្ពុជា

ឆ្នាំ២០០៩ ដល់ ២០១២

(គិតជាលានដុល្លារអាមេរិក)

| | ២០០៩ | ២០១០ | ២០១១ | ២០១២[ព] |
|---|---|---|---|---|
| **ជញ្ជីងពាណិជ្ជកម្ម** | **-១.៤៩៤,២** | **-១.៥៨១,៦** | **-១.៤៩០,១** | **-១.៧៤១,៨** |
| នាំចេញ (FOB) | ២.៩៩៥,៧ | ៣.៨៨៤,៣ | ៥.២១៩,៥ | ៥.៨០២,១ |
| នាំចេញផលិតផលក្នុងស្រុក | ២.៧៣៣,៧ | ៣.៦២០,២ | ៤.៩២៧,០ | ៥.៥០៤,២ |
| នាំចេញតាមប្រព័ន្ធ GSP ( ភាគច្រើនសម្លៀកបំពាក់ ) | ២.៦២៦,៧ | ៣.៤៣៥,៧ | ៤.៦៣៩,២ | ៥.២៥៨,៧ |
| នាំចេញផលិតផលក្នុងស្រុកផ្សេងៗ | ១០៧,០ | ១៨៤,៥ | ២៨៧,៨ | ២៤៥,៦ |
| នាំចេញបន្ត( រាប់បញ្ចូលចំណេញ និងចំណាយដឹកជញ្ជូន ) | ២៦២,០ | ២៦៤,១ | ២៩២,៤ | ២៩៧,៨ |
| នាំចូល (FOB) | -៤.៤៨៩,៩ | -៥.៤៦៦,០ | -៦.៧០៩,៥ | -៧.៥៤៣,៨ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុក | -៤.២៨៨,៨ | -៥.២៦២,២ | -៦.៤៨៩,៣ | -៧.៣២០,២ |
| សម្លៀកបំពាក់ | -១.០៤៩,៩ | -១.៣៥៨,៨ | -១.៧២៥,៨ | -២.០៦១,៦ |
| ប្រេងឥន្ធនៈ | ៤១៣,៧ | -៤៦៥,៩ | -៩៦៨,៧ | -១.១៣៣,៩ |
| អគ្គិសនី | -៥៤,៥ | -១០៤,៩ | -១២៥,១ | -១៤៥,៧ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុកផ្សេងៗ | -២.៧៧០,៦ | -៣.៣៣២,៦ | -៣.៦៦៩,៧ | -៣.៩៧៩,១ |
| នាំចូលសម្រាប់នាំចេញបន្ត | -២០១,១ | -២០៣,៧ | -២២០,២ | -២២៣,៦ |
| **សេវា (សុទ្ធ)** | **៦១៥,៣** | **៦៩៧,៣** | **៨៨៩,២** | **១.០៧៣,០** |
| ចំណូល | ១.៥២៤,៧ | ១.៦៦៩,០ | ២.២១២,៦ | ២.៦៩៦,០ |
| ក្នុងនោះ : សេវាធ្វើដំណើរ | ១.០៨១,៥ | ១.១៧៩,៦ | ១.៦១៦,៤ | ១.៩៩៩,៥ |
| ចំណាយ | -៩០៩,៤ | -៩៧១,៧ | -១.៣២៣,៤ | -១.៦២៣,០ |
| ក្នុងនោះ : សេវាធ្វើដំណើរ | -១០៣,៥ | -១៩៧,៨ | -២៥៣,៤ | -៣៦១.៣ |
| **ប្រាក់ចំណូល (សុទ្ធ)** | **-៤៧៧,២** | **-៥២៩,៨** | **-៦៩៤,៩** | **-៨០០,១** |
| ចំណូល | ៥៥,៦ | ៥៨,៧ | ៦១,៣ | ៦៦,៣ |
| ក្នុងនោះ : ការប្រាក់ | ២៦,២ | ២៨,៤ | ២៩,២ | ៣២,២ |
| ចំណាយ | -៥៣២,៨ | -៥៨៨,៥ | -៧៥៦,២ | -៨៦៦,៤ |
| ក្នុងនោះ : - ការបង់ការប្រាក់ | -៤៨,៨ | -៥២,០ | -៥៤,២ | -៥១,៣ |
| - ចំណូលពីហ៊ុន | -៣៨៤,២ | -៣៨៥,៦ | -៥៧២,៣ | -៧៦០,៩ |
| **បង្វែរឯកជន (សុទ្ធ)** | **២៩០,៤** | **២៤៣,០** | **១៧៣,៥** | **១៥២,៨** |
| ចំណូល | ៣៦៧,៦ | ៣៥១,៥ | ៣៥៥,០ | ២៧៨,១ |
| ចំណាយ | -៧៧,២ | -១០៨,៥ | -១០៩,៦ | -១២៥,៤ |
| **សមតុល្យគណនីចរន្ត** (មិនរាប់បញ្ចូលបង្វែរផ្លូវការ) | **-១.០៦៥,៧** | **-១.១៧១,២** | **-១.១២២,២** | **-១.៣១៦,២** |
| **បង្វែរផ្លូវការ (សុទ្ធ)** | **៥៩២,៦** | **៧៣០,៥** | **៦៣២,៦** | **៦១០,៧** |
| ចំណូល | ៥៩២,៩ | ៧៣០,៨ | ៦៣២,៩ | ៦១១,០ |
| ចំណាយ | -០,៣ | -០,៣ | -០,៣ | -០,៣ |
| **សមតុល្យគណនីចរន្ត និងបង្វែរផ្លូវការ** | **-៤៧៣,០** | **-៤៤០,៧** | **-៤៨៩,៦** | **-៧០៥,៥** |
| **គណនីហិរញ្ញវត្ថុ** | **៤៧៦,៧** | **៦២០,៤** | **៨២៤,៨** | **១.០៧១,១** |
| **ឥណទេយ្យផ្លូវការ** (មិនរាប់បញ្ចូល IMF) **សុទ្ធ*** | ១៥៣,១ | ២៤៤,៩ | ២២១,៨ | ១៣៤,០ |
| ដកប្រាក់ | ១៦៤,១ | ២៥៧,១ | ២៣៣,៣ | ១៤៧,៩ |
| ទូទាត់ | -១១,០ | -១២,១ | -១១,៤ | -១៣,៩ |
| **វិនិយោគមិនផ្លូវការ** | **៣២៣,៦** | **៣៧៥,៤** | **៦០២,៩** | **៩៣៧,១** |
| វិនិយោគផ្ទាល់ (សុទ្ធ)* | ៥២០,២ | ៧៦២,០ | ៨៧២,៥ | ១.២១៦,៥ |
| វិនិយោគលើផលប័ត្រ (សុទ្ធ) * | -៧,៦ | -៣៦,៧ | -៦,១ | -៣៩,០ |
| វិនិយោគផ្សេងទៀត (សុទ្ធ) * | -១៨៩,០ | -៣៤៩,៩ | -២៦៣,៤ | -២៤០,៤ |
| **កំហុស និងរំលង** | **-៨,៤** | **-២៩,៤** | **-២៦,៤** | **-៤៣,៧** |
| **សមតុល្យរួម** | **-៤,៧** | **១៥០,៣** | **៣០៨,៧** | **៣២១,៩** |
| **ហិរញ្ញប្បទាន** | **៤,៧** | **-១៥០,៣** | **-៣០៨,៧** | **-៣២១,៩** |
| ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិ * | -៨,១ | -១៦៣,០ | -៣២១,៥ | ៣៣៤,៦ |
| បម្រែបម្រួលទ្រព្យសកម្មជាទុនបម្រុងបរទេស | -១១៦,៦ | -១៦៣,០ | -៣២១,៥ | ៣៣៤,៦ |
| ការប្រើប្រាស់ឥណទានរបស់ IMF | -- | -- | -- | -- |
| ការបែងចែកSDR | ១០៨,៥ | — | -- | -- |
| ហិរញ្ញប្បទានពិសេស | ១២,៨ | ១២,៨ | ១២,៨ | ១២,៨ |

** តម្លៃវិជ្ជមានតំណាងឲ្យកំណើនទ្រព្យអកម្មបរទេស ឬថយចុះទ្រព្យសកម្មបរទេស និងតម្លៃអវិជ្ជមានតំណាងឲ្យកំណើនទ្រព្យសកម្មបរទេស ឬការថយចុះទ្រព្យអកម្មបរទេស*

***ប្រភព*** : ទិន្នន័យទទួលបានពីអាជ្ញាធរកម្ពុជានិងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

***កំណត់សំគាល់*** : - ទិន្នន័យបណ្តោះអាសន្នសម្រាប់ឆ្នាំ២០០៩-២០១១ *(ទិន្នន័យទាំងនេះអាចនឹងត្រូវបានកែប្រែឡើងវិញក្នុងពេលអនាគត)*

- ព = ព្យាករណ៍ទិន្នន័យសម្រាប់ឆ្នាំ *២០១២*